# ក្រសួងអប់រំ យុវជន និង កីឡា

Ministry of Edacation, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការរៀន និងបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ

# ករណីសិក្សា៖ វិទ្យាល័យ គិត ម៉េង ប្រាសាទ

# Learning and Teaching English Language at Lower-Secondary School In Takeo Province

## Case Study: Kith Meng Brasat High School


ដោយ/ by

**អ៊ឹម សិរីរដ្ឋ**

EM SEREYRATH


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ  ជំនាន់ទី ៦

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧ - ២០១៩


ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF )

# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការរៀន និង បង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្ត តាកែវ

## ករណីសិក្សា៖ វិទ្យាល័យ គិត ម៉េង ប្រាសាទ

# Learning and Teaching English Language at Lower-Secondary School In Takeo Province

## Case Study: Kith Meng Brasat High School

**ដោយ**/ by

**អ៊ឹម សិរីរដ្ឋ**

EM SEREYRATH

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ៦**

**ឆ្នាំសិក្សា ២០១៧ - ២០១៩**

**សាស្ត្រាចារ្យដឹកនាំ៖ បណ្ឌិត នួន វីរ៉ា**

**សាស្ត្រាចារ្យដឹកនាំរង៖ លន លីណា**

**ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

Supported by Cambodia International Education Support Foundation ( CIESF )

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៦២៩ **អយក.** ប្រក
**(ការសម្ងាត់)**

## លិខិតឧទ្ទេសនាម

**យោង៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត ទូវ រ៉ៃ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម ឡៅ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក នី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារុំម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត នី ផាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត ស៊ិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈួក ច័ន្ទនាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី វេជ្ជា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

# សេចក្ដីប្រកាសរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ការរៀន និងបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ**» សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី ៦ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ចំពោះស្នាដៃនេះ ពុំទាន់ត្រូវបានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានខ្លឹមសារដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ គឺជាស្នាដៃរបស់ខ្ញុំបាទតែម្នាក់ឯងពិតប្រាកដដោយពុំមានចាប់ដៃគូជាមួយនិស្សិតណាម្នាក់ឡើយ។

*ថ្ងៃ ព្រហស្បតិ៍ ០៧ រោច ខែ បុស្ស ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣*

*រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០២០*

**ហត្ថលេខាបេក្ខជន**

**អ៊ឹម សិរីរដ្ឋ**

# លិខិតបញ្ជាក់

បណ្ឌិត **នួច វីរ៉ា** ជាសាស្ត្រាចារ្យដឹកនាំ
លោក **លន លីណា** ជាសាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **អ៊ឹម សិរីរដ្ឋ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ការរៀន និង បង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ**" ពិតប្រាកដមែន។

ថ្ងៃព្រហស្បតិ៍ ០៧ រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០

| | |
|---|---|
| ...................................... | .................................... |
| **បណ្ឌិត នួច វីរ៉ា** | **លន លីណា** |
| នាយករងវិទ្យាស្ថានជាតិអប់រំ | មន្ត្រីដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ |

# មាតិកា


សេចក្តីប្រកាសរបស់បេក្ខជន ..................... iii

លិខិតបញ្ជាក់ ..................... iv

បញ្ជីមាតិកា ..................... v

បញ្ជីក្រាប ..................... ix

បញ្ជីតារាង ..................... x

សេចក្តីថ្លែងអំណរគុណ ..................... xi

មូលន័យសង្ខេប ..................... xiii

Abstract ..................... xv

**ជំពូកទី ១ សេចក្តីផ្តើម** ..................... ១

១.១- លំនាំបញ្ហា ..................... ១

១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ ..................... ៣

១.៣- គោលបំណងនៃការស្រាវជ្រាវ ..................... ៤

១.៤- សំណួរស្រាវជ្រាវ ..................... ៤

១.៥- សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ..................... ៤

១.៦- ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ ..................... ៥

១.៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..................... ៥

**ជំពូកទី២ រំលឹកទ្រឹស្តី** ..................... ៩

២.១. និយមន័យពាក្យគន្លឹះ ..................... ៩

២.២. គុណសម្បត្តិគ្រូភាសាអង់គ្លេស ........................................................................ ១០

២.២.១. ចំណេះដឹងវិជ្ជាជីវៈគ្រូបង្រៀនភាសាអង់គ្លេស ................................................ ១១

២.២.២. វិធីសាស្ត្របង្រៀនភាសាអង់គ្លេស .................................................................. ១៣

២.៣. សម្ភារបង្រៀនភាសាអង់គ្លេស ........................................................................ ១៥

២.៤. កម្មវិធីសិក្សាភាសាអង់គ្លេស ........................................................................ ១៧

២.៥. ការលើកទឹកចិត្ត ......................................................................................... ២០

២.៦. ការរៀបចំមេរៀន ឬកិច្ចតែងការបង្រៀន ............................................................ ២២

២.៧. បរិមាណសិស្សក្នុងថ្នាក់ ................................................................................ ២២

**ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ** ........................................................................ ២៥

៣.១. ការប្រមូលទិន្នន័យ ...................................................................................... ២៥

៣.២. ទីតាំងនៃការស្រាវជ្រាវ ................................................................................... ២៥

៣.៣. ការជ្រើសរើសសំណាក .................................................................................. ២៦

៣.៤. ឧបករណ៍ស្រាវជ្រាវ ..................................................................................... ២៦

៣.៥. ដំណាក់កាលនៃការប្រមូលទិន្នន័យ ................................................................. ២៨

៣.៦. ការវិភាគទិន្នន័យ ........................................................................................ ២៩

៣.៧. ក្រមសីលធម៌នៃការស្រាវជ្រាវ ......................................................................... ៣០

**ជំពូកទី៤ លទ្ធផល និងការពិភាក្សា** .................................................................... ៣២

៤.១ ការយល់ឃើញរបស់នាយក (សម្ភាសន៍) ............................................................... ៣៣

៤.២ ការយល់ឃើញរបស់គ្រូ(សម្ភាសន៍) ...................................................................... ៣៤

៤.២.១ គុណវុឌ្ឍិគ្រូបង្រៀន ......................................................................................................៣៤

៤.២.២ កម្មវិធីសិក្សា ........................................................................................................... ៣៥

៤.២.៣ សម្ភារទ្រទ្រង់ការបង្រៀន ............................................................................................ ៣៦

៤.២.៤ សកម្មភាពរៀនរបស់សិស្សក្នុងថ្នាក់ ................................................................................ ៣៧

៤.២.៥ ការរៀបចំមេរៀន ....................................................................................................... ៣៧

៤.២.៦ បរិមាណសិស្សក្នុងថ្នាក់.............................................................................................. ៣៧

៤.២.៧ ស្ថានភាពសិស្សក្នុងថ្នាក់............................................................................................. ៣៨

៤.២.៨ បញ្ហាប្រឈមនានាចំពោះការបង្រៀនភាសាអង់គ្លេស ..................................................... ៣៨

៤.៣ ការយល់ឃើញរបស់សិស្ស(សំណួរស្ទង់មតិ) ...................................................................... ៣៨

៤.៣.៣ សម្ភារឧបទ្ទេស ..........................................................................................................៤១

៤.៣.៤ សកម្មភាពរៀនក្នុងថ្នាក់ ...............................................................................................៤២

៤.៣.៥ ចំនួនសិស្សក្នុងថ្នាក់ ....................................................................................................៤៣

៤.៣.៦ ស្ថានភាពសិក្សារបស់សិស្ស .......................................................................................... ៤៥

៤.៤ ការពិភាក្សា..................................................................................................................... ៤៦

៤.៤.១ ការពិភាក្សាទៅលើសំណួរសម្ភាស................................................................................... ៤៦

៤.៥. សំណូមពរទាក់ទងនឹងបញ្ហាប្រឈមនានាចំពោះការសិក្សាភាសាអង់គ្លេសរបស់សិស្ស ...............................................................................................................................៤៧

**ជំពូក ៥ សេចក្តីសន្និដ្ឋាន និង សំណូមពរ** .................................................................................. ៤៩

៥.១. សេចក្តីសន្និដ្ឋាន ........................................................................................................... ៤៩

៥.២. សំណូមពរ ........................................................................................................ ៤៩

៥.៣. ការស្រាវជ្រាវបន្ត ................................................................................................ ៥១

**ឯកសារយោង** .................................................................................................... ៥២

ឧបសម្ព័ន្ធ ............................................................................................................ ៥៣

# បញ្ជីក្រាប

ក្រាបទី១៖គុណវុឌ្ឍគ្រូបង្រៀនភាសាអង់គ្លេស ........................................................ ៤០

ក្រាបទី២៖កម្មវិធីសិក្សា ........................................................................................ ៤១

ក្រាបទី៣៖សម្ភារឧបទ្ទេស ........................................................................................ ៤២

ក្រាបទី៤៖សកម្មភាពរៀន និងបង្រៀន ........................................................................ ៤៣

ក្រាបទី៥៖ចំនួនសិស្សក្នុងថ្នាក់ ................................................................................ ៤៥

ក្រាបទី៦៖ស្ថានភាពសិក្សារបស់សិស្ស ........................................................................ ៤៦

# បញ្ជីតារាង

តារាងទី១៖ សិស្ស........................................................................................................ ៣២

តារាងទី២៖ចម្លើយរបស់កម្រងសំណួរតាមក្រុម.........................................................៣៩

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ អ្នកមានគុណទាំងពីរ បងប្អូន និងមិត្តភក្តិទាំងអស់ដែលបានជួយឧបត្ថម្ភគាំទ្រទាំងផ្នែកថវិកា សម្ភារៈ ចិត្ត គំនិត ប្រាជ្ញា និងផ្នែកស្មារតីដល់ខ្ញុំបាទក្នុងខណៈពេលសិក្សានាពេលកន្លងមក។

ខ្ញុំបាទសូមអនុញ្ញាតគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា និងថ្នាក់ដឹកនាំប្រទេសគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំកសាងប្រទេសជាតិឱ្យមានសន្តិភាព ស្ថេរភាពនិងការអភិវឌ្ឍលើគ្រប់វិស័យរហូតមកដល់បច្ចុប្បន្ននេះ (ប្រទេសជាតិមានសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ ទើបការអប់រំមានភាពសម្បូរបែប ល្អប្រសើរ មានគុណភាព និងមានការប្រកួតប្រជែងក្នុងតំបន់និងសកលលោក)។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះក្រសួងអប់រំ យុវជន និងកីឡា និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់របស់ក្រសួងអប់រំ ដែលបានខិតខំប្រឹងប្រែងយ៉ាងសស្រាក់សស្រាំក្នុងការកសាងនិងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា ឱ្យមានភាពល្អប្រសើរគួរជាទីមោទនៈ (ពោលគឺការកសាងធនធានមនុស្សពេញលេញជូនជាតិមាតុភូមិ)។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងក្រៃលែងដល់វិទ្យាស្ថានជាតិអប់រំ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃវិទ្យាស្ថានជាតិអប់រំ និងជាពិសេសអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (Cambodia International Education Support Foundation, CIESF) ដែលបានរៀបចំកម្មវិធី និងផ្ដល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនេះឡើងនិងផ្ដល់ឱកាសសម្រាប់ខ្ញុំបាទបានប្រឡងជាប់ ហើយបានចូលសិក្សានៅវិទ្យាស្ថានជាតិអប់រំ ក្នុងឆ្នាំសិក្សា(២០១៧-២០១៩) នាពេលកន្លងទៅថ្មីៗនេះ។

ខ្ញុំបាទសូមគោរពថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ គណៈកម្មការគ្រប់គ្រងនិងដឹកនាំការបណ្ដុះបណ្ដាលវគ្គសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំគ្រប់លំដាប់ថ្នាក់ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រីជាសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយនូវពេលវេលាដ៏មានតម្លៃផ្ទេរចំណេះដឹង បំណិន ឥរិយាបថ បទពិសោធន៍ និងមេរៀនជីវិតល្អៗជាច្រើន ពិសេសលើផ្នែកគ្រប់គ្រងដឹកនាំ ការរៀបចំ និងធ្វើផែនការក្នុងវិស័យអប់រំ មកដល់ខ្ញុំបាទផ្ទាល់និងមិត្តរួមជំនាន់ដទៃទៀតដូចៗគ្នានិងស្មើៗគ្នា។ ជាពិសេស ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងអនេកដែលរកអ្វីមកប្រៀបផ្ទឹមពុំបានជូនចំពោះសាស្ត្រាចារ្យបណ្ឌិត **នូច ទីរ៉ា** ជាសាស្ត្រាចារ្យណែនាំ និងលោក **លន លីណា** ជាសាស្ត្រាចារ្យជំនួយ ដែលលោកទាំងទ្វេរតែងតែចំណាយពេលដ៏មានតម្លៃពន្យល់ណែនាំពីចំណុចគន្លឹះល្អៗនៃដំណាក់កាលមួយទៅដំណាក់កាលមួយនិងគ្រប់ជំហានទាំងអស់ រហូតទើបធ្វើឱ្យ

ការសិក្សាស្រាវជ្រាវរបស់ខ្ញុំបានសម្រេចជោគជ័យ បញ្ចប់យ៉ាងរលូន ប្រកបដោយគុណភាព និងប្រសិទ្ធភាពសម្រាប់បម្រើឱ្យការអភិវឌ្ឍវិស័យអប់រំកម្ពុជា។ មួយចំណែកទៀត ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះ លោក លោកស្រីជាមិត្តរួមជំនាន់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំទាំងអស់ ខ្ញុំពិតជាមានមោទនភាពដែលមានលោក លោកស្រីជាមិត្ត ព្រោះលោកអ្នកទាំងអស់គ្នា ជាមនុស្សដែលមានសមានចិត្តល្អ ក្នុងការចែករំលែកនូវចំណេះដឹង បំណិន ឥរិយាបថ បទពិសោធន៍ និងមេរៀនជីវិតល្អៗសម្រាប់ខ្ញុំ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់ គណៈគ្រប់គ្រងមន្ទីរអប់រំខេត្ត ការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងសាលា បុគ្គលិកទីចាត់ការ លោកគ្រូ អ្នកគ្រូ ព្រមទាំងប្អូនៗសិស្សានុសិស្ស នៃវិទ្យាល័យគោលដៅដែលបានសហការនិងសម្របសម្រួល យ៉ាងល្អប្រសើរ ក្នុងដំណើរការចុះប្រមូលទិន្នន័យ ដែលជាកត្តារួមចំណែកមួយយ៉ាងធំធេង ក្នុងការធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំទទួលបានលទ្ធផលជោគជ័យមួយរយភាគរយ។

ខ្ញុំបាទសូមឧទ្ទិសនូវស្នាដៃស្រាវជ្រាវនេះ ជូនចំពោះដួងវិញ្ញាណក្ខន្ធបុព្វបុរសខ្មែរគ្រប់សម័យកាល ដែលបានតស៊ូដើម្បីបុព្វហេតុជាតិមាតុភូមិនិងជូនចំពោះដួងវិញ្ញាណក្ខន្ធញាតិការប្រាំពីរសន្តានដែលបានបែកកាយរំលាយក្ខន្ធទៅកាន់បរលោកហើយ និងសូមលោកទាំងនោះបែរភក្ត្រាងាកក្រោយឱ្យពរជ័យដល់ប្រទេសកម្ពុជាប្រកបដោយសន្តិភាព និងការអភិវឌ្ឍជានិច្ចនិរន្តរ៍ទៅ។

ជាទីបញ្ចប់ ខ្ញុំបាទសូមបួងសួងដល់អស់វត្ថុស័ក្តិសិទ្ធិក្នុងលោក ពិសេសក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រសិទ្ធពរជ័យសិរីបវរមហាប្រសើរ ជូនចំពោះលោកអ្នកមានគុណទាំងពីរនិងអ្នកទាំងអស់គ្នា សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងកាយ ប្រាជ្ញា និងស្មារតីមាំមួន ភ្លឺថ្លា មានសេចក្តីសុខ និងសេចក្តីចម្រើន រកទទួលទានមានបាន កើតកាលវាលគុម្ព ត្រជាក់ត្រជុំ សុខដុមរមនា និងម្រេចបានជោគជ័យគ្រប់ភារកិច្ចជានិច្ចនិរន្តរ៍ និងជួបប្រសព្វនូវពុទ្ធពរទាំងបួន ប្រការគឺ៖ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# មូលន័យសង្ខេប

កិច្ចការស្រាវជ្រាវនេះមានគោលបំណងស្វែងរក និងបង្ហាញឱ្យឃើញពីស្ថានភាពជាក់ស្តែងនៃការបង្រៀន និង រៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងវិទ្យាល័យ គិត ម៉េង ប្រាសាទ ដែលស្ថិតនៅក្នុង ភូមិក្រាំងប្រទាល ឃុំដូង ស្រុកបាទី ខេត្ត តាកែវ និងបញ្ហាប្រឈមនានាដែលជះឥទ្ធិពលដល់ការបង្រៀន និងរៀនភាសាអង់គ្លេស។

វិធីសាស្ត្រដែលអ្នកសិក្សាស្រាវជ្រាវយកមកប្រើ ដើម្បីប្រមូលទិន្នន័យនោះគឺវិធីសាស្ត្របែបបរិមាណវិស័យ (Quantitative Method) និង វិធីសាស្ត្របែបគុណវិស័យ (Qualitative Method) ។ ក្នុងការសិក្សាស្រាវជ្រាវបែបបរិមាណវិស័យអ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវកម្រងសំណួរបែបពហុជ្រើសរើសសម្រាប់សិស្ស រីឯវិធីសាស្ត្របែបគុណវិស័យវិញ អ្នកស្រាវជ្រាវចងក្រងជាកម្រងសំណួរបែបសំណួរបើកសម្រាប់សម្ភាស គ្រូបង្រៀនភាសាអង់គ្លេស នាយកសាលា និង នាយករង ដើម្បីងាយទទួលបានព័ត៌មានបន្ថែម សម្រាប់គាំទ្រដល់ចម្លើយមួយចំនួននៅក្នុងកម្រងសំណួរបែបបរិមាណវិស័យ។ ធាតុសំណាកដែលបានចូលរួមនៅក្នុងការស្រាវជ្រាវ ត្រូវបានជ្រើសរើសយកចេញពី ការសម្ភាសនាយកវិទ្យាល័យ (១នាក់) នាយករង(១នាក់) គ្រូបង្រៀនភាសាអង់គ្លេសចំនួន ៣ នាក់។ កម្រងសំណួរដែលឱ្យសិស្សបំពេញមានចំនួន ២៥០ (ពីររយហាសិប) ។ សិស្សចំនួន ៩០ (កៅសិប) នាក់ត្រូវបានជ្រើសរើសចេញពីថ្នាក់ទី ៧ សិស្សចំនួន ៨០ (ប៉ែតសិប) នាក់ត្រូវបានជ្រើសរើសចេញពីថ្នាក់ទី ៨ និងសិស្សចំនួន ៨០ (ប៉ែតសិប) នាក់ទៀតត្រូវបានជ្រើសរើសចេញពីថ្នាក់ទី ៩ ដោយអ្នកស្រាវជ្រាវ។

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបានបង្ហាញថា ស្ថានភាពជាក់ស្តែងទាក់ទងទៅនឹងការបង្រៀនភាសាអង់គ្លេសនៅកម្រិតមធ្យមបឋមភូមិក្នុងវិទ្យាល័យ គិត ម៉េង ប្រាសាទ មានភាពល្អបង្គួរ និង មានការខ្វះខាតខ្លះៗ ។ គ្រូបង្រៀនភាសាអង់គ្លេសទាំងបីនាក់មានកម្រិតសញ្ញាបត្រគរុកោសល្យត្រឹមត្រូវទៅតាមកម្រិតថ្នាក់ដែលគាត់បង្រៀន។ គ្រូបង្រៀន ១ នាក់កំពុងរៀនបន្តបរិញ្ញាបត្រ ១នាក់ចប់បរិញ្ញាបត្រនិង ១ នាក់ទៀតចប់បរិញ្ញាបត្រជាន់ខ្ពស់។ ជាងនេះទៅទៀតពួកគាត់សុទ្ធតែជាគ្រូដែលមានបទពិសោធន៍បង្រៀនយូរឆ្នាំ។ ពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការបង្រៀនវិញគឺគ្រូតែងតែឆ្លាស់វិធីសាស្ត្រគ្រប់ពេលដែលគាត់បង្រៀន ដោយម្តងគាត់ប្រើវិធីសាស្ត្រនេះ និងម្តងគាត់ប្រើវិធីសាស្ត្រនោះ។ លើសពីនេះទៅទៀត គ្រូបង្រៀនទាំងបីនាក់សុទ្ធតែបានរៀបចំកិច្ចតែងការបង្រៀនមុនពេលបង្រៀនមេរៀននីមួយៗ ទោះបីពេលខ្លះពួកគាត់ថាបានរៀបចំមិនគ្រប់ជំហ៊ានក៏ដោយ តែពួកគាត់ពិតជាបានរៀបចំ។

ទន្ទឹមនឹងចំណុចវិជ្ជមានខាងលើ ក្នុងនោះក៏មានចំណុចខ្វះខាតមួយចំនួនដែលជាបញ្ហា

ប្រឈមទាមទារឱ្យមានដំណោះស្រាយផងដែរ។បញ្ហាទាំងនោះមានដូចជាកង្វះសម្ភារទ្រទ្រង់ចាំបាច់សម្រាប់ការបង្រៀនភាសាអង់គ្លេសមួយចំនួនរួមមាន ម៉ាញ៉េចាក់កាសែតឬស៊ីឌីប្រដាប់បំពងសម្លេង (MP3 player or Speaker) បន្ទប់សម្រាប់ការអនុវត្តស្តាប់ និងមើលវីដេអូ និងបណ្ណាល័យដែលខ្វះឯកសារជាភាសាអង់គ្លេសជាដើម។ក្នុងចំណោមគ្រូបង្រៀនភាសាអង់គ្លេសទាំបីនាក់មានតែគ្រូបង្រៀនភាសាអង់គ្លេសចំនួន ១នាក់ទេដែលទទួលបានការបណ្តុះបណ្តាលដែលទាក់ទងទៅនឹងវិធីសាស្រ្តបង្រៀនភាសាអង់គ្លេសបន្ថែមដើម្បីបំប៉នសមត្ថភាពក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។

ក្រៅពីនេះចំនួនម៉ោងបង្រៀននិងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិក៏នៅតែជាបញ្ហាដោយសារតែក្រសួងអប់រំបានកំណត់មានឱ្យការបង្រៀននិងរៀនភាសាអង់គ្លេសត្រឹមតែ ៤ ម៉ោងប៉ុណ្ណោះក្នុងមួយសប្តាហ៍។

ម្យ៉ាងវិញទៀត បញ្ហាប្រឈមដែលជះឥទ្ធិពលអវិជ្ជាមានខ្លាំងជាងគេដល់ដំណើរការបង្រៀន និងរៀនភាសាអង់គ្លេស គឺ ចំនួនសិស្សក្នុងថ្នាក់។ ដោយសារកង្វះខាតគ្រូ និងអគារសិក្សា វិទ្យាល័យ គិត ម៉េង ប្រាសាទ ត្រូវរៀបចំសិស្សមួយថ្នាក់យ៉ាងតិច ៤២ នាក់ រហូតដល់ ៤៩ នាក់ ក៏មាន។

# Abstract

This research study is done to find out the real situation of teaching and learning English language conducted at Kith Meng Brasat High School located in Krangbroteal Village, Doung Commune, Bati District and Takeo Province, Cambodia, and it is aimed to find out the main cause effected the process of Learning and Teaching English Language at Lower Secondary School.

The researcher has used both methods to do this study. Those methods are (Qualitative and Quantitative.) The questionnaires of the Qualitative are the combinations of Open-ended Questions used to interview a School Principal, a Vice Principal and three teachers of English language responsible for teaching English to students at Lower Secondary School: Grade 7, Grade 8 and Grade 9. Two hundred and fifty (250) students are asked to complete the questionnaire of Quantitative. Ninety (90) students are chosen from Grade 7. Eighty (80) students are selected from Grade 8 and another eighty (80) students are chosen from Grade 9. All the students are chosen carefully and scientifically by the researcher.

The result shows that the real situation is fairly good, and that it is still lack of something that needs to be solved. The three teachers of English language are well-qualified because all of the three were trained properly at pedagogy. One teacher is pursuing Bachelor´s Degree in TEFL. One holds Bachelor´s Degree in English Literature, and another one holds Master´s Degree in TESOL.

Additionally, all of the three teachers have been teaching English since long. One teacher has been a teacher of English since 2008. One has become a teacher of English since 2009, and another one since 2012. Based on the answers given, all of them always prepare the lesson plans before teaching. One of them said he always prepares the lessons plans before teaching even sometimes he couldn´t complete all the steps, five steps.

Contrary to the positive points described above, there are still some points to be improved. Those challenges are the teaching materials that are very important for the process of learning and teaching English Language. There is only one (SPEAKER)

shared by the three teachers. There is no listening room that the students can listen to audios or songs in English. There exist no a room that the students can watch movies or films in English, and there are not enough documents written in English stored in the library. Out of the three teachers of English language, only one has been chosen to attend the training courses related to how to teach English, Teaching Methodology, for the last five years.

Another challenge is the number of hour that the Ministry of Education allows to teach English. At Lower Secondary School, four hours a week is the limited hour set by the Ministry.

The last and most challenging factor is the number of the student in the class. Because of the number of teacher is not enough and due to the lack of buildings, in each class at Kith Meng Brasat High School, it is loaded from at least forty students a class, and sometimes there is forty-nine a class.

Based on the findings, the researcher would love suggest that the the provincial Departmet of Education and the  Ministry did provide some demanding materials such speakers, LCD projectors, a listening room and a room for watching films or movies in English to Kith Meng Brasat High School.

If the requested things above are provided, the conditions of learning and teaching English as well as other subjets at Kith Meng Brasat High School will be made better.

*THANK YOU!*

# ជំពូក ១

# សេចក្តីផ្តើម

# ជំពូកទី ១
# សេចក្ដីផ្ដើម

## ១.១- លំនាំបញ្ហា

ប្រទេសកម្ពុជាបានឆ្លងកាត់នូវអស្ថិរភាពនយោបាយ និងសង្គ្រាមស៊ីវិលអស់រយៈពេលជាង ៣ ទសវត្សរ៍ (១៩៧០-១៩៩៨) ហើយកត្តាទាំងនេះ បានជះឥទ្ធិពលអវិជ្ជមានដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៃប្រទេសកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា, ២០១៣)។ ក្រោយមកទៀត តាមរយៈគោលនយោបាយឈ្នះឈ្នះរបស់រាជរដ្ឋាភិបាលកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៨ សន្តិភាព និងស្ថិរភាពនយោបាយ បានចាប់ផ្ដើមល្អប្រសើរឡើងវិញ ដែលបានបើកឱកាសឱ្យប្រទេសកម្ពុជាមានការអភិវឌ្ឍជាបន្តបន្ទាប់លើគ្រប់វិស័យ ជាពិសេសវិស័យអប់រំ។ តាមរយៈការពង្រឹងវិស័យអប់រំប្រទេសកម្ពុជា ឱ្យមានគុណភាព ប្រសិទ្ធភាព និងភាពឆ្លើយតបទៅនឹងការរីកចម្រើនក្នុងតំបន់និងពិភពលោក រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តច្បាប់ស្ដីពីការអប់រំ ដើម្បីលើកទឹកចិត្ត និងជំរុញប្រជាពលរដ្ឋគ្រប់រូប ឱ្យទទួលបានការអប់រំយ៉ាងតិចនៅត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិថ្នាក់ទី៩ និងផ្ដល់ឱកាសឱ្យពួកគេទទួលបាននូវការសិក្សាពេញមួយជីវិត ដែលអាចពង្រឹង និងបង្កើននូវចំណេះដឹង បំណិនវិជ្ជាជីវៈ សមត្ថភាព ភាពថ្លៃថ្នូរ និងឥរិយាបថសមរម្យក្នុងសង្គម (ច្បាប់ស្ដីពីការអប់រំ, ២០០៧) ។ ម្យ៉ាងវិញទៀត នៅក្នុងផែនការអភិវឌ្ឍជាតិឆ្នាំ២០១៤-២០១៨ ក៏ដូចជាផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្ដោតយកចិត្តទុកដាក់សំខាន់លើការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្សរួមមាន៖ ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រនិងបច្ចេកទេស ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស ហើយក៏បានចាត់ទុកវិស័យអប់រំ ជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពដទៃទៀត ដែលអាចកសាងធនធានមនុស្សមួយដែលពោរពេញដោយសមត្ថភាព និងជំនាញច្បាស់លាស់ ដើម្បីចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា ឱ្យមានការរីកចម្រើនប្រកបដោយចីរភាព និងជឿនលឿនកាន់តែឆាប់រហ័សនាពេលអនាគតយ៉ាងខ្លី (RGC, 2014-2018)។

ផ្អែកលើចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាលកម្ពុជា គឺជំរុញកែប្រែនិងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញឆ្នាំ២០២៥ តាមរយៈការតភ្ជាប់ខ្សែសង្វាក់តម្លៃសកល សមាហរណកម្មទៅក្នុងបណ្ដាញផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡា ទន្ទឹមនឹងការពង្រឹងការប្រកួត

ប្រជែងនិងការលើកកម្ពស់ផលិតផលឧស្សាហកម្មក្នុងស្រុក ហើយឈានបន្តអភិវឌ្ឍទៅជាឧស្សាហកម្មទំនើបដែលផ្អែកលើមូលដ្ឋានបច្ចេកវិទ្យាព័ត៌មានវិទ្យានិងចំណេះដឹង (CIDP, 2015) និងកំណត់ទិសដៅរបស់ខ្លួន ជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងបន្តប្រែក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ ឬប្រទេសអភិវឌ្ឍន៍ក្នុងឆ្នាំ២០៥០, (TTD, 2015)។ ឆ្លើយតបទៅនឹងគោលដៅទាំងនេះ ព្រមទាំងដើម្បីអភិវឌ្ឍធនធានមនុស្សរបស់ប្រទេសកម្ពុជាឱ្យក្លាយជាពលរដ្ឋពេញលេញ ដែលទទួលបាននូវចំណេះដឹង បំណិន និងឥរិយាបថ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ជាពិសេសដើម្បីប្រកួតប្រជែង និងឆ្លើយតបទៅនឹងទីផ្សារការងារទាំងក្នុងពេលបច្ចុប្បន្ននិងអនាគត និងដើរឱ្យទាន់និន្នាការនៃការអភិវឌ្ឍ និងការរីកចម្រើនរបស់ពិភពលោក ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ជាអទិភាព និងកំពុងអនុវត្តនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំរយៈពេល ៥ ឆ្នាំ (២០១៤-២០១៨) គោលនយោបាយអប់រំជាតិ និងអន្តរជាតិ ព្រមទាំងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគាំទ្រដល់ការពង្រឹង និងលើកកម្ពស់វិស័យអប់រំនៅកម្ពុជាឱ្យមានភាពល្អប្រសើរជាបន្តបន្ទាប់ ជាពិសេសការបន្ស៊ីកំណែទម្រង់វិស័យអប់រំលើ ១៥ ចំណុច ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជា ក៏បានខិតខំសម្របខ្លួនទៅនឹងសកលភាវូបនីយកម្ម ជាពិសេសក្នុងឆ្នាំ១៩៩៩ ប្រទេសកម្ពុជាបានចូលជាសមាជិកនៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា ASEAN ដែលធ្វើឱ្យប្រទេសកម្ពុជាត្រូវការបណ្តុះបណ្តាលធនធានមនុស្សឱ្យមានភាពឆ្លើយតប និងមានការប្រកួតប្រជែងទាំងក្នុងប្រទេស ក្នុងតំបន់អាស៊ាន និងពិភពលោក (សេចក្តីប្រកាសស្តីពីប្រទេសកម្ពុជាចូលជាសមាជិកអាស៊ាន ១៩៩៩)។ ក្នុងក្របខណ្ឌអន្តរជាតិ ក្រសួងអប់រំក៏បានសម្របខ្លួនចូលក្នុងឆាកអន្តរជាតិលើផ្នែកអប់រំ ជាក់ស្តែង ក្រសួងអប់រំបាន និងកំពុងអនុវត្តនូវក្របខណ្ឌការអប់រំដើម្បីទាំងអស់គ្នា EFA ឆ្នាំ២០០០-២០១៥ ដែលផ្តោតការយកចិត្តទុកដាក់លើគោលដៅសំខាន់ៗចំនួន៦ គឺ ការយកចិត្តទុកដាក់និងការអប់រំលើកុមារតូច ដែលធានាឱ្យមានការអប់នៅកម្រិតបឋមសិក្សាជាសកល ធានានូវវិសមភាពនៃការអប់រំឱ្យឆ្លើយតបនឹងតម្រូវការរបស់មនុស្សពេញវ័យ សម្រេចឱ្យបាន៥០%នៃចំនួនអក្ខរកម្ម ជាពិសេសសម្រាប់ស្ត្រី លុបបំបាត់នូវគម្លាតនៃយេនឌ័រចំពោះមនុស្សប្រុសនិងស្រីនៅកម្រិតមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ និងធានាពង្រឹងគុណភាពអប់រំ ដែលផ្តោតលើអក្សរ លេខ និងបំណិនជីវិត (Bokova, 2015) គោលដៅអភិវឌ្ឍសហសវត្សរ៍ MDG ដែលសង្កត់ធ្ងន់លើ ៨ គោលដៅចម្បងៗ ក្នុងនោះគោលដៅទី២ គឺធានាសម្រេចឱ្យបាននូវការអប់រំពេញលេញជាសកលសម្រាប់ក្មេងប្រុសនិងក្មេងស្រីនៅកម្រិតបឋមសិក្សានៅត្រឹមឆ្នាំ២០១៥ (Moon, 2007) គោលដៅអភិវឌ្ឍប្រកបដោយចីរភាព

ដែលរួមមាន ១៧ គោលដៅសំខាន់ៗ ហើយក្នុងនោះគោលដៅទី៤ ការអបរំប្រកបដោយគុណភាព SDG4 គឺសង្កត់ធ្ងន់លើការអប់រំប្រកបដោយគុណភាព ដែលធានាឱ្យបាននូវគុណភាពអប់រំប្រកបដោយសមភាពនិងបរិយាប័ន្ន និងជំរុញឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា (Gutteres, 2017) ។

## ១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ

ជំនាញផ្សេងៗនិងបំណិននាសតវត្សរ៍ទី២១នេះ គឺមិនអាចកាត់ផ្ដាច់ចេញបានពីការសិក្សាភាសាបរទេសឡើយ ជាពិសេសគឺការសិក្សាភាសាអង់គ្លេស ព្រោះថាភាសានេះត្រូវបានគេប្រើប្រាស់ជាទូទៅ និងសកលក្នុងចំណោមប្រជាជាតិមកពីប្រទេសផ្សេងៗគ្នា។ គេបានប្រើវាជាភាសាវិទ្យាសាស្ត្រទៀតផង ដូច្នេះហើយដើម្បីស្វែងយល់ពីវិទ្យាសាស្ត្រ គេចាំបាច់ត្រូវចេះភាសាអង់គ្លេសឱ្យបានច្រើន (OKAMURA, 2004)។ នៅក្នុងប្រទេសកម្ពុជា អ្នកចេះភាសាអង់គ្លេសភាគច្រើនមានឱកាសការងារសម្បូរបែប និងអាចរកប្រាក់ចំណូលបានច្រើនជាងអ្នកមិនចេះភាសាអង់គ្លេស។ ការចេះប្រើប្រាស់ភាសាអង់គ្លេសបានល្អ នឹងអាចជួយបើកទូលាយនូវឱកាសល្អៗលាស់នៃសមត្ថភាពការងារ និងបង្កើនកម្រិតជីវភាពរស់នៅប្រចាំថ្ងៃ។ ដោយមើលឃើញពីសារសំខាន់នៃភាសាអង់គ្លេសនេះហើយ ទើបក្រសួងអប់រំ យុវជន និងកីឡា បានដាក់បញ្ចូលឱ្យមានការសិក្សាភាសាអង់គ្លេសនេះ ទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិចាប់ពីថ្នាក់ទី៤ រហូតដល់ថ្នាក់ទី១២ សម្រាប់ផ្ដល់ឱកាសឱ្យសិស្សានុសិស្ស អាចបង្វិតខ្លួនរបស់ពួកគេទៅនឹងចំណេះដឹងថ្មីៗបានយ៉ាងឆាប់រហ័សនិងទូលំទូលាយ (MOEYS, 2015) ។ តែទោះបីជាយ៉ាងណាក៏ដោយ ក្រសួងអប់រំ យុវជន និងកីឡា បានទទួលស្គាល់ និងបង្ហាញថា ការសិក្សាភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាបឋមភូមិនៃគ្រឹះស្ថានសិក្សាសាធារណៈនានា មិនទាន់មានលក្ខណៈទូលំទូលាយ មានភាពឆ្លើយតប និងនៅមានកម្រិតនៅឡើយ។ ម្យ៉ាងវិញទៀត តាមរយៈការស្រាវជ្រាវ៖ ការអប់រំភាសាបរទេសនៅកម្ពុជា បានបង្ហាញថា ការសិក្សាភាសាអង់គ្លេសនៅតាមគ្រឹះស្ថានសិក្សាសាធារណៈមានមតិរិះគន់លើចំណុចមួយចំនួនដូចជា៖ ខ្លឹមសារមេរៀនមិនទាន់មានលក្ខណៈពិស្ដារល្អ រូបភាព និងការពណ៌នាមួយចំនួនមិនស៊ីសង្វាក់គ្នា គ្មានផ្នែករំលឹកមេរៀន កម្មវិធីនិងមេរៀនច្រើនពេក កម្រិតសៀវភៅមិនសមស្របនឹងសមត្ថភាពរបស់សិស្ស គ្រូខ្វះវិធីសាស្ត្របង្រៀន ម៉ោងសិក្សាតិច (នាយកដ្ឋានគោលនយោបាយ, ២០១៧)។ ដូចនេះ ទើបអ្នកស្រាវជ្រាវបានលើកយកប្រធានបទ "ការបង្រៀន និង រៀនមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សានបឋមភូមិ ករណីសិក្សា វិទ្យាល័យ គិត ម៉េង ប្រាសាទ ខេត្ត តាកែវ" យកមកសិក្សាស្រាវជ្រាវ ដើម្បីរកឱ្យឃើញពី បញ្ហាប្រឈមនិងផលលំបាកនៃការសិក្សាភាសាអង់គ្លេសរបស់សិស្ស និងតម្រូវការចាំបាច់នៃការសិក្សាភាសា

អង់គ្លេសដែលបម្រើឱ្យការរីកចម្រើន និងពង្រឹងប្រសិទ្ធភាពនៃការបង្រៀននិងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងវិទ្យាល័យ គិត ម៉េង ប្រាសាទ និង ក្នុងប្រទេសប្រទេសកម្ពុជា។

## ១.៣- គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណង (១) ស្វែងយល់ស្ថានភាពនៃការបង្រៀន និងរៀនភាសអង់គ្លេស នៅកម្រិតមធ្យមសិក្សាបឋមភូមិ នៅវិទ្យាល័យ គិត ម៉េង ប្រាសាទ។ (២) សិក្សាអំពីកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការបង្រៀន និងរៀនភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាបឋមភូមិ នាពេលបច្ចុប្បន្ន។

## ១.៤- សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវខាងលើ អ្នកសិក្សាស្រាវជ្រាវបានកំណត់លើកយកសំណួរស្រាវជ្រាវចំនួនពីរមកពិភាក្សាដូចខាងក្រោមះ

១. តើស្ថានភាពនៃការបង្រៀន និងរៀនភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាបឋមភូមិ នៅវិទ្យាល័យ គិត ម៉េង ប្រាសាទ បច្ចុប្បន្នប្រព្រឹត្តទៅយ៉ាងដូចម្តេច?

២. តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលខ្លាំងជាងគេដល់គុណភាពនៃការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ នាពេលបច្ចុប្បន្ន?

## ១.៥- សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ នឹងបង្ហាញពីសារសំខាន់នៃការសិក្សាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ ផលលំបាកក្នុងការសិក្សាភាសាអង់គ្លេសរបស់សិស្ស និងតម្រូវការនៃការសិក្សាភាសាអង់គ្លេសឱ្យទទួលបានលទ្ធផលល្អប្រសើរ។ ម្យ៉ាងវិញទៀត ការសិក្សាស្រាវជ្រាវនេះ នឹងក្លាយជារបកគំហើញថ្មីមួយ សម្រាប់លោកគ្រូ/អ្នកគ្រូដែលកំពុងបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ដើម្បីឱ្យពួកគាត់យល់ដឹងពីចំណុចខ្វះខាតរបស់ខ្លួននិងសិស្ស និងតម្រូវការនៃការបង្រៀននិងរៀនភាសាអង់គ្លេសប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ។ ហើយការសិក្សាស្រាវជ្រាវនេះពិតជាមានសារសំខាន់ណាស់សម្រាប់លោកគ្រូអ្នកគ្រូដែលកំពុងបង្រៀនភាសាអង់គ្លេសនៅវិទ្យាល័យ គិត ម៉េង ប្រាសាទ។ លើសពីនេះទៀត វាក៏អាចជាប្រទីបបំភ្លឺផ្លូវសម្រាប់អ្នកអភិវឌ្ឍ និងរៀបចំកម្មវិធីសិក្សា ក្នុងការអភិវឌ្ឍនិងរៀបចំកម្មវិធីសិក្សាភាសាអង់គ្លេសថ្នាក់ជាតិ ឱ្យស្របទៅតាមតម្រូវការរបស់សិស្ស បរិបទសង្គម តម្រូវការទីផ្សារការងារ និងមានភាពឆ្លើយតប ជាពិសេសការសិក្សាស្រាវជ្រាវនេះ ក៏ចូលរួមជាវិភាគទានដល់អ្នកសិក្សា

ស្រាវជ្រាវក្រោយៗ ដើម្បីឱ្យពួកគេធ្វើការសិក្សាស្រាវជ្រាវបន្តទៀតពាក់ព័ន្ធនឹងប្រធានបទស្រដៀងគ្នានេះ។

## ១.៦- ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវនេះនឹងត្រូវធ្វើឡើងក្នុងវិទ្យាល័យ គិត ម៉េង ប្រាសាទ តែមួយទេពីព្រោះការស្រាវជ្រាវនេះជាករណីសិក្សា។ លោកនាយក (១នាក់) និង លោកនាយករង (១ នាក់) និងគ្រូបង្រៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិចំនួនបីនាក់ នឹងត្រូវបានសូមឱ្យបំពេញកម្រងសំណួរ និងធ្វើការសម្ភាសបន្ថែម ដាច់ដោយឡែកពីគ្នា ដែលរៀបចំឡើងដោយអ្នកសិក្សាស្រាវជ្រាវ។ លើសពីនេះទៀត សិស្សានុសិស្សពីថ្នាក់ទី ៧ ដល់ទី ៩ ចំនួន ២៥០ នាក់នឹងត្រូវបានជ្រើសរើសឱ្យបំពេញកម្រងសំណួរ ដែលរៀបចំឡើងដោយអ្នកស្រាវជ្រាវ។ សិស្សចំនួន ៩០ (កៅសិប) នាក់ត្រូវបានជ្រើសរើសចេញពីថ្នាក់ទី ៧ សិស្សចំនួន ៨០ (ប៉ែតសិប) នាក់ត្រូវបានជ្រើសរើសចេញពីថ្នាក់ទី ៨ និងសិស្សចំនួន ៨០ (ប៉ែតសិប) នាក់ទៀតត្រូវបានជ្រើសរើសចេញពីថ្នាក់ទី ៩ ។ ក្នុងការជ្រើសរើសសិក្សានុសិស្សនេះឱ្យបំពេញកម្រងសំណួរនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្ររើសសំណាកតាមបែប Random Sampling ។

## ១.៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជា ៥ ជំពូកធំៗ៖

**ជំពូកទី១៖** *សេចក្តីផ្តើម* នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការសិក្សាស្រាវជ្រាវ សំណួរស្រាវជ្រាវ និងដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវលើប្រធានបទ "ការបង្រៀន និង រៀនមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សានបឋមភូមិ ករណីសិក្សា វិទ្យាល័យ គិត ម៉េង ប្រាសាទ ខេត្ត តាកែវ"។

**ជំពូកទី២៖** *រំលឹកទ្រឹស្តី* នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកនូវទ្រឹស្តីចាស់ៗពាក់ព័ន្ធនឹងប្រធានបទ ពីអ្នកសិក្សាស្រាវជ្រាវមុនៗតាមរយៈសៀវភៅ កម្រងអត្ថបទស្រាវជ្រាវជាតិ និងអន្តរជាតិ រដ្ឋធម្មនុញ្ញ លិខិតបទដ្ឋានគតិយុត្ត សេចក្តីប្រកាស សារាចរណ៍ណែនាំ និងឯកសារពាក់ព័ន្ធនានារបស់ក្រសួងអប់រំ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើជាគំនិតនិងជាទុនសម្រាប់ស្រាវជ្រាវ និងបង្កើតជាស្នាដៃថ្មី។

**ជំពូកទី៣៖** *វិធីសាស្ត្រនៃការស្រាវជ្រាវ* ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ វិធីសាស្ត្រជ្រើសរើសសំណាក និងប្រភេទសំណាកព្រមទាំងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យរកតម្លៃមធ្យម និងភាគរយតាមរយៈកម្មវិធី SPSS និងកម្មវិធី MS. EXCEL សម្រាប់សង់ក្រាហ្វិក និងផ្គុំទិន្នន័យបញ្ចូលគ្នា។

*ជំពូកទី៤៖ លទ្ធផលនៃការស្រាវជ្រាវ* ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកធ្វើការវិភាគ និងធ្វើការបកស្រាយឱ្យបានយ៉ាងក្បោះក្បាយដើម្បីរកឱ្យឃើញនូវចំណុចល្អ ចំណុចដែលត្រូវកែលម្អនៅក្នុងបរិបទជាក់ស្តែងនៃការសិក្សាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាបឋមភូមិ និងតម្រូវការសម្រាប់នាយក គ្រូ និងសិស្សដែលបម្រើឱ្យការបង្រៀន និងរៀនភាសាអង់គ្លេសទទួលបានលទ្ធផលល្អប្រសើរ។

*ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ* ជាផ្នែកមួយដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការសន្និដ្ឋានលើចំណុចរួមទាំងអស់ដែលបានវិភាគ ព្រមទាំងផ្តល់ជាសំណូមពរមួយចំនួនដល់ក្រសួងអប់រំ មន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក គណៈគ្រប់គ្រងសាលា គ្រូបង្រៀនភាសាអង់គ្លេស អ្នកសិក្សាស្រាវជ្រាវក្រោយៗ និងភាគីពាក់ព័ន្ធក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍ និងធ្វើឱ្យស្ថានភាពនៃការបង្រៀន និងរៀនភាសាអង់គ្លេសរបស់សិស្ស និងគ្រូបង្រៀនភសាអង់គ្លេសមានភាពល្អប្រសើរជាងមុន។

# ជំពូក ២

# រំលឹកទ្រឹស្តី

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១. និយមន័យពាក្យគន្លឹះ

តើការបង្រៀន និង រៀន គឺជាអ្វី?

**ការបង្រៀន៖** ជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្ស លើកទឹកចិត្ត ឱ្យចេះរៀនដោយខ្លួនឯង ពង្រឹងនិងពង្រីកចំណេះដឹង បទពិសោធន៍ ដល់សិស្សគ្រប់រូប ។ សកម្មភាពនៃការបង្រៀនរួមមាន ការពន្យល់ ការដាក់ចំណោទ ការសួររកហេតុ និង ផល ការសួរសំណួរ ការលើកទឹកចិត្ត ការតាមដានសាវតាររបស់សិស្ស ការប្រឡងឬការវាយតម្លៃអំពីការរីកចម្រើនរបស់សិស្ស។ល។ ក្រៅពីមានចិត្ត គរុកោសល្យ គ្រូបង្រៀនក៏ដូចជាអ្នកដ៏ទៃទៀតដែរ ចាំបាច់ត្រូវតែបន្តស្រាវជ្រាវរកអ្វីដែលថ្មី អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន និងបង្កើតអ្វីដែលថ្មីពេញមួយជីវិតការងារ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស ២០១៥)។ Modern Concept បានលើកឡើងថាការបង្រៀនគឺជាបុព្វហេតុដែលជំរុញឱ្យសិស្សខិតខំរៀនសូត្រ និងទទួលបានចំណេះដឹង បទពិសោធន៍ និងមធ្យោបាយសម្រាប់ការរស់នៅ របស់ខ្លួនគេជាមួយសង្គមឱ្យសមស្របទៅតាមបំណងប្រាថ្នាដែលពួកគេចង់បានផងដែរ ។ ទិដ្ឋភាពដ៏សំខាន់បំផុតនៃដំណើរការបង្រៀន គឺ សិស្ស និងអ្វីដែលពួកគេរៀន (Dr. A. H. Sequeira, 2002)។ ការបង្រៀនគឺជាកិច្ចការរបស់គ្រូក្នុងការប្រើប្រាស់ចំណេះដឹងរបស់ខ្លួន សម្រាប់អភិវឌ្ឍសមត្ថភាពរបស់សិស្សឱ្យមានភាពល្អប្រសើរ (Thomas F. Green) ។ ការបង្រៀនគឺជាសកម្មភាពនៃការចែករំលែកការអប់រំ ដល់អ្នកសិក្សានៅក្នុងថ្នាក់រៀនមួយ ( Traditional teaching)។ ការបង្រៀនគឺជាការយកចិត្តទុកដាក់ទៅលើសកម្មភាពរបស់សិស្សរួមមាន សកម្មភាពលេង និង ការបង្កើតថ្មី ឬរបកគំហើញថ្មី ( Paul H. Hirst, 2004) ។

**ការរៀន៖** គឺជាទង្វើនៃការទទួលបានអ្វីដែលថ្មី ឬការកែប្រែនិងពង្រឹងចំណេះដឹង អាកប្បកិរិយា បំណិន គុណតម្លៃ ឬចំណង់ចំណូលចិត្តដែលមានស្រាប់ ហើយអាចពាក់ព័ន្ធនឹងការសំយោគព័ត៌មានប្រភេទផ្សេងៗគ្នាសម្រាប់ការប្រើប្រាស់ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅនិងអប់រំបច្ចេកទេស ២០១៥) ។ ការសិក្សា

គឺជាសកម្មភាពរបស់មនុស្សម្នាក់ៗ ដែលចង់បានចំណេះសម្រាប់យកទៅប្រើប្រាស់ក្នុងជីវភាពរស់នៅរបស់ខ្លួន និងធ្វើយ៉ាងណាឱ្យកាន់តែប្រសើរឡើង ពោលគឺធ្វើឱ្យមានការផ្លាស់ប្តូរជីវិតរស់នៅទាំងឥរិយាបថ និងស្មារតី ។

ការសិក្សាគឺជាដំណើរការនៃការទទួលយកនូវអ្វីដែលថ្មី និងអភិវឌ្ឍទៅលើអ្វីដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីទទួលបានការផ្លាស់ប្តូរទាំងស្រុងដែលឆ្ពោះទៅរកពលរដ្ឋពេញលេញ។ ការរៀនអាចកើតឡើងបានអាស្រ័យលើគម្រោង ឬកាលវិភាគនៃការសិក្សាដែលជាគ្រឿងជំរុញឱ្យត្រូវតែមករៀន។ ឥរិយាបថនៃការរៀនរបស់សិស្ស ក៏អាចឈានទៅដល់ចំណុចទីបញ្ចប់នៃគម្រោងការណ៍នេះផងដែរ (ThreeTypes of Learning, 2015)។

មធ្យមសិក្សាមបឋមភូមិ ជាកម្រិតសិក្សាបន្តពីបឋមសិក្សាដែលមានកម្រិតថ្នាក់ចាប់ពីថ្នាក់ទី ១ ដល់ថ្នាក់ទី ៦ ។ ចំណែកឯ មធ្យមសិក្សាមបឋមភូមិនេះ គឺជាកម្រិតសិក្សាដែលរាប់ចាប់ពីថ្នាក់ទី ៧ ដល់ថ្នាក់ទី ៩ ។ ការសិក្សាកម្រិតនេះ គឺជាការរៀបចំសិស្សឱ្យត្រៀមខ្លួនរួចរាល់ដើម្បីបន្តការសិក្សាចូលដល់ថ្នាក់ មធ្យមសិក្សាទុតិយភូមិដែលចាប់ពីថ្នាក់ទី ១០ ដល់ទី ១២ (ក្រសួងអប់រំ យុវជន និង កីឡា នៃព្រះរាជាណាចក្រកម្ពុជា ២០០២។

## ២.២. គុណសម្បត្តិគ្រូភាសាអង់គ្លេស

ដើម្បីឱ្យលទ្ធផលនៃការបង្រៀនភាសាអង់គ្លេសទទួលបានគុណភាពល្អ គ្រូបង្រៀនភាសាអង់គ្លេសនីមួយៗចាំបាច់ត្រូវមានលក្ខណៈសម្បត្តិដូចជា៖ ចិត្ត គរុកោសល្យ កម្រិតយល់ដឹងភាសាអង់គ្លេស វិធីសាស្ត្រនៃការបង្រៀន និងសម្ភារបង្រៀនជាដើម។ ភារៈកិច្ចចម្បងរបស់វិធីសាស្ត្រគឺ ជាការបង្កើនដំណើរការនៃការបង្រៀនភាសាអង់គ្លេសដោយការពង្រឹងឥទ្ធិពល និងគ្រូបង្រៀនធ្វើយ៉ាងណាឱ្យក្លាយជាអ្នកសម្របសម្រួលស្ទាត់ជំនាញ។ ការបង្រៀនេះផ្សារភ្ជាប់ទៅនឹងការវិភាគជាបន្តបន្ទាប់អំពីខ្លួនឯង ទទួលយកបទពិសោធន៍របស់គ្រូដទៃ និងស្វែងរកមធ្យោបាយថ្មីៗ ដើម្បីលើកកម្ពស់ការបង្រៀន។ នៅពេលបង្រៀនគ្រូត្រូវគិតពីគុណសម្បត្តិជាក់លាក់មួយដែលត្រូវផ្តល់ឱ្យទៅសិស្ស។ នោះមានន័យថា វិធីសាស្ត្រនៃការបង្រៀនភាសាអង់គ្លេស ត្រូវពិចារណាលើបញ្ហាដែលបង្កឡើងដោយភាសាអង់គ្លេសសម្រាប់សិស្សដែលត្រូវរៀនវា (Elena Taralunga TAMURA, vol.48 No.3, 2006)។ គ្រូល្អ ត្រូវមានចំណេះដឹង លក្ខណៈពិសេសផ្ទាល់ខ្លួនដាច់ដោយឡែក និងជំនាញវិជ្ជាជីវៈ

(Burton, 2000)។ គ្រូបង្រៀនម្នាក់ដែលទទួលបានជោគជ័យក៏ត្រូវមានចំណេះដឹងយ៉ាងជ្រៅជ្រះ ជំនាញលើឯកទេសខ្ពស់ និងមានបុគ្គលិកលក្ខណៈដាច់ដោយឡែក (Cheng Lying & Andy Curtis)។ បើយោងទៅតាមគំនិតខាងលើទាំងអស់នេះ គេអាចនិយាយបានថា គុណសម្បត្តិរបស់គ្រូបង្រៀនល្អ គួរត្រូវបានចែកជាបីប្រភេទធំៗគឺ៖ ចំណេះដឹង ជំនាញវិជ្ជាជីវៈ និង វិធីសាស្ត្របង្រៀន។

## ២.២.១. ចំណេះដឹងវិជ្ជាជីវៈគ្រូបង្រៀនភាសាអង់គ្លេស

ចំណេះដឹងភាសាអង់គ្លេសរបស់គ្រូបង្រៀនភាសាអង់គ្លេស នៅក្នុងប្រទេសកម្ពុជាភាគច្រើនមានកម្រិតមធ្យម និងមិនមានសមត្ថភាពខ្ពស់ក្នុងការផ្ទេរចំណេះដឹងទៅឱ្យសិស្សនៅឡើយ។ ដូច្នេះពួកគាត់ចាំបាច់ត្រូវទទួលការបណ្តុះបណ្តាលបន្ថែម ដើម្បីពង្រឹងសមត្ថភាព ពីព្រោះប្រសិនបើពួកគាត់មានសមត្ថភាព ពួកគាត់នឹងមានភាពជឿជាក់ក្នុងការបង្រៀនប្រកបទៅដោយប្រសិទ្ធភាព (Mao, 2013) ។ តាមការសិក្សាទៅលើគ្រូម្នាក់នៅសាកលវិទ្យាល័យ ណានជីង ប្រទេសចិន រកឃើញថាគ្រូបង្រៀនដែលទទួលបានជោគជ័យគឺត្រូវមានចំណេះដឹងសម្បូរបែបដូចជា ចំណេះដឹងទូទៅ ការស្វែងយល់ពីវប្បធម៌នានា សមត្ថភាពទំនាក់ទំនង ចំណេះដឹងខាងវិធីសាស្ត្របង្រៀន និងជាមនុស្សដែលចូលចិត្តទទួលយកអ្វីដែលថ្មីៗ។ លើសពីនេះពួកគាត់ត្រូវមានសមត្ថភាពជួយសិស្សឱ្យចេះយកវិធីត្រឹមត្រូវ និងមានប្រសិទ្ធភាពសម្រាប់ការរៀនភាសាអង់គ្លេស ព្រមទាំងបង្កើតឱកាសដើម្បីឱ្យសិស្សបានអនុវត្តភាសាអង់គ្លេសរបស់ពួកគេ (Huang, 2010)។ ដើម្បីឱ្យលទ្ធផលសិក្សារបស់សិស្សប្រសើរឡើង ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនគឺជាកត្តាចាំបាច់បំផុត ពោលគឺធ្វើយ៉ាងណាត្រូវលើកកម្ពស់ចំណេះដឹង និងជំនាញ ព្រមទាំងវិធីសាស្ត្របង្រៀនរបស់គ្រូ។ ការអភិវឌ្ឍវិជ្ជាជីវៈ អាចបម្រើឱ្យគោលបំណងជាច្រើនដូចជា ការជួយកែលម្អនូវចំណុចខ្វះខាតទាំងជំនាញ និងចំណេះដឹងរបស់គ្រូថ្មី ព្រមទាំងធ្វើបច្ចុប្បន្នភាពចំណេះដឹងរបស់គ្រូដែលកំពុងបង្រៀន (Yoon, K. S., Duncan, T., Lee, S. W.-Y., Scarloss,B., &Shapley, K, 2007)។

ការសិក្សាមួយនៅប្រទេសហូឡង់ក៏បានឱ្យនិយមន័យថា គ្រូបង្រៀនដែលល្អគឺជាអ្នកបង្ហាត់បង្ហាញដ៏មានសមត្ថភាព (Beishuizen, 2001)។ នៅក្នុងការសិក្សាមួយផ្សេងទៀតធ្វើឡើងដោយ Gi-Piyo Park & Hyo-Woong Lee, (2006) នៅប្រទេសកូរ៉េទៅលើសិស្ស និងគ្រូ

មុខវិជ្ជាភាសាអង់គ្លេស នៅក្នុងវិទ្យាល័យមួយតាមរយៈការឱ្យពួកគេបំពេញនូវកម្រងសំណួរ ដោយបានបញ្ចូលពចំណុចចំពោះការបង្រៀនមានប្រសិទ្ធភាព ដូចជា៖ ចំណេះដឹងភាសាអង់គ្លេស គរុកោសល្យ និងជំនាញដែលពាក់ព័ន្ធនឹងសង្គម។ ជាលទ្ធផលរវាងសិស្សនិងគ្រូបានឱ្យតម្លៃទៅលើប្រសិទ្ធភាពនៃការបង្រៀនផ្សេងគ្នា ដោយគ្រូគិតថាចំណេះដឹងភាសាអង់គ្លេសសំខាន់។ ចំណែកឯសិស្សគិតថាចំណេះដឹងគរុគោសល្យរបស់គ្រូសំខាន់ជាង។ យោងតាម Ethel និង McMeniman គ្រូបង្រៀនដែលទទួលបានជោគជ័យត្រូវមានចំណេះដឹងមូលដ្ឋានទូលំទូលាយដើម្បីប្រើប្រាស់នៅក្នុងការបង្រៀនឱ្យទទួលបានលទ្ធផលល្អ។ ជាងនេះទៅទៀត គ្រូបង្រៀនចាំបាច់ត្រូវមានចំណេះដឹងឯកទេស ចំណេះដឹងគរុកោសល្យខ្ពង់ខ្ពស់ផងដែរ (Ethel, R. G. & McMeniman, M. M., 2000)។ Mosha បានធ្វើការសិក្សាដោយប្រៀបធៀបសាលាពីរនៅក្នុងទីក្រុង បង្រៀនដោយគ្រូមានកម្រិតវប្បធម៌ខ្ពស់ ជាមួយនឹងសាលាពីរទៀតនៅតាមជនបទដែលមិនមានគ្រូភាសាអង់គ្លេសគ្រប់គ្រាន់។ ជាលទ្ធផលគេសង្កេតឃើញថា ការសិក្សារបស់សិស្សនៅក្នុងតំបន់ទាំងពីរមានលក្ខណៈខ្សោយដូចគ្នា។ នេះបញ្ជាក់ឱ្យឃើញថា គ្រូមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្រៀនមុខវិជ្ជារបស់ខ្លួនឡើយ បើទោះបីជាពួកគាត់បានទទួលការបណ្តុះបណ្តាលក៏ដោយ។ លើសពីនេះទៅទៀត សមត្ថភាពរបស់គ្រូគឺជាកត្តាចម្បងដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស។ ជាការពិត សិស្សភាគច្រើននៅតាមជនបទទទួលបានលទ្ធផលនៃការសិក្សាភាសាអង់គ្លេសទាប ដោយសារនៅទីនោះគ្រូភាគច្រើនសមត្ថភាពនៅមានកម្រិត និងមិនបានទទួលការបណ្តុះបណ្តាលបានគ្រប់គ្រាន់។ ដូច្នេះ ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស គ្រូភាសាអង់គ្លេសទាំងអស់គួរទទួលបានការបណ្តុះបណ្តាលបំប៉នបន្ថែមនៅក្នុងប្រព័ន្ធជាចាំបាច់ផងដែរ (Mosha, 2014)។ គ្រូដែលមានសមត្ថភាពទាំងអស់ត្រូវចេះច្បាស់ពីមុខវិជ្ជាដែលខ្លួនបង្រៀន។ គាត់ត្រូវដឹងថាវិធីសាស្ត្រណាមួយដែលគាត់គួរប្រើសម្រាប់បង្រៀនមុខវិជ្ជានីមួយៗ និងឆ្លើយតបទៅនឹងការចង់បានរបស់កម្មវិធីសិក្សាព្រមទាំងរបៀបរៀនរបស់សិស្ស (Vic Zbar, Graham Marshall, Paul Power, 2007)។

## ២.២.២. វិធីសាស្ត្របង្រៀនភាសាអង់គ្លេស

គោលដៅធំបំផុតនៃការបង្រៀន និងរៀនគឺ ធ្វើឱ្យអ្នកសិក្សាទទួលបានលទ្ធផលល្អ ហើយដើម្បីសម្រេចគោលបំណងនេះការបង្រៀន និងរៀនត្រូវពឹងផ្អែកជាចម្បងទៅលើវិធីសាស្ត្របង្រៀន។ បើគ្រូប្រើវិធីសាស្ត្របានសមស្របនោះការបង្រៀននិងរៀនទទួលបានលទ្ធផលល្អ។ យើងដឹងហើយថាពុំមានវិធីសាស្ត្រណាល្អបំផុតដាច់គេនោះទេពោលគឺវិធីសាស្ត្រណាក៏មានចំណុចល្អរបស់វាដែរ។ អ្វីដែលសំខាន់ត្រង់ថា អ្នកប្រើប្រាស់ត្រូវចេះច្នៃប្រឌិតយកមកប្រើប្រាស់ឱ្យបានសមស្របនឹងពេលវេលា និងកាលៈទេសៈរបស់ខ្លួន ជាពិសេសគប្បីយកចិត្តទុកដាក់ទៅលើវិធីសាស្ត្រដែលទំនើបមានលក្ខណៈបច្ចុប្បន្នភាព និងប្រសិទ្ធភាព (ចៅ លិន, ២០១១)។ Elena Taralunga TAMURA(2006) បានលើកឡើងថា វិធីសាស្ត្របង្រៀនភាសាអង់គ្លេស តែងតែមានទំនាក់ទំនងទៅនឹងបញ្ហាប្រឈមចំនួនបីគឺ៖(១) តើត្រូវបង្រៀនអ្វី? មានន័យថា មានចំនួននៃចំណេះដឹង ជំនាញ និងទម្លាប់ ដែលសិស្សចាំបាច់ត្រូវតែមានក្នុងដំណើរការរៀនភាសា។ (២) តើវត្ថុបំណងនៃការបង្រៀននេះជាអ្វី? នៅពេលដែលគ្រូប្រាកដច្បាស់ពីវត្ថុបំណងនៃការបង្រៀនរបស់ពួកគាត់ គាត់នឹងមានភាពងាយស្រួលក្នុងការដើរទៅដល់គោលដៅ។ (៣) តើបង្រៀនដោយវិធីណា? មានន័យថា គ្រូត្រូវជ្រើសរើសវិធីសាស្ត្រ ម៉ូដែល តិចនិច ណាមួយដើម្បីឱ្យសម្រេចបានតម្រូវការបញ្ចប់ចុងក្រោយ។

ចំពោះការបង្រៀនភាសាអង់គ្លេស គ្រូត្រូវផ្សាភ្ជាប់ទៅនឹងទ្រឹស្តី និងវិធីសាស្ត្រផ្សេងៗគ្នាជាច្រើនដើម្បីឱ្យការបង្រៀនរបស់ខ្លួនទទួលបានលទ្ធផលល្អ។ ក្នុងនោះវិធីសាស្ត្រដែលមានវ័យចំណាស់ជាងគេគឺវិធីសាស្ត្របកប្រែវេយ្យាករណ៍។ Celce-Murcia (2001) បានលើកឡើងថាវិធីសាស្ត្រនេះគ្រូប្រើភាសាកំណើត ឬបកប្រែពីភាសាកំណើតទៅជាភាសាអង់គ្លេសវិញ។ ប៉ុន្តែដោយមើលឃើញពីភាពបរាជ័យនៃវិធីសាស្ត្រខាងលើដែលមិនអាចឱ្យសិស្សទំនាក់ទំនងគ្នាបានដោយប្រើភាសាអង់គ្លេស ទើបក្រោយមកមានការបង្កើតនូវវិធីសាស្ត្រមួយទៀតដែលមានឈ្មោះថាវិធីសាស្ត្រផ្ទាល់ ដែលមិនអនុញ្ញាតឱ្យសិស្សប្រើប្រាស់ភាសាកំណើតឡើយ។ នៅក្នុងវិធីសាស្ត្រនេះ ការបង្រៀនវេយ្យាករណ៍តាមបែបអនុមានរួម និងបើកទូលាយឱ្យសិស្សអានច្រើនជាលក្ខណៈកម្សាន្ត ប៉ុន្តែវាផ្តោតសំខាន់ធ្វើយ៉ាងណាឱ្យសិស្ស

និយាយភាសាអង់គ្លេសបានស្ទាត់ជំនាញដូចជនជាតិដើម (Celce-Murcia, 2001)។ មួយវិញទៀតវិធីសាស្ត្រនេះបានលើកទឹកចិត្តឱ្យសិស្សស្វែងរកក្បួនវេយ្យាករណ៍ដោយខ្លួនឯង តាមរយៈការធ្វើសកម្មភាពក្នុងថ្នាក់ ឬការធ្វើលំហាត់ (Stern, 2001)។

(Richards, J., & Rodgers, T., 2001) បានលើកឡើងនៅវិធីសាស្ត្រមួយចំនួនដូចជា៖ ១ វិធីសាស្ត្របែបទំនាក់ទំនង ជាវិធីសាស្ត្រដែលបង្រៀនឱ្យសិស្សអភិវឌ្ឍសមត្ថភាពទំនាក់ទំនងដោយប្រើភាសាទីពីរ។ ២ វិធីសាស្ត្ររៀនតាមបែបសហការណ៍ ជាវិធីសាស្ត្រដែលសិស្សធ្វើការប្រាស្រ័យទាក់ទង និងសហការណ៍តាមរយៈការសន្ទនា។ ៣ វិធីសាស្ត្រការបង្រៀនដោយផ្អែកលើខ្លឹមសារ សិស្សមានឱកាសរៀននូវប្រធានបទ និងសកម្មភាពផ្សេងៗគ្នាជាច្រើន។ លើសពីនេះទៅទៀត Celce-Murcia (2001) ក៏បានបន្ថែមវិធីសាស្ត្រមួយទៀតគឺវិធីសាស្ត្របែបយល់ដឹងដែលដូចនឹងវិធីសាស្ត្រមួយចំនួនដែរ ដែលវេយ្យាករណ៍ត្រូវបានបង្រៀនតាមបែបអនុមាណរួម។ ជាទូទៅសិស្សជាអ្នកទទួលខុសត្រូវលើការរៀនរបស់ខ្លួន ហើយគ្រូជាមនុស្សមានចំណេះដឹងភាសាគ្រប់គ្រាន់សម្រាប់បង្រៀន។

រីឯលោក Mao (2013) បានលើកឡើងស្រដៀងគ្នានេះដែរថា គ្រូបង្រៀនភាសាអង់គ្លេសភាគច្រើននៅកម្ពុជាមិនទាន់សូវច្បាស់ ពីនិន្នាការនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មីៗមួយចំនួនមានដូចជា វិធីសាស្ត្របង្រៀន និងរៀន តាមបែបទំនាក់ទំនង វិធីសាស្ត្ររៀនដោយឈរលើមូលដ្ឋានការងារ វិធីសាស្ត្រការរៀនដោយឈរលើមូលដ្ឋានជាគម្រោង វិធីសាស្ត្រនៃការរៀនបែបសហការណ៍ជាដើម។ គ្រូភាសាអង់គ្លេសភាគច្រើនមិនអាចអនុវត្តវិធីសាស្ត្រទាំងនេះបានដោយជោគជ័យឡើយ ដូច្នេះពួកគាត់ភាគច្រើនជ្រើសយកវិធីសាស្ត្រនៃការបកប្រែវេយ្យាករណ៍ដើម្បីបង្រៀនសិស្ស ដែលជាហេតុនាំឱ្យលទ្ធផលនៃការសិក្សារបស់សិស្សមិនគួរជាទីពេញចិត្ត។ លើសពីនេះទៀត ការប្រើប្រាស់វិធីសាស្ត្រនេះក៏ធ្វើឱ្យសិស្សក្លាយជាសិស្សមិនសូវសកម្មក្នុងការរៀនសូត្រនិងពឹងផ្អែកការរៀនរបស់គេទៅលើគ្រូ និងមិនព្យាយាមសិក្សាស្រាវជ្រាវពង្រីកចំណេះដឹងបន្ថែមដោយខ្លួនឯងទេ។ សរុបមក មិនថាវិធីសាស្ត្រមួយណាដែលគ្រូគួរជ្រើសរើសយកមកប្រើដើម្បីបង្រៀននោះទេ ប៉ុន្តែត្រូវធានាថាបានជួយឱ្យការបង្រៀន និងរៀនមានគុណភាពពីព្រោះពុំមានវិធីសាស្ត្រមួយណាល្អជាងមួយណានោះទេ អ្វីដែលសំខាន់គ្រូត្រូវចេះប្រើវាប្រកបទៅដោយភាពច្នៃប្រឌិត។

## ២.៣. សម្ភារបង្រៀនភាសាអង់គ្លេស

គ្រូបង្រៀនគួរតែជ្រើសរើសសម្ភារៈសមស្របសម្រាប់បង្រៀន និង រៀបចំផែនការសម្រាប់ដំណើរការសកម្មភាពក្នុងថ្នាក់ដែលអាចឱ្យសិស្សចូលរួមបានគ្រប់គ្នា។ ដោយសារសិស្សនៅប្រទេសចិនមិនមានឱកាសគ្រប់គ្រាន់ ក្នុងការប្រើប្រាស់ភាសាអង់គ្លេសក្នុងជីវភាពប្រចាំថ្ងៃឡើយ ដូច្នេះគ្រូភាសាអង់គ្លេសត្រូវតែរៀបចំសម្ភារ និងសកម្មភាពនានាដើម្បីជួយសិស្សឱ្យអនុវត្តភាសាអង់គ្លេសបានកាន់តែច្រើនតាមដែលអាចធ្វើទៅបាន (Huang, 2010)។ តាមលោក ចៅ លិន(2011) បានលើកឡើងថាសម្ភារឧបទេសជាមធ្យោបាយ និងជាលក្ខខណ្ឌចាំបាច់សម្រាប់ដំណើរការក្នុងការបង្រៀន និងរៀនដោយប្រសិទ្ធភាព និងគុណភាព។ ដូច្នេះ សម្ភារឧបទេសគឺជាធនធានទាំងឡាយ ដែលគ្រូនិងសិស្សយកមកប្រើប្រាស់សម្រាប់ការបង្រៀន និងរៀនដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែជាក់លាក់ច្បាស់លាស់ ងាយយល់ ងាយចាប់បាន ដែលអាចសម្រេចនូវវត្ថុបំណងមេរៀន។ សម្ភារត្រូវមានទាំងគ្រូទាំងសិស្ស ហើយសម្ភារឧបទេសមានលក្ខណៈទូលំទូលាយ និងច្រើនប្រភេទណាស់។ ការប្រើប្រាស់សម្ភារឧបទេសបានជួយដល់សកម្មភាពបង្រៀន និងរៀនជាច្រើនដូចជា៖ ធ្វើឱ្យសិស្សបានចូលរួមការសិក្សាប្រកបដោយភាពរីករាយ ធ្វើឱ្យថ្នាក់រៀនមានភាពរស់រវើក ធ្វើឱ្យសិស្សចាប់យកមេរៀនថ្មីងាយស្រួល ធ្វើឱ្យសិស្សចងចាំមេរៀនបានយូរ និងចំណេញពេលវេលាបង្រៀន។ សម្ភារឧបទេសមានច្រើនបែប ច្រើនប្រភេទ និង ច្រើនសណ្ឋាន។ ដូច្នេះ ដើម្បីងាយស្រួលដល់ការប្រើប្រាស់ ការស្វែងរកនិងផលិត យើងអាចចែកវាជាបីប្រភេទគឺ៖ សម្ភារធនធានបរិស្ថាន សម្ភារអេឡិចត្រូនិច និងសម្ភារច្នៃប្រឌិត។

Mary Atanas Mosha (2014) ក៏បានលើកឡើងដែរថាការខ្វះសម្ភារបង្រៀនជាពិសេសសៀវភៅសិក្សាគោលក៏ជាកត្តាជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃការរៀន និងបង្រៀនផងដែរ ។ ជាការពិតណាស់គ្រូភាគច្រើនមានការលំបាកក្នុងការទទួលបានសម្ភារបង្រៀន ដែលបានណែនាំនៅក្នុងកម្មវិធីសិក្សា ហើយម៉្យាងពួកគាត់មិនសូវមានចំណាប់អារម្មណ៍ក្នុងការផលិតសម្ភារទាំងនោះដែលនាំឱ្យរាំងស្ទះដល់ដំណើរការនិងប្រសិទ្ធភាពនៃការបង្រៀនដែលនាំឱ្យលទ្ធផលសិក្សារបស់សិស្សមុខវិជ្ជាភាសាអង់គ្លេសទាប។ Hayes (2014) បានលើកឡើងថា សម្ភារបង្រៀនគួរតែរៀបចំឡើងឱ្យឆ្លើយតបទៅនឹងតម្រូវការថ្នាក់រៀន និងសិស្សរបស់ខ្លួន

ផ្ទាល់។ សម្ភារទាំងអស់គួរបង្កើតឡើងដោយផ្អែកលើវត្ថុបំណងមេរៀន ជាពិសេសគឺលើកកម្ពស់ដល់សកម្មភាពចូលរួមរបស់សិស្ស ដែលអាចផ្តល់ឱកាសឱ្យពួកគេបានអនុវត្តភាសាអង់គ្លេសក្នុងថ្នាក់រៀន។

នៅក្នុងការបង្រៀនភាសាអង់គ្លេស គ្រូបង្រៀនអាចប្រើប្រាស់សម្ភារឧបទេសសម្រាប់ជាជំនួយដល់ការបង្រៀនដូចជា៖ ម៉ាញ៉េ មាស៊ីនចាក់ស៊ីឌី ម៉ាស៊ីនចាក់វីឌីអូ រូបភាព និងវត្ថុពិតជាដើម។ គ្រូគួរតែជ្រើសរើស និងប្រើប្រាស់ សម្ភារទាំងអស់នោះដោយផ្អែកទៅលើវត្ថុបំណងមេរៀន (Spatt, M, Pulvemess, A., & Williams, M., 2005)។ ក្តារខៀនជាឧបករណ៍ដ៏សំខាន់មួយដែលមិនអាចខ្វះបាននៅក្នុងថ្នាក់រៀន ។ ប៉ុន្តែគ្រូបង្រៀនគួរតែប្រើប្រាស់វាដោយយកចិត្តទុកដាក់ថែរក្សាឱ្យបានល្អ (Grower, et al., 2005)។ ក្រៅពីនេះ ពួកគេក៏បានលើកឡើងដែរថា សៀវភៅសិក្សាគោល និងសៀវភៅផ្សេងទៀតក៏ជាសម្ភារៈឧបទេសយ៉ាងសំខាន់សម្រាប់ដំណើរការបង្រៀនផងដែរ (Grower, R, Phillips, D., & Walters, S., 2005)។ កុំព្យូទ័រក៏ជាសម្ភារសំខាន់ក្នុងថ្នាក់ដែរ ដោយសារសព្វថ្ងៃនេះជាមួយបច្ចេកវិទ្យាដែលគេតែងតែប្រើប្រាស់បណ្តាញអ៊ីនធើណែតសម្រាប់ធ្វើការទំនាក់ទំនងតាមរយៈអ៊ីម៉ែល និងប្រព័ន្ធបណ្តាញសង្គមផ្សេងទៀត។ ថ្មីៗនេះបណ្តាញទាំងនេះអាចប្រើប្រាស់នៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស ដូចជាការប្រើដើម្បីផលិតសម្ភារឧទេសជាដើម (Celce-Murcia, 2001)។

សម្ភារឧបទេសសម្រាប់ការបង្រៀន ដើរតួនាទីសំខាន់ណាស់ក្នុងការលើកកម្ពស់ដល់ការប្រើភាសាទំនាក់ទំនងរបស់សិស្ស។ សម្ភារឧបទេសសម្រាប់ការបង្រៀនចែកចេញជាបីគឺ សម្ភារឧបទេសជាអត្ថបទ កិច្ចការ និងវត្ថុពិត។ សម្ភារទាំងអស់នោះអាចជា សៀវភៅពុម្ពការលេងល្បែង ការដើរតួ និងសកម្មភាពផ្សេងទៀតដែលគាំទ្រដល់ការបង្រៀន (Richards, 2001)។ ការប្រើសម្ភារបង្រៀនមានឥទ្ធិពលលើសកម្មភាពបង្រៀនភាសាបរទេស។ Abebe និង Davidson (2011) បានលើកឡើងថា សិស្សអាចរៀនពាក្យថ្មីមួយលឿនដោយសារគ្រូបានប្រើប្រាស់សម្ភារៈដែលមើលឃើញ ដែលជំរុញឱ្យសិស្សមានសមត្ថភាពនិងឱកាសក្នុងការបង្ហាញពីគំនិតនិងអារម្មណ៍របស់ពួកគេ (Abebe, T. T. & Davidson, L. M., 2011)។ ប៉ុន្តែនៅឆ្នាំ២០១២លោកបានរកឃើញថា គ្រូកម្រប្រើប្រាស់សម្ភារឧបទេសដែល

មើលឃើញដូចជា កាតតារាង និងវត្ថុពិតនៅក្នុងការបង្រៀនរបស់ខ្លួនណាស់ បើទោះបីជាគ្រូបង្រៀន និងសិស្សភាគច្រើនទទួលស្គាល់ថាការប្រើប្រាស់សម្ភារឧបទេសជួយសិស្សឱ្យរៀនភាសាទទួលបានប្រសិទ្ធភាពខ្ពស់ក៏ដោយ។ ចំណែក (Mathew, N. G., & Alidmat, A. O. H., 2013) បានទទួលស្គាល់ថាការប្រើប្រាស់សម្ភារសោតទស្សន៍ក្នុងការបង្រៀនភាសាអង់គ្លេស ជួយឱ្យសិស្សមានការរីកចម្រើនទៅលើជំនាញបញ្ចេញសំឡេង និងជំនាញសន្ទនាតាមរយៈការស្តាប់ជនជាតិដើម។ មួយវិញទៀត ការប្រើសម្ភារៈទាំងនេះថែមទាំងជួយឱ្យសកម្មភាពនៅក្នុងថ្នាក់កាន់តែគួរឱ្យចាប់អារម្មណ៍ និងធ្វើឱ្យសិស្សចាំមេរៀនបានយូរជាងមុន។

## ២.៤. កម្មវិធីសិក្សាភាសាអង់គ្លេស

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា(២០១៥) បានលើកឡើងថា គុណភាពនៃការអប់រំរងឥទ្ធពលពីកត្តាជាច្រើន ជាពិសេសកម្មវិធីសិក្សាដែលរួមបញ្ចូលទាំងឯកសារពាក់ព័ន្ធ ក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត សៀវភៅគ្រូ សៀវភៅសិស្ស សៀវភៅអនុវត្តសម្ភារឧបទេស និងសៀវភៅណែនាំស្តីពីការវាយតម្លៃសមត្ថភាពសិស្ស។ការរៀបចំកម្មវិធីសិក្សាមួយគិតឱ្យបានល្អិតល្អន់ទៅលើមុខវិជ្ជា និងកម្រិតថ្នាក់ពីមួយកម្រិតទៅមួយកម្រិតទៀត ដើម្បីធានាប្រសិទ្ធភាពការរៀននិងបង្រៀន និងភាពពាក់ព័ន្ធគ្នានៃចំណេះដឹងសម្រាប់ការរស់នៅប្រចាំថ្ងៃ។ ខ្លឹមសារមេរៀននីមួយៗត្រូវតែមានភាពប្រទាក់ក្រឡាគ្នា ព្រមទាំងមានភាពរលូនទៅតាមការបែងចែកនៃការអភិវឌ្ឍកម្មវិធីសិក្សាតាមលក្ខណៈវិទ្យាសាស្ត្រដែលកំណត់ច្បាស់លាស់អំពីវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ដែលសិស្សនឹងត្រូវទទួលបានក្រោយពេលរៀនចប់មេរៀន កម្រិតថ្នាក់ និងកម្រិតសិក្សានីមួយៗ។ ឯកសារដដែល ក៏បានបន្តទៀតថា ការអភិវឌ្ឍកម្មវិធីសិក្សាភាសាបរទេស (អង់គ្លេស ឬ បារាំង) ត្រូវតែឆ្លើយតបនឹងការផ្លាស់ប្តូរសង្គម និងការជឿនលឿនផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាក្នុងតំបន់ និងលើសកលលោក ពីព្រោះភាសាបរទេសមានសារប្រយោជន៍យ៉ាងទូលំទូលាយក្នុងការសិក្សា ការទទួលបានការងារធ្វើ និងការរស់នៅប្រចាំថ្ងៃ។ ក្នុងនោះការកំណត់វត្ថុបំណង ត្រូវបានធានាឱ្យសិស្សមានសមត្ថភាពទំនាក់ទំនងនៅក្នុង

បំណិនទាំងបួន (ការស្ដាប់ ការនិយាយ ការអាន និងការសរសេរ) ព្រមទាំងឱ្យសិស្សក្លាយជាអ្នករៀនពេញមួយជីវិតប្រកបដោយការច្នៃប្រឌិតនិងការជឿជាក់ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា, ២០១៥)។

ខ្លឹមសារកម្មវិធីសិក្សាដែលល្អសំខាន់គឺត្រូវធ្វើយ៉ាងណាជួយឱ្យលទ្ធផលការសិក្សារបស់សិស្សបានល្អ ប៉ុន្តែខ្លឹមសារនេះត្រូវបានបំពេញបន្ថែម និងគាំទ្រដោយការអនុវត្តប្រកបដោយប្រសិទ្ធភាព។ កម្មវិធីសិក្សាដែលល្អ មិនមែនត្រឹមតែបង្ហាញពីអ្វីដែលគ្រូគួរបង្រៀនតាមមុខវិជ្ជានិងកម្រិតថ្នាក់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រាប់អំពីការបង្រៀន និងវាយតម្លៃ (Stabback, 2016)។កម្មវិធីសិក្សាក្នុងពេលបច្ចុប្បន្ន គួរធ្វើយ៉ាងណាឱ្យមានភាពស៊ីជម្រៅប្រសើរជាជាងការធ្វើឱ្យមានភាពទូលំទូលាយពេក ពោលគឺក្នុងកម្មវិធីសិក្សាត្រូវក្ដោបទៅលើចំណុចសំខាន់ៗនិងធ្វើយ៉ាងណាឱ្យមានភាពត្រឹមត្រូវស្របតាមក្បួនកំណត់ និងស្របតាមបរិបទរបស់សង្គមបច្ចុប្បន្នព្រោះវាជាបញ្ចាចម្បងនៃការអប់រំ។ ម្យ៉ាងវិញទៀត កម្មវិធីសិក្សាត្រូវបញ្ចូលនូវបំណិនសម្រាប់ដោះស្រាយបញ្ហានានា ឬបញ្ចូលនូវចំណេះដឹងផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងសង្គមនោះ។ កម្មវិធីសិក្សាគួរដាក់ឱ្យសិស្សរៀនពីលក្ខណៈដោយឡែកៗរបស់មនុស្ស និងធ្វើយ៉ាងណាឱ្យគេចេះធ្វើការទំនាក់ទំនងគ្នាដោយភាតរភាព(Glatthor, A. & Jailall, J, 2000)។

សៀវភៅសិក្សាគោលជាធាតុដ៏សំខាន់នៃកម្មវិធីសិក្សា ហើយត្រូវបានចាត់ទុកជាឧបករណ៍ដ៏សំខាន់បំផុតនៅក្នុងការបង្រៀននិងរៀន។ ដូចនេះ ខ្លឹមសារនៅក្នុងសៀវភៅសិក្សាគួរតែមានលក្ខណៈសមស្របទៅតាមកម្រិតសមត្ថភាព និងចំណេះដឹងរបស់សិស្ស។

ការសិក្សារបស់ Igawa (2008) បានរកឃើញថាៈ ខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលគួរតែធ្វើឱ្យមានការចាប់អារម្មណ៍ និងសមស្របសម្រាប់សិស្សគ្រប់កម្រិតសិក្សារបស់សិស្ស ហើយត្រូវផ្សារភ្ជាប់ជីវិតប្រចាំថ្ងៃក្នុងបរិបទប្រទេសកម្ពុជាផងដែរ។ លើសពីនេះទៀត សៀវភៅសិក្សាគោលរបស់ក្រសួងអប់រំយុវជន និងកីឡា ហាក់មានអត្ថបទអានច្រើនជាងសកម្មភាពផ្សេងៗ។ កម្មវិធីសិក្សាភាសាអង់គ្លេសនៅប្រទេសកម្ពុជា ត្រូវបានឆ្លងកាត់ការកែលម្អជាច្រើនដំណាក់កាល ដោយចាប់ផ្ដើមដាក់ឱ្យសិស្សរៀនជាផ្លូវការនៅឆ្នាំ១៩៨៩ ប៉ុន្តែការអប់រំភាសាអង់គ្លេសនាពេលនោះមានភាពខ្វះខាតច្រើន។ យោងតាមការសិក្សារបស់ Mao (2015) ការ

អប់រំភាសាអង់គ្លេសនៅពេលនោះមិនទាន់មានកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការបណ្តុះបណ្តាលគ្រូច្បាស់លាស់ទេ។ ប៉ុន្តែដោយមានការខិតខំប្រឹងប្រែងជាបន្តបន្ទាប់ពីអ្នកពាក់ព័ន្ធ ជាពិសេសក្រសួងអប់រំយុវជន និងកីឡា ការអប់រំភាសាអង់គ្លេសសម្រេចបាននូវវឌ្ឍនភាពជាបន្តបន្ទាប់។ ជាក់ស្តែងនៅឆ្នាំ២០១៦ សៀវភៅសិក្សាគោលភាសាអង់គ្លេសមួយមានចំណងជើងថា៖ "The Cambodia English Course" ត្រូវបានចងក្រងនឹងបោះពុម្ពឱ្យប្រើប្រាស់សម្រាប់ថ្នាក់ទី៧ នៅក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ។ កម្មវិធីសិក្សាភាសាអង់គ្លេសលម្អិតសម្រាប់មធ្យមសិក្សា ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីសម្រួលបន្ថែមលើវិធីសាស្ត្រ និងការរៀបចំកិច្ចតែងការបង្រៀនរបស់គ្រូ (ក្រសួងអប់រំយុវជន និងកីឡា ១៩៩៦ និង ង.ឧ ហាង់ ជូនណារ៉ុន ២០១៦)។

ផ្អែកលើឯកសារខាងលើភាសាអង់គ្លេសត្រូវបានដាក់ឱ្យបង្រៀនចំនួន ៣៦ សប្តាហ៍ក្នុងមួយឆ្នាំសិក្សាដែលក្នុងមួយសប្តាហ៍ត្រូវបង្រៀន៥ម៉ោង សម្រាប់មធ្យមសិក្សាបឋមភូមិ។ ក្រោយមកទៀតកម្មវិធីសិក្សាលម្អិត មុខវិជ្ជាភាសាអង់គ្លេសស្រដៀងគ្នាត្រូវបានរៀបចំសម្រាប់ថ្នាក់ទី១០ ទី១១ និងទី១២ ប៉ុន្តែម៉ោងសិក្សាសម្រាប់ភាសាអង់គ្លេសបានយកមកត្រឹមតែ ៤ ម៉ោងវិញ (យោងទៅតាមសេចក្តីណែនាំស្តីពីការបង្រៀនភាសាបរទេសនៅមធ្យមសិក្សាលេខ ២៩៨៨ អយក. សណន ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ១៩៩៩)។ ក្រោយមកទៀត ដោយមានជំនួយពីដៃគូអភិវឌ្ឍនានា ក្រសួងអប់រំ យុវជន និងកីឡា បានបន្តរៀបចំកម្មវិធីសិក្សាភាសាអង់គ្លេស និងសៀវភៅសិក្សាគោលគ្រប់កម្រិត។ ជាលទ្ធផល សៀវភៅសិក្សាគោលមានចំណងជើងថា៖ "English For Cambodia" ចំនួន ប្រាំមួយកម្រិតសម្រាប់ថ្នាក់ទី ៧ ដល់ថ្នាក់ទី ១២ ត្រូវបានបោះពុម្ព និងដាក់ឱ្យប្រើប្រាស់ជាបន្តបន្ទាប់( ណារ៉ុន ហ., ២០១៦)។

នៅក្នុងឆ្នាំ២០០៤ កម្មវិធីសិក្សានៅក្នុងប្រព័ន្ធអប់រំនៅកម្ពុជាត្រូវបានកែលម្អដោយក្រសួងអប់រំ យុវជន និងកីឡា ។ ក្នុងនោះកម្មវិធីសិក្សាភាសាបរទេស(អង់គ្លេស និងភាសាបារាំង) ត្រូវបានដាក់ឱ្យសិស្សរៀនចាប់ពីថ្នាក់ទី៥ នៅកម្រិតបឋមសិក្សា ប៉ុន្តែមុខវិជ្ជានេះត្រូវបានដាក់ឱ្យសិក្សានៅក្នុងបំណិនជីវិតតាមមូលដ្ឋាន។ ចាប់ពីថ្នាក់ទី៧ ឡើងទៅមុខវិជ្ជាភាសាបរទេសត្រូវបានដាក់ក្នុងកម្មវិធីសិក្សាជាតិជាមុខវិជ្ជាចាំបាច់ដែលសិស្សត្រូវសិក្សាចំនួន ៤ម៉ោងក្នុងមួយសប្តាហ៍។ ប៉ុន្តែក្រោយមកទៀត របាយម៉ោងសិក្សាភាសាបទេសមានការផ្លាស់ប្តូរនៅ

កម្រិតមធ្យមសិក្សាទុតិយភូមិ។ យោងតាមសេចក្តីណែនាំលេខ ២៣ អយក. សណន ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការអនុវត្តកម្មវិធីសិក្សាចំណោះទូទៅថ្នាក់ទី១១ និងថ្នាក់ទី១២ ចំនួនម៉ោងសិក្សាភាសាបរទេសត្រូវបានកាត់បន្ថយនៅសល់ត្រឹមតែ ០២ម៉ោងក្នុងមួយសប្តាហ៍ ទាំងថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់វិទ្យាសាស្ត្រសង្គម ។

ដើម្បីបន្តអភិវឌ្ឍ និងពង្រឹងកម្មវិធីសិក្សាភាសាអង់គ្លេស ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំ និងដាក់ឱ្យប្រើនូវកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសចំនួនពីរនៅឆ្នាំ ២០១២ ដែលទី១ គឺកម្មវិធីសិក្សាលម្អិតសម្រាប់បឋមសិក្សាថ្នាក់ទី៤ ទី៥ និងថ្នាក់ទី៦ និងលើកទី២គឺកម្មវិធីសិក្សាលម្អិតសម្រាប់ថ្នាក់ទី៧ ទី៨ និងទី៩(អយក, ២០១២)។ តាមរយៈជំនួយពីអង្គការគីហ្សូណា សៀវភៅសិក្សាគោលភាសាអង់គ្លេសថ្មីដែលមានចំណងជើងថា៖ "English Grade" ត្រូវបានផលិតឡើងដែលក្នុងនោះសៀវភៅ "English Grade 4 & 5" ផលិតនៅឆ្នាំ២០១៣ និង "English Grade 6 & 7" នៅឆ្នាំ២០១៥។ ចំណែកសៀវភៅ English grade 8 & 9" ក៏ត្រូវបានផលិតនៅឆ្នាំបន្តបន្ទាប់ ។ យោងតាមសេចក្តីណែនាំលេខ៤៧ អយក. សណន ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ សៀវភៅ "English Grade7" "English Grade 8" English Grade 9" ត្រូវបានដាក់ឱ្យប្រើប្រាស់ជាសៀវភៅសិក្សាគោលសម្រាប់មធ្យមសិក្សាបឋមភូមិ ដែលក្នុងនោះមានទាំងសៀវភៅសិស្ស សៀវភៅណែនាំគ្រូ និងខ្សែអាត់សំឡេង។ ដោយឡែកសៀវភៅសិក្សាគោលភាសាអង់គ្លេសថ្មី សម្រាប់ថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២ មិនទាន់បានផលិតចេញនៅឡើយទេ ដូច្នេះ សម្រាប់កម្រិតថ្នាក់ទាំងនោះនៅតែអនុវត្តតាមសៀវភៅសិក្សាគោលចាស់ដដែលគឺ សៀវភៅ "English For Cambodia"។

## ២.៥. ការលើកទឹកចិត្ត

ការលើកទឹកចិត្តត្រូវបានគេចាត់ទុកថា ជាកត្តាដ៏ចម្បងមួយដែលជះឥទ្ធិពលដល់ល្បឿន និងកម្រិតនៃការសិក្សាភាសាបទេសរបស់សិស្ស (Gardner, 2006) ។ ជាឧទាហរណ៍ Gardner (2006) បានលើកឡើងថា សិស្សដែលមានកម្រិតនៃការលើកទឹកចិត្តខ្ពស់តែងតែធ្វើបានល្អជាងសិស្សដែលមានកម្រិតការលើកទឹកចិត្តទាបជាង។ ប្រសិនបើសិស្សមានការលើកទឹកចិត្តពួកគេមានហេតុផលគ្រប់គ្រាន់ ក្នុងការចូលរួមរាល់សកម្មភាពទាំងអស់។ (Elliot, S., Kratochil, T,. & Cook, J., 2000) មើលឃើញថាការលើទឹកចិត្តជាសភាពលក្ខណៈ

ខាងក្នុងដែលជំរុញឱ្យយើងធ្វើសកម្មភាព ដើម្បីឆ្ពោះទៅរកគោលដៅដែលខ្លួនចង់បាន និងជំរុញឱ្យយើងព្យាយាមស្វែងរកចំណេះដឹង និងជំនាញថ្មីៗ។ ចំណែក (Petty, 1998) យល់ឃើញថា ប្រសិនបើសិស្សមិនចង់រៀន ប្រសិទ្ធភាពនៃការសិក្សារបស់ពួកគេប្រាកដជាយឺត ឬក៏គ្មានទទួលបានលទ្ធផលអ្វីទាំងអស់។ ដូច្នេះបើគ្រូបង្រៀនដឹងពីវិធីនៃការលើកទឹកចិត្តសិស្ស គ្រូអាចជួយបង្កើនការសិក្សារបស់សិស្សឱ្យប្រសើរជាងមុន។

ការលើកទឹកចិត្តគឺជាការគិតនិងអារម្មណ៍ដែលអាចជំរុញឱ្យយើងបន្តធ្វើអ្វីមួយ ហើយប្រែក្លាយការគិតទាំងនោះទៅជាសកម្មភាព។ ចំណែកការលើកទឹកចិត្តក្នុងការរៀនភាសាអង់គ្លេសកាន់តែសំខាន់ ប៉ុន្តែវាអាចប្រែប្រួលទៅតាមអាយុ ពេលវេលា ទីកន្លែង និងសូម្បីតែការរៀនជាមួយគ្រូផ្សេងគ្នា។ មានកត្តាជាច្រើនដែលជះឥទ្ធិពលនិងជំរុញលើកទឹកចិត្តឱ្យសិស្សចង់រៀនភាសាអង់គ្លេសដូចជា៖ ការយល់ពីសារសំខាន់នៃការរៀនភាសាអង់គ្លេសការចាប់អារម្មណ៍ពីវប្បធម៌របស់ប្រទេសដែលប្រើប្រាស់ភាសាដែលសិស្សចង់រៀន និងការគាំទ្រពីមនុស្សដទៃទៀតជុំវិញខ្លួន ។ គ្រូចាំបាច់ត្រូវជួយសិស្សដើម្បីបង្កើតឱ្យមានកម្លាំងជំរុញទឹកចិត្តនិងថេរក្សាវា(Spatt, M, Pulvemess, A., & Williams, M., 2005)។

(Stern, 2001) ដែលបានសិក្សាពីអាកប្បកិរិយារបស់មនុស្សបានបញ្ជាក់ថា ឥរិយាបថចំពោះប្រទេស ក្រុម និងភាសាបានជួយយើងយល់ថាហេតុអ្វីបានជាមនុស្សមួយចំនួនមានកម្លាំងចិត្តក្នុងការរៀនភាសាជាមួយអ្នកដទៃ។ បន្ទាប់ពីការធ្វើអង្កេតថ្នាក់រៀនមួយ អ្នកស្រាវជ្រាវបានជោគជ័យក្នុងការសិក្សា ។ (Shalaway, 2005) លើកឡើងថាការរៀបចំមេរៀនសម្រាប់បង្រៀនដោយផ្អែកលើចំណាប់អារម្មណ៍របស់សិស្សតែមួយមុខ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ គ្រូបង្រៀនចាំបាច់ត្រូវតែជួយ ជំរុញសិស្សឱ្យយល់ពីតម្លៃនៃការទទួលបាននូវជំនាញប្រើប្រាស់ភាសានោះថែមទៀត។ អ្នកសិក្សាជាច្រើនបានបែងចែកការជំរុញទឹកចិត្តជាពីរប្រភេទ៖ ខាងក្នុង និង ខាងក្រៅ និងបានឱ្យនិយមន័យចំពោះការជំរុញទឹកចិត្តខាងក្នុងថាជាការធ្វើអ្វីមួយដោយសារការចូលចិត្តរបស់បុគ្គលនោះផ្ទាល់តែម្តង។ រីឯការជំរុញទឹកចិត្តខាងក្រៅថាកើតឡើងនៅពេលដែលមានកម្លាំងជំរុញពីខាងក្រៅអាចជាសម្ភារ ឬដើម្បីសម្រេចគោលដៅណាមួយ។ ជាទូទៅសិស្សដែលមានកម្លាំងជំរុញខាងក្នុង ច្រើនទទួលបាន

លទ្ធផលនៃការសិក្សាខ្ពស់ជាងសិស្សដែលមានតែកម្លាំងជំរុញពីខាងក្រៅ (Ryan, M, R. & Deci, E, L., 2000)។

## ២.៦. ការរៀបចំមេរៀន ឬកិច្ចតែងការបង្រៀន

មានការលើកឡើងផ្សេងគ្នាចំពោះការរៀបចំមេរៀន និងការធ្វើកិច្ចតែងការ។ Spatt, M, Pulvemess, A., & Williams, M.(2005) បានលើកឡើងថា ការធ្វើកិច្ចតែងការគឺជាការកត់ចំណាំដែលជួយគ្រូបានគិតទុកជាមុននូវវត្ថុបំណងមេរៀន ដំណើរការបង្រៀននិងរបៀបដែលគ្រូត្រូវបង្រៀនមេរៀនមួយ និង ជាផ្លូវសម្រាប់ជួយគ្រូបានរៀបចំនូវសម្ភារៈសម្រាប់ជួយសិស្សក្នុងការធ្វើសកម្មភាព។ នៅក្នុងថ្នាក់រៀនភាសាអង់គ្លេសមួយ ដើម្បីឱ្យសកម្មភាពសិក្សារបស់សិស្សទទួលបានលទ្ធផលល្អ ពួកគេត្រូវការអនុវត្តសកម្មភាពជាច្រើន ដូច្នេះនៅពេលធ្វើកិច្ចតែងការបង្រៀនគ្រូ ត្រូវតែដាក់បញ្ចូលសកម្មភាពឱ្យបានច្រើន សម្រាប់សិស្សអនុវត្ត (Woodward, 2001)។ Celce-Murcia (2001) និយាយថាកិច្ចតែងការបង្រៀនដែលល្អគឺត្រូវទាមទារឱ្យសកម្មភាពទាំងអស់មានទំនាក់ទំនងគ្នា ផ្សេងៗពីគ្នា និងមានភាពបត់បែន។ គ្រូបង្រៀនភាសាអង់គ្លេសត្រូវតែយល់និងដឹងពីគោលការណ៍នៃការបង្រៀននិងរៀនភាសាអង់គ្លេសព្រមទាំងតម្រូវការរបស់សិស្ស និងស្ថាប័នរបស់ខ្លួន។ គ្រូបង្រៀនត្រូវចាំទុកក្នុងចិត្តជានិច្ចនូវវត្ថុបំណងមេរៀននៅពេលរៀបចំសកម្មភាពបង្រៀនមេរៀននីមួយៗ។

## ២.៧. បរិមាណសិស្សក្នុងថ្នាក់

Blatchford (2003) បានពន្យល់ថាមានយុទ្ធសាស្ត្រជាច្រើនសម្រាប់លើកកម្ពស់ស្តង់ដាអប់រំ។ អ្នកសិក្សារូបនេះក៏បានពន្យល់បន្ថែមទៀតថា ថ្នាក់តូចអាចនាំឱ្យគុណភាពការរៀននិងបង្រៀនប្រសើរឡើង។ នៅពេលដែលគាត់បានចុះទៅអង្កេតនៅថ្នាក់រៀនមួយដែលមានសិស្ស១៥នាក់ឃើញថា ស្ថានភាពទូទៅនៅក្នុងថ្នាក់រៀននោះគឺវិជ្ជមាន ដោយគ្រូតែងតែនិយាយលេងសើចជាមួយសិស្ស និងមានការទំនាក់ទំនងផ្ទាល់ខ្លួនជាច្រើន។ ក្រៅពីនេះអ្នកស្រាវជ្រាវក៏ចុះទៅអង្កេតថ្នាក់រៀនធំផ្សេងទៀតដែលមានសិស្សចំនួន៣០នាក់ ហើយបានរកឃើញថារវាងថ្នាក់ទាំងពីរមានសភាពខុសគ្នាគួរឱ្យកត់សម្គាល់។ នៅក្នុងថ្នាក់តូចគ្រូបានចំណាយពេលតិចតួចនៅក្នុងការគ្រប់គ្រងថ្នាក់រៀន ប៉ុន្តែនៅក្នុងថ្នាក់ធំគ្រូព្យាយាមចំណាយពេលជាច្រើនដើម្បីទាញចំណាប់អារម្មណ៍សិស្សលើការងារដែលគ្រូដាក់។

ម៉្យាងទៀតនៅក្នុងថ្នាក់តូចគ្រូស្គាល់សិស្សម្នាក់ៗច្បាស់ ដែលអាចឱ្យគ្រូជួយសិស្សក្នុងការសិក្សាបានងាយស្រួល (Blatchford, 2003)។ Hong Thi Nguyen, Wendy Warren & Heather Fehring, (2014) បានធ្វើការសិក្សាមួយទៀតគឺ បានធ្វើការអង្កេតថ្នាក់មួយចំនួននៅក្នុងសាលា HUTECH ក្នុងប្រទេសវៀតណាម ដែលក្នុងនោះថ្នាក់រៀនភាគច្រើនមានសិស្សច្រើនចាប់ពី៤០ នាក់ ដល់ទៅ៥០ នាក់។ ជាលទ្ធផលរកឃើញថាក្នុងថ្នាក់រៀនដែលមានសិស្សតិចគឺ ការសិក្សារបស់សិស្សទទួលបានលទ្ធផលជាង ពីព្រោះនៅក្នុងថ្នាក់រៀនតូចគ្រូងាយស្រួលគ្រប់គ្រងរាល់សកម្មភាពទាំងឡាយដែលគ្រូដាក់ឱ្យសិស្សអនុវត្ត និងធ្វើ។

# ជំពូក ៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. ការប្រមូលទិន្នន័យ

ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងនៃការសិក្សាស្រាវជ្រាវ និងសំណួរស្រាវជ្រាវខាងលើ វិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័យត្រូវបានជ្រើសរើសយកមកប្រើប្រាស់ក្នុងការប្រមូលទិន្នន័យពីអ្នកដែលពាក់ព័ន្ធនានា។ មុននឹងប្រមូលទិន្នន័យទាំងនេះ កម្រងសំណួរចំនួន៣ប្រភេទត្រូវបានបង្កើតឡើង សម្រាប់អ្នកចូលរួមចំនួនបីប្រភេទផ្សេងគ្នាឆ្លើយរួមមាន នាយក នាយករងសាលា គ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី ៧ ៨ និង ៩ និងសិស្សានុសិស្ស។ កម្រងសំណួរទាំងនេះត្រូវបានបង្កើតឡើងតាមរយៈការអាន និងពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើឯកសារគោលនានាដូចជាៈ ឯកសារកម្មវិធីសិក្សាភាសាបរទេស លិខិតនិងសេចក្ដីណែនាំរបស់ក្រសួង សៀវភៅសិក្សាគោល ព្រមទាំងឯកសារពាក់ព័ន្ធនានា បានមកពីការសិក្សាស្រាវជ្រាវដែលមានស្រាប់ទាំងក្នុងស្រុកនិងក្រៅប្រទេសមួយចំនួននៅក្នុងតំបន់ និងសកលលោក។

## ៣.២. ទីតាំងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវសម្រេចជ្រើសរើសយកវិទ្យាល័យ គិត ម៉េង ប្រាសាទ ដែលស្ថិតនៅក្នុងភូមិ ក្រាំងប្រទាល ឃុំ ដូង ស្រុក បាទី ខេត្តតាកែវ សម្រាប់ធ្វើការសិក្សាស្រាវជ្រាវជាករណីសិក្សាឱ្យបានស៊ីជម្រៅ និងច្បាស់លាស់។ ឆ្នាំសិក្សា ២០១៩-២០២០ នេះ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ វិទ្យាល័យ គិត ម៉េង ប្រាសាទ មានសិស្សថ្នាក់ទី៧ ចំនួន ២៤៥ នាក់ ស្រី ១៣០ នាក់ ថ្នាក់ទី៨ ចំនួន ១៤៥ នាក់ ស្រី ៨០ នាក់ និង ថ្នាក់ទី៩ ចំនួន ១១៥ នាក់ ស្រី ៦០ នាក់ ។

មូលហេតុដែលអ្នកសិក្សាស្រាវជ្រាវ ជ្រើសរើសវិទ្យាល័យនេះសម្រាប់ធ្វើការស្រាវជ្រាវ ដោយសារអ្នកស្រាវជ្រាវជាគ្រូបង្រៀនកម្រិតឧត្តមកំពុងបម្រើការនៅសាលានេះ ហើយអ្នកស្រាវជ្រាវបានធ្វើតេស្តសិស្សថ្នាក់ទី ៩ ឡើងទី ១០ ជារៀងរាល់ឆ្នាំ ហើយសង្កេតឃើញថា ថា ចំណេះដឹងរបស់សិស្សនៅមានកម្រិត ។

## ៣.៣. ការជ្រើសរើសសំណាក

ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រក្នុងការជ្រើសរើសសំណាកតាមបែបគោលបំណងក្នុងការប្រមូលទិន្នន័យ ដោយដៅតែសំណាកណាដែលអ្នកស្រាវជ្រាវយល់ថា ភាគសំណាកនោះអាចផ្តល់នូវទិន្នន័យបានជាក់លាក់ ច្បាស់លាស់ និងអាចឆ្លើយតបទៅនឹងប្រធានបទនេះបាន។ ដូច្នេះធាតុសំណាកដែលអ្នកសិក្សាស្រាវជ្រាវយល់ថា អាចទទួលបានទិន្នន័យដែលអាចជឿទុកចិត្តបាននោះមានបីប្រភេទរួមមាន៖ លោកនាយក នាយករងសាលា ចំនួន ០២នាក់ គ្រូបង្រៀនភាសាអង់គ្លេសចំនួន ០៣នាក់ និងសិស្សានុសិស្សថ្នាក់ទី ៧ ដល់ទី៩ ចំនួន ២៥០នាក់។ ប្រភេទ ទី ១ ការសម្ភាសផ្ទាល់ និងឱ្យលោកនាយក នាយករងបំពេញកម្រងសំណួរបន្ថែម។ មូលហេតុដែលជ្រើសរើសនាយក នាយករងសាលាក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវនេះ ពីព្រោះតែនាយកសាលាក៏ជាអ្នកដែលអាចផ្តល់ព័ត៌មានទូទៅស្តីពីការបង្រៀន ការរៀន របស់លោកគ្រូអ្នកគ្រូ និងសិស្ស ជាពិសេសនាយកគឺជាអ្នកធ្វើអធិការកិច្ចផ្ទាល់នៅសាលាក្នុងការតាមដានការអនុវត្តការងារប្រចាំថ្ងៃរបស់លោកគ្រូ អ្នកគ្រូ។ ប្រភេទទី២ គឺ គ្រូបង្រៀនភាសាអង់គ្លេស ត្រូវបានសុំធ្វើការសម្ភាស និងសុំឱ្យបំពេញកម្រងសំណួរ ពីព្រោះពួកគាត់ជាអ្នកបង្រៀនភាសាអង់គ្លេសផ្ទាល់ ច្បាស់ណាស់ពួកគាត់ប្រាកដជាផ្តល់ព័តិបានល្អប្រសើរ។ ប្រភេទទី៣ គឺ ការជ្រើសរើសយកសិស្សចំនួន ២៥០នាក់ មកធ្វើជាសំណាកព្រោះតែពួកគេជាអ្នកសិក្សាមុខវិជ្ជាភាសាអង់គ្លេស ជាមួយគ្រូភាសាអង់គ្លេសរបស់ពួកគេផ្ទាល់។ ហេតុដូច្នេះពួកគេប្រាកដជាអាចផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងប្រធានបទបានគ្រប់ជ្រុងជ្រោយ សម្រាប់ឱ្យអ្នកសិក្សាស្រាវជ្រាវយកមកធ្វើការវិភាគ ។

## ៣.៤. ឧបករណ៍ស្រាវជ្រាវ

ដើម្បីប្រមូលទិន្នន័យបានជាក់លាក់ អ្នកសិក្សាស្រាវជ្រាវបានបង្កើតទម្រង់សំណួរស្រាវជ្រាវចំនួន៣ ដើម្បីឆ្លើយតបនឹងវត្ថុបំណងនៃការស្រាវជ្រាវរួមមាន៖ ទី១ ទម្រង់សំណួរសម្រាប់គ្រូបង្រៀនភាសាអង់គ្លេស ទី២គឺ ទម្រង់សំណួរសម្រាប់សិស្ស និងទី ៣ គឺទម្រង់សំណួរសម្រាប់សម្ភាសនិងឱ្យនាយកបំពេញ។

ទម្រង់សំណួរទី១៖ ទម្រង់សំណួរសម្រាប់គ្រូ អ្នកសិក្សាស្រាវជ្រាវបានរៀបចំជា៨ផ្នែក៖

ផ្នែកទី(១) អំពីព័ត៌មានទូទៅរបស់គ្រូ ចែកចេញជា៣ចំណុចគឺ (១)ឈ្មោះ ក្រុង/ស្រុក (២)ឈ្មោះសាលា (៣) ភេទ ។ ផ្នែកទី(២) គុណវឌ្ឍិគ្រូបង្រៀនភាសាអង់គ្លេស ដែលបែងចែកចេញជា ៧ចំណុចគឺ (១) ក្របខណ្ឌរបស់គ្រូបង្រៀន (២) កម្រិតសញ្ញាបត្រចុងក្រោយរបស់គ្រូបង្រៀន (៣) សមត្ថភាពគ្រូខ្ពស់ជួយដល់ការបង្រៀន (៤)បទពិសោធន៍បង្រៀន (៥) ការចូលរួមវគ្គបណ្តុះបណ្តាល (៦)គុណប្រយោជន៍នៃការចូលរួមវគ្គបណ្តុះបណ្តាល (៧) ការជ្រើសរើសវគ្គបំប៉ន ។ ផ្នែកទី(៣) កម្មវិធីសិក្សា ត្រូវបានបែងចែកជា ៤ចំណុចគឺ (១) បំណែងចែកកម្មវិធីប្រចាំឆ្នាំ (២) សារប្រយោជន៍នៃបំណែងចែកកម្មវិធីសិក្សា (៣) ខ្លឹមសារសៀវភៅសិក្សាគោល (៤) ចំនួនម៉ោងបង្រៀន។ ផ្នែកទី(៤) សម្ភារទ្រទ្រង់ការបង្រៀន បែងចែកជា ២គឺ (១) ស្ថានភាព និងកម្រិតប្រើប្រាស់សម្ភារៈ (២) សារប្រយោជន៍នៃសម្ភារឧបទេស។ ផ្នែកទី(៥) សកម្មភាពរៀនរបស់សិស្សក្នុងថ្នាក់ ត្រូវបានចែកជា ៣ចំណុចគឺ (១) កម្រិតនៃការឱ្យសិស្សធ្វើការម្នាក់ឯង ដៃគូ ក្រុម និង ធ្វើការរួមគ្នា (២) ការដាក់ការងារឱ្យសិស្សធ្វើនៅផ្ទះ (៣) ការលើកទឹកចិត្តសិស្ស។ ផ្នែកទី(៦) ការរៀបចំមេរៀនបង្រៀន ត្រូវបានចែកចេញជា ១ ចំណុចគឺ (១) ការរៀបចំធ្វើកិច្ចតែងការបង្រៀន។ ផ្នែកទី(៧) បរិមាណសិស្សក្នុងថ្នាក់ ត្រូវបានបែងចែកជា ២ ចំណុច (១) ចំនួនសិស្សក្នុងថ្នាក់នីមួយៗ (២) កត្តាជះឥទ្ធិពលអវិជ្ជមានចំពោះថ្នាក់រៀនដែលមានសិស្សច្រើន។ ផ្នែកទី(៨) ស្ថានភាពសិក្សារបស់សិស្សមាន ៤ចំណុចគឺ (១) ការមករៀនទៀងទាត់ និងទាន់ពេលវេលា (២) ការយកចិត្តទុកដាក់ស្តាប់គ្រូក្នុងម៉ោងសិក្សា (៣) ការចូលរួមធ្វើសកម្មភាពសិក្សាក្នុងថ្នាក់ (៤) ការធ្វើកិច្ចការផ្ទះដែលគ្រូដាក់ឱ្យ។

ទម្រង់សំណួរទី២៖ ទម្រង់សំណួរសម្រាប់សិស្ស អ្នកសិក្សាស្រាវជ្រាវរៀបចំជា៨ផ្នែក៖ ផ្នែកទី(១) ព័ត៌មានទូទៅរបស់សិស្ស ចែកចេញជា៣ចំណុចគឺ (១)ឈ្មោះក្រុង/ស្រុក (២) ឈ្មោះសាលារៀន (៣) ភេទ។ ផ្នែកទី(២) គុណវឌ្ឍិគ្រូបង្រៀនភាសាអង់គ្លេស ដែលបែងចែកចេញជា ៣ចំណុចគឺ (១)កម្រិតចំណេះដឹងលើមុខវិជ្ជា (២) សមត្ថភាពខ្ពស់របស់គ្រូជួយសិស្សឆាប់យល់មេរៀន (៣) គុណភាពនៃការបង្រៀនរបស់គ្រូ។ ។ ផ្នែកទី(៣) កម្មវិធីសិក្សា ត្រូវបានបែងចែកជា ៤ចំណុចគឺ (១) ខ្លឹមសារសៀវភៅសិក្សាគោល (២) កម្រិតខ្លឹមសារសៀវភៅសិក្សាគោលធៀបនឹងសមត្ថភាពសិស្ស (៣) ចំនួនម៉ោងដែលសិស្សត្រូវរៀន។ ផ្នែកទី(៤) សម្ភារទ្រទ្រង់ការបង្រៀន បែងចែកជា ២គឺ (១) កម្រិតនៃការប្រើប្រាស់សម្ភារឧបទេសក្នុង

ការរៀន (២) សារប្រយោជន៍នៃការប្រើប្រាស់សម្ភារឧបទេសក្នុងការរៀន។ ផ្នែកទី(៥) សកម្មភាពរៀនរបស់សិស្សក្នុងថ្នាក់ ត្រូវបានចែកជា ៣ចំណុចគឺ (១) កម្រិតនៃការឱ្យសិស្សធ្វើការម្នាក់ឯង ដៃគូ ក្រុម និង ធ្វើការរួមគ្នា (២) ការលើកទឹកចិត្តពីសំណាក់គ្រូក្នុងពេលបង្រៀន (៣) ការដាក់ការងារឱ្យសិស្សធ្វើនៅផ្ទះ។ ផ្នែកទី(៦) បរិមាណសិស្សក្នុងថ្នាក់ ត្រូវបានបែងចែកជា ២ ចំណុច (១) ចំនួនសិស្សក្នុងថ្នាក់នីមួយៗ (២) កត្តាជះឥទ្ធិពលអវិជ្ជមានចំពោះថ្នាក់រៀនដែលមានសិស្សច្រើន។ ផ្នែកទី(៧) ស្ថានភាពសិក្សារបស់សិស្សមាន ៤ចំណុចគឺ (១) ការមករៀនទៀងទាត់ និងទាន់ពេលវេលា (២) ការយកចិត្តទុកដាក់ស្តាប់គ្រូក្នុងម៉ោងសិក្សា (៣) ការចូលរួមធ្វើសកម្មភាពសិក្សាក្នុងថ្នាក់ (៤) ការធ្វើកិច្ចការផ្ទះដែលគ្រូដាក់ឱ្យ។

ទម្រង់សំណួរទី៣៖ កម្រងសំណួរសម្រាប់សម្ភាសនាយក ឬនាយិកាសាលា។ នៅក្នុងកម្រងសំណួរនេះអ្នកសិក្សាស្រាវជ្រាវបានរៀបចំជា ៦ ផ្នែក។ ផ្នែកទី(១) ជំនាញឯកទេស ក្របខណ្ឌគរុកោសល្យ និងសមត្ថភាពក្នុងការបង្រៀនរបស់គ្រូ។ ផ្នែកទី(២) ការចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លី ឬសិក្ខាសាលារយៈពេល ៥ឆ្នាំចុងក្រោយ។ ផ្នែកទី(៣) ការអនុវត្តរបស់គ្រូបង្រៀនទាក់ទងទៅនឹងការមកបំពេញការងារបានទៀងទាត់ ការរៀបចំកិច្ចតែងការបង្រៀន និងការយកចិត្តទុកដាក់លើការសិក្សារបស់សិស្ស ពីសំណាក់គ្រូបង្រៀន។ ផ្នែកទី(៤) ទាក់ទងទៅនឹងប្រភេទសម្ភារជំនួយដល់ការបង្រៀន និងរៀនភាសាអង់គ្លេសដែលសាលាមាន និងកម្រិតនៃការប្រើប្រាស់សម្ភារៈដែលមានពីសំណាក់លោកគ្រូ អ្នកគ្រូ។

## ៣.៥. ដំណាក់កាលនៃការប្រមូលទិន្នន័យ

ក្រោយពីទទួលបានការណែនាំ និងឯកភាពពីគ្រូណែនាំ ព្រមទាំងទទួលបានលិខិតឧទ្ទេសនាមពីវិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា លេខ : ១១៩ វជអ.ផក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៩ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី ៦ នៃវិទ្យាស្ថានជាតិអប់រំ ឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅតាមរាជធានី ខេត្តនានា។ និងលិខិតជូនដំណឹងពីក្រសួងអប់រំ យុវជន និងកីឡា លេខ: ១៨៨៥ អយក.វជអ ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០១៨ ស្តីពីការស្នើទៅនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយមជ្ឈិម ប្រធានមន្ទីរអប់រំយុវជន និងកីឡារាជធានី-ខេត្ត សុំ

ជួយសម្រួលដល់ការចុះស្រាវជ្រាវប្រមូលទិន្នន័យ នៅតាមរាជធានី ខេត្តនានា។ បន្ទាប់ពីទទួលបានការយល់ព្រមពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ស្តីពីការសម្រួលដល់ការចុះសិក្សាស្រាវជ្រាវនៅសាលាគោលដៅ អ្នកសិក្សាស្រាវជ្រាវបានរៀបចំផែនការដោយធ្វើការទំនាក់ទំនងទៅសាលាគោលដៅដោយផ្ទាល់។ មូលហេតុគឺដើម្បីជួបពិភាក្សាជាមួយនាយកសាលាដើម្បីកំណត់កាលបរិច្ឆេទក្នុងការណាត់ជួបសម្ភាសនាយកសាលា លោកគ្រូ អ្នកគ្រូដែលបង្រៀនភាសាអង់គ្លេស និងសិស្ស ក្នុងការបំពេញកម្រងសំណួរដែលត្រៀមទុកជាមុនធ្វើយ៉ាងណាមិនឱ្យប៉ះពាល់ដល់ការបង្រៀនរបស់គ្រូ និងការរៀនរបស់សិស្ស។ ដំណើរការទាំងមូលបានពិភាក្សាជាមួយថ្នាក់ដឹកនាំសាលា អំពីគោលបំណង និងផែនការទាំងមូលនៃការសិក្សាស្រាវជ្រាវ ។ ក្រោយពីនាយកសាលាបានពិនិត្យលិខិតអនុញ្ញាតពីមន្ទីរអប់រំយុវជន និងកីឡាក្នុងកិច្ចការស្រាវជ្រាវនេះរួចហើយគាត់ក៏បានអនុញ្ញាតឱ្យរៀបចំការប្រមូលទិន្នន័យតាមផែនការដែលឯកភាពគ្នា តាមដំណាក់កាលនីមួយៗ។

មុនការចុះប្រមូលទិន្នន័យផ្លូវការ អ្នកសិក្សាស្រាវជ្រាវបានរៀបចំសាកល្បងលើកម្រងសំណួរទាំងអស់ជាមួយសិស្សចំនួន ៥ នាក់ ។ គោលបំណងនៃការសាកល្បងកម្រងសំណួរនេះគឺដើម្បីធានាអំពីប្រសិទ្ធភាព និងភាពពិតប្រាកដនៃកម្រងសំណួរថាតើអាចយកមកប្រមូលទិន្នន័យផ្លូវការបានដែរឬទេ។ ក្រោយពីការសាកល្បងលើកម្រងសំណួរទាំងនេះ អ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថា ការសាល្បងនេះពិតជាទទួលបានផលល្អមែន ព្រោះយើងរកឃើញចំណុចខ្វះខាតមួយចំនួនរបស់កម្រងសំណួរ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវក៏យកបញ្ហាទាំងនេះទៅពិភាក្សាជាមួយសាស្ត្រាចារ្យដឹកនាំ ដើម្បីទទួលបានយោបល់ត្រឡប់ក្នុងការកែលម្អ កម្រងសំណួរឡើងវិញ។ ក្រោយពីការណែនាំ កែលម្អ និងឯកភាពពីសាស្ត្រាចារ្យណែនាំរួចមក អ្នកសិក្សាស្រាវជ្រាវក៏ចាប់ផ្តើមចុះប្រមូលទិន្នន័យតែម្តង។

## ៣.៦. ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ទិន្នន័យបែបបរិមាណវិស័យដែលប្រមូលបានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាដំបូងត្រូវវិភាគដាច់ដោយឡែកទៅតាមប្រភេទសំណាកនីមួយៗ ( គ្រូបង្រៀន និងសិស្ស)។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវសំយោគបញ្ចូលគ្នាដោយ

ផ្តោតសំខាន់ទៅលើគុណវឌ្ឍិគ្រូបង្រៀន ភាសាអង់គ្លេស កម្មវិធីសិក្សា សម្ភារទ្រទ្រង់ការបង្រៀន និងរៀន វិធីសាស្ត្របង្រៀន ការរៀបចំមេរៀនបង្រៀន បរិមាណសិស្សក្នុងថ្នាក់ និងស្ថានភាពការសិក្សារបស់សិស្ស។ ដើម្បីឆ្លើយតបនឹងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីកម្មវិធី SPSS សម្រាប់ស្វែងរកចំនួនប្រេកង់គិតជាភាគរយ និង Microsoft Excel សម្រាប់សង់ក្រាប តារាង និងបកស្រាយព័ត៌មាន។ ការវិភាគបែបគុណវិស័យ ជាការប្រមូលផ្តុំគំនិតទស្សនៈការយល់ឃើញនានា របស់អ្នកផ្តល់បទសម្ភាសដោយចាប់បញ្ចូលនូវចំណុចដែលដូច ឬប្រហាក់ប្រហែលគ្នា ដើម្បីបន្ថែមព័ត៌មាន និងបង្ហាញគំនិតគាំទ្រចំពោះទិន្នន័យនៃការវិភាគតាមបែបបរិមាណវិស័យ ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវបានលើកជាសំណូមពរចំពោះចំណុចខ្វះខាត និងកែលម្អចំណុចខ្វះខាតទាំងនោះឱ្យបានប្រសើរឡើង។

## ៣.៧. ក្រមសីលធម៌នៃការស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវបានផ្តោតយកចិត្តទុកដាក់ពីបញ្ហាក្រមសីលធម៌ ពីព្រោះវាមានសារសំខាន់ណាស់ក្នុងការធានាប្រសិទ្ធភាព នៃការស្រាវជ្រាវក៏ដូចជាបង្កើននូវភាពទុកចិត្ត និងភាពជឿជាក់ដល់អ្នកចូលរួមផ្តល់ចម្លើយ ក៏ដូចជាទិន្នន័យផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងកិច្ចការស្រាវជ្រាវនេះផងដែរ។ មានការព្រមព្រាងគ្នារវាងអ្នកផ្តល់ចម្លើយ និងអ្នកដែលស្វែងរកប្រភពព័ត៌មានច្បាស់លាស់និងមានប្រសិទ្ធភាព ហើយអាចយកមកប្រើការបានសម្រាប់ធ្វើការវិភាគស៊ីជម្រៅ។ អត្តសញ្ញាណរបស់អ្នកផ្តល់ចម្លើយត្រូវបានរក្សាការសំខាត់ លើកលែងតែឈ្មោះសាលាដែលត្រូវបានបង្ហាញ ប៉ុន្តែក៏មានការឯកភាពពីនាយកសាលាគោលដៅនីមួយ អ្នកសិក្សាស្រាវជ្រាវបាននាំយកនូវលិខិតអនុញ្ញាតទៅជាមួយ ហើយសុំការអនុញ្ញាតពីភាគីពាក់ព័ន្ធ ដោយចាប់ផ្តើមមុនពេលពួកគាត់បំពេញកម្រងសំណួរ និងផ្តល់បទសម្ភាស។ ការធ្វើបែបនេះមានន័យថាអ្នកផ្តល់ចម្លើយយល់នូវគោលបំណង នៃការស្រាវជ្រាវជាមុន ហើយអ្នកស្រាវជ្រាវក៏រំពឹងផងដែរថានឹងទទួលបានចម្លើយ ឬព័ត៌មានដែលពិត។ ការធ្វើដូច្នេះ ធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវមានទំនុកចិត្ត និងមានភស្តុតាងបញ្ជាក់ពីការចុះទៅប្រមូលទិន្នន័យរបស់ខ្លួនដោយស្របច្បាប់។

# ជំពូក ៤

# លទ្ធផល និងការពិភាក្សា

# ជំពូកទី៤
# លទ្ធផល និងការពិភាក្សា

ក្នុងជំពូកទី ៤ នេះបង្ហាញអំពីពត៌មានទូទៅរបស់អ្នកចូលរួមទាំងអស់ដែលមាននាយកសាលា១ នាក់ (ប្រុស) នាយករង ១ នាក់ (ប្រុស) គ្រូភាសាអង់គ្លេសចំនួន ៣ នាក់ (ប្រុសទាំងអស់) និងសិស្សានុសិស្សចំនួន២៥០នាក់ដែលបានផ្តល់ទិន្នន័យរួមមាន ភេទនិងលទ្ធផលរបស់សំណួរស្រាវជ្រាវ។ តាមទិន្នន័យក្នុងតាងរាងទី១សិស្សទាំង២៥០ នាក់ បានឆ្លើយសំណួរដែលបានចែកជូនដែលមានប្រុសចំនួន១១៩នាក់ ស្មើនឹង៤៧.៦% និងស្រីចំនួន១៣១នាក់ស្មើនឹង៥២.៤%។

តារាងទី១៖ សិស្ស

| ភេទ | ចំនួន (នាក់) | ចំនួនភាគរយ |
|---|---|---|
| ប្រុស | 119 | 47.6% |
| ស្រី | 131 | 52.4% |
| សរុប | 250 | 100% |

១. តើស្ថានភាពនៃការបង្រៀន និងរៀនភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាបឋមភូមិ នៅវិទ្យាល័យ គិត ម៉េង ប្រាសាទ បច្ចុប្បន្នប្រព្រឹត្តទៅយ៉ាងដូចម្តេច?

តាមរយៈការសំភាសជាមួយនាយក នាយករង គ្រូបង្រៀនភាសាអង់គ្លេស និង ការបំពេញកម្រងសំណួររបស់សិស្ស អ្នកស្រាវជ្រាវអាចវាយតម្លៃបានថា ការបង្រៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិសក្សាបឋមភូមិ នៅវិទ្យាល័យ គិត ម៉េង ប្រាសាទ បច្ចុប្បន្នប្រព្រឹតទៅមានលក្ខណៈល្អបង្គួរ។

២. តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលខ្លាំងជាងគេដល់គុណភាពនៃការបង្រៀននិងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ នាពេលបច្ចុប្បន្ន?

កត្តាផ្សេងៗដែលជៈឥទ្ធិពលដល់គុណភាពនៃការបង្រៀន និង រៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិមាន៖

## ៤.១ ការយល់ឃើញរបស់នាយក (សម្ភាសន៍)

តាមរយៈការសម្ភាសបង្ហាញថា លោកនាយកបានបំពេញតួនាទីជានាយកតាំងពីឆ្នាំ ២០០២ រហូតមកដលពេលនេះគឺ ឆ្នាំ ២០១៩ ពោលគឺមានរយៈពេល ១៧ ឆ្នាំមកហើយ។ លោកនាយកមានក្របខណ្ឌជាគ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេស ជីវវិទ្យា-គីមីវិទ្យា ហើយ លោកបានបញ្ចប់បរិញ្ញាបត្រឯកទេស គ្រប់គ្រងអប់រំពីសាកលវិទ្យាល័យ ខេមរៈ សាខាខេត្ត តាកែវ ក្នុងឆ្នាំ ២០០៦។

កិច្ចសម្ភាសជាមួយលោកនាយករងបង្ហាញថា គាត់ជាគ្រូបង្រៀនកម្រិតឧត្តមឯកទេស ភូមិវិទ្យា។ គាត់បានបញ្ចប់បរិញ្ញាបត្រភូមិវិទ្យាពីសាកលវិទ្យាល័យ ភូមិមិន្ទភ្នំពេញ ក្នុងឆ្នាំ ១៩៩៨។ លោកនាយករងត្រូវបានក្រសួងអប់រំ យុវជន និងកីឡា តែងតាំងជានាយករងក្នុងឆ្នាំ ២០០៦ បន្តពីនាយករងចាស់ដែលចូលនិវត្តន៍។

ទាំងលោកនាយក និង លោកនាយយករងមានមតិស្រដៀងគ្នាថា៖

- ពួកគាត់ទាំងពីរធ្លាប់បានចូលរួមវគ្គបំប៉នរយៈពេលខ្លីទាក់ទងនឹងការគ្រប់គ្រងដែល មានរយៈពេលចាប់ពី ៣ ថ្ងៃដល់ ២ សប្តាហ៍។
- វិទ្យាល័យ គិត ម៉េង ប្រាសាទ មានគ្រូបង្រៀនភាសាអង់គ្លេសនៅកម្រិតមធ្យម សិក្សាបឋមភូមិចំនួន ៣ នាក់ ។
- គ្រូបង្រៀនភាសាអង់គ្លេសទាំងបីនាក់សុទ្ធតែមានសមត្ថភាពគ្រប់គ្រាន់ក្នុងការ បង្រៀនភាសាអង់គ្លេស។
- គ្រូបង្រៀនភាសាអង់គ្លេសម្នាក់បានទទួលការបណ្តុះបណ្តាលរយៈពេលខ្លី (សិក្ខា សាលា)ស្តីអំពីវិធីសាស្ត្របង្រៀនភាសាអង់គ្លេស រយៈពេលប្រាំឆ្នាំចុងក្រោយ។
- គ្រូបង្រៀនភាសាអង់គ្លេសបានមកបង្រៀនទៀងទាត់ និង ទាន់ពេលវេលា ។
- គ្រូបង្រៀនភាសាអង់គ្លេសពិតជាបានរៀបចំកិច្ចតែងការបង្រៀនមុនពេលបង្រៀន មេរៀននីមួយៗ ។
- គ្រូបង្រៀនភាសាអង់គ្លេសទាំងអស់ពិតជាបានពង្រឹងចំណេះដឹង និង ជំនាញរបស់ ខ្លួនតាមរយៈការរៀបចំសៀវភៅវេយ្យាករណ៍ភាសាអង់គ្លេស និង សៀវភៅអំណា នភាសាអង់គ្លេសជាដើម ។
- លោកនាយក និង នាយករង មានប្រសាសន៍ថា គ្រូបង្រៀនភាសាអង់គ្លេសបាន យកចិត្តទុកដាក់ក្នុងការសិក្សារបស់សិស្សព្រោះពួកគាត់បានកែកិច្ចការផ្ទះ ឱ្យ សិស្សបានជាទៀងទាត់។ (ការតាមដានរបស់ពួកគាត់)

- ➢ លោកនាយក និង នាយករង មានប្រសាសន៍ថា សៀវភៅសិក្សាគោលភាសាអង់គ្លេសថ្មី (English Grades and English is Funs) មានមិនទាន់គ្រប់គ្រាន់ទេ វាជាការលំបាកសម្រាប់សិស្ស ព្រោះសិស្សភាគច្រើនត្រូវប្រើសៀវភៅមួយក្បាលពីរនាក់ ។
- ➢ សាលាមានសម្ភារៈឧបទេសសម្រាប់ជួយដល់ដំណើរការបង្រៀនរបស់គ្រូ ដូចជា ស៊ីកយ៉រ ជាដើម តែវានៅមានបញ្ហាព្រោះសាលាមានតែមួយ។
- ➢ គ្រូបង្រៀននៅប្រើសម្ភារទាំងនេះនៅមានកម្រិតនៅឡើយដោយសារការខ្វះខាតពេលខ្លះគាត់ត្រូវអានអត្ថបទស្តាប់ជំនួសការចាក់ស៊ីកយ័រ។
- ➢ លោកនាយក និង លោកនាយករង សំណូមពរឱ្យក្រសួងអប់រំជួយផ្តល់សៀវសិក្សាឱ្យបានគ្រប់គ្រាន់ ស៊ីឌីសម្រាប់ចាក់សំឡេងភាសាអង់គ្លេស ឧបករណ៍សម្រាប់បញ្ចាំងស្លាយ និង ឧបករណ៍ផ្សេងៗទៀតទាក់ទងនឹងការបង្រៀនភាសាអង់គ្លេស។

## ៤.២ ការយល់ឃើញរបស់គ្រូ(សម្ភាសន៍)

តាមរយៈការសម្ភាស បង្ហាញថាគ្រូបង្រៀនភាសាអង់គ្លេសម្នាក់ជាគ្រូបង្រៀនកម្រិតឧត្តម ហើយបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឯកទេសបង្រៀនភាសាអង់គ្លេស ហើយត្រូវបានសុំឱ្យជួយបង្រៀនថ្នាក់ទី ៩ ដោយសារតែនៅកម្រិតមធ្យមសិក្សាបឋមភូមិខ្វះគ្រូភាសាអង់គ្លេស។ គ្រូបង្រៀនរូបនេះមានបទពិសោធន៍បង្រៀនភាសាអង់គ្លេសនៅសាលារដ្ឋរយៈពេល ៨ ឆ្នាំមកហើយ ហើយក៏ធ្លាប់ជាគ្រូបង្រៀនកម្រិតមូលដ្ឋានដែរ។ ចំណែកឯគ្រូបង្រៀនភាសាអង់គ្លេសពីរនាក់ទៀតជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ម្នាក់បានបញ្ចប់បរិញ្ញាបត្រភាសាអង់គ្លេស ចំណែកម្នាក់ទៀតកំពុងរៀនបន្តបរិញ្ញាបត្រ (វគ្គសៅរ៍ និង អាទិត្យ)។ លោកគ្រូទាំងពីរនាក់មានបទពិសោធន៍បង្រៀនភាសាអង់គ្លេសនៅសាលារដ្ឋអស់រយៈពេល ១០ និង១១ ឆ្នាំមកហើយ។ លោកគ្រូទាំងបីនាក់បានមានមតិយល់ឃើញពីការបង្រៀនភាសាអង់គ្លេសដូចតទៅៈ

### ៤.២.១ គុណវុឌ្ឍិគ្រូបង្រៀន

- លោកគ្រូពីរនាក់យល់ឃើញថា គ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ អាចជួយឱ្យសិស្សឆាប់ចេះបានកម្រិតខ្លាំង ចំណែកឯលោកគ្រូម្នាក់ទៀតយល់ឃើញថា គ្រូបង្រៀនដែលមានសម្ថភាពខ្ពស់ អាចជួយឱ្យសិស្សឆាប់ចេះបានកម្រិតមធ្យម។

- លោកគ្រូពីរនាក់បានឱ្យដឹងថា រយៈពេលប្រាំឆ្នាំចុងក្រោយនេះពួកគាត់មិនបានឆ្លងកាត់ការបណ្តុះបណ្តាលរយៈពេលខ្លី ឬ សិក្ខាសាលាទាក់ទងនិងគរុកោសល្យ ឬវិធីសាស្រ្តបង្រៀនភាសាអង់គ្លេសទេ។ ចំណែកលោកគ្រូម្នាក់ទៀតគាត់ថា គាត់បានចូលរួមវគ្គសិក្ខាសាលារយៈពេលខ្លី (២ ថ្ងៃ) ស្តីអំពីការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសថ្មីគឺ English Grades និង English is Funs នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ។
- លោកគ្រូម្នាក់គាត់មានប្រសាសន៍ថា ការចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លី ឬ សិក្ខាសាលាទាក់ទងនិងគរុកោសល្យ ឬវិធីសាស្រ្តបង្រៀនភាសាអង់គ្លេសមានប្រយោជន៍ខ្លាំងណាស់ដល់ការបង្រៀនភាសាអង់គ្លេស។ ចំណែកឯលោកគ្រូពីរនាក់ទៀតបានឱ្យដឹងថាការចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លី ឬ សិក្ខាសាលាទាក់ទងនិងគរុកោសល្យ ឬវិធីសាស្រ្តបង្រៀនភាសាអង់គ្លេសមានប្រយោជន៍ខ្លាំងដល់ការបង្រៀនភាសាអង់គ្លេស។
- លោកគ្រូពីរនាក់បានជ្រើសរើសយក វិធីសាស្រ្តបង្រៀន បច្ចេកវិទ្យាព័ត៌មាន (ICT) និង ការពង្រឹងចំណេះដឹងភាសាអង់គ្លេស ជាកត្តាចាំបាច់ក្នុងការបង្រៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ។ ចំណែកលោកគ្រូម្នាក់ទៀតបានជ្រើសរើសយក វិធីសាស្រ្តបង្រៀន បច្ចេកវិទ្យាព័ត៌មាន (ICT) និង ការផលិត និងប្រើប្រាស់សម្ភារឧបទេស។

### ៤.២.២ កម្មវិធីសិក្សា

- លោកគ្រូទាំងបីនាក់បានឱ្យដឹងថា ពួកគាត់សុទ្ធតែមានបំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេសប្រចាំឆ្នាំសម្រាប់ប្រើប្រាស់។
- លោកគ្រូពីនាក់បានឆ្លើយនឹងសំណួរសម្ភាសថា បំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេសមានសារប្រយោជន៍ខ្លាំងដល់ការបង្រៀនមុខវិជ្ជាភាសាអង់គ្លេស។ ចំណែកលោកគ្រូម្នាក់ទៀតបានឆ្លើយថា ខ្លាំងណាស់ ។
- លោកគ្រូទាំងបីនាក់បានប្រាប់ឱ្យដឹងថា សៀវភៅសិក្សាគោលដែលកំពុងប្រើប្រាស់រាល់ថ្ងៃនេះ មានកម្រិតខ្ពស់ជាងសមត្ថភាពរបស់សិស្ស។
- ចំណែចំនួនមេរៀនក្នុងសៀវភៅសិក្សាគោលវិញ លោកគ្រូទាំងបីនាក់និយាយថាមិនសមស្របទៅនឹងពេលវេលាដែលត្រូវដាក់ឱ្យបង្រៀនក្នុងមួយឆ្នាំទេ។

- លោកគ្រូអ្នកគ្រូនិយាយថា ម៉ោងសិក្សាប្រចាំសប្ដាហ៍នៅសាលារបស់ពួកគាត់មិនគ្រប់គ្រាន់សម្រប់ឱ្យសិស្សរៀនចេះទេ។
- បន្ថែមលើចំនុចម៉ោងសិក្សាប្រចាំសប្ដាហ៍នេះ លោកគ្រូទាំងបីនាក់និយាយថា គួរតែមានយ៉ាងតិច ៦ ម៉ោងក្នុងមួយសប្ដាហ៍។ លោកគ្រូម្នាក់បានបន្ថែមថា ភាសាខ្មែរដែលជាភាសាជាតិ ហើយសិស្សចេះនិយាយ និង ស្ដាប់ស្រាប់ ហើយមានដល់ទៅ ៦ម៉ោងក្នុងមួយសប្ដាហ៍ សិស្សច្រើនណាស់នៅរៀនមិនចេះ។ ចុះទម្រាំភាសាអង់គ្លេសដែលជាភាសាបរទេស ហើយរៀនបានតែ ៤ ម៉ោងក្នុងមួយសប្ដាហ៍ សិស្សរៀនយ៉ាងមិចនឹងចេះកើតនោះ។

## ៤.២.៣ សម្ភារឧបទ្ទេសការបង្រៀន

- លោកគ្រូទាំងបីនាក់បានប្រាប់ថា ពួគគាត់បានប្រប្រាស់សៀវភៅសិកស្សាគោលជាសម្ភារសំខាន់បំផុតក្នុងការបង្រៀន ហើយពួកគាត់បានប្រើប្រាស់គ្រប់ពេល។
- ចំណែកសៀវភៅគ្រូវិញ (Teacher's Guide) លោកគ្រូម្នាក់គាត់ថា គាត់ប្រើប្រាស់គ្រប់ពេលដែរ។ លោកគ្រូម្នាក់ថាប្រើប្រាស់បានញឹកញាប់ ។ ចំណែកលោកគ្រូម្នាក់ទៀតថា គាត់ប្រើប្រាស់ម្ដងម្កាល។
- ចំពោះប្រដាប់បំពងសំឡេង (Speaker) លោកគ្រូម្នាក់និយាយថា គាត់បានប្រើប្រាស់ញឹកញាប់ ហើយលោកគ្រូពីរនាក់ទៀតនិយាយថាពួកគាត់បានប្រើប្រាស់ម្ដងម្កាល។
- លោកគ្រូទាំងបីនាក់ និយាយថាពួកគាត់បានប្រើប្រាស់បណ្ណរូបភាព/បណ្ណពាក្យម្ដងម្កាល។
- លោកគ្រូទាំងបីនាក់និយាយាថាពួកគាត់មិនដែលបានប្រើប្រាស់បន្ទប់អនុវត្តការស្ដាប់ទេ ព្រោះវិទ្យាល័យរបស់ពួកគាត់ មិនមានបន្ទប់សម្រាប់អនុវត្តការស្ដាប់ទេ។
- ចំណែកឯបណ្ណាល័យដែលមានឯកសារជាភាសាអង់គ្លេសវិញ ពួកគាត់បានចូលអានម្ដងម្កាលប៉ុណ្ណោះ ព្រោះក្នុងបណ្ណាល័យពុំសូវមានឯកសារភាសាអង់គ្លេសទេ។
- លោកគ្រូទាំងបីនាក់មានប្រសាសន៍ថា ការប្រើប្រាស់សម្ភារឧបទ្ទេសគ្រប់ ម៉ោងបង្រៀនពិតជាមានប្រយោជន៍ណាស់ដល់ការសិក្សាភាសាអង់គ្លេសរបស់សិស្សានុសិស្ស។

### ៤.២.៤ សកម្មភាពរៀនរបស់សិស្សក្នុងថ្នាក់

លោកគ្រូម្នាក់មានប្រសាសន៍ថា គាត់បានឱ្យសិស្សធ្វើការម្នាក់ឯងបានញឹកញាប់ចំណែកឯ លោកគ្រូពីរនាក់ទៀតមានប្រសាសន៍ថាការឱ្យសិស្សធ្វើការម្នាក់ឯងមិនសូវល្អទេ ដូចនេះពួកគាត់ពុំសូវឱ្យសិស្សធ្វើការម្នាក់ឯងទេ។ ពួកគាត់ភាគច្រើនរៀបចំឱ្យសិស្សធ្វើការជាដៃគូ ឬជាក្រុមដើម្បីឱ្យសិស្សពួកគេមានឱកាសពិភាក្សាគ្នា។ ប៉ុន្តែលោកគ្រូទាំងបីនាក់បានឆ្លើយដូចគ្នាថា ការធ្វើអន្តរទំនាក់ទំនងពិតជាមានសារសំខាន់ណាស់ ។ ហេតុដូចនេះហើយទើបពួកគាត់ពេលខ្លះឱ្យសិស្សធ្វើសកម្មភាពមួយរួមគ្នាក្នុងថ្នាក់ទាំងមូលតែម្តង។ ពួកគាត់បន្ថែមទៀតថា ការធ្វើបែបនេះនាំឱ្យសិស្សមានឱកាសច្រើនក្នុងការប្រើប្រាស់ភាសាដែលគេបានរៀន យកមកនិយាយប្រាស្រ័យទាក់ទងគ្នាហាក់បីដូចជាសង្គមមួយ។

លោកគ្រូទាំងបីនាក់បាននិយាយថា ពួកគាត់បានរៀបចំដាក់កិច្ចការផ្ទះសិស្សជាប្រចាំចន្លោះពី ១ ទៅ ២ ដងក្នុងមួយសប្តាហ៍។ ពួកគាត់ថា កិច្ចការផ្ទះមានសារៈសំខាន់ណាស់ដើម្បីឱ្យសិស្សរៀនស្វ័យសិក្សាដោយខ្លួនឯងនៅផ្ទះ។ ពួកគាត់ក៏បានបន្ថែមទៀតថា ពួកគាត់តែងតែកែរាល់កិច្ចការដែលបានដាក់ឱ្យទាំងអស់។

លោកគ្រូទាំងបី បានបង្ហើបឱ្យដឹងថា ពួកគាត់បានលើកទឹកចិត្តសិស្សឱ្យខិតសិក្សាភាសាអង់គ្លេសដោយប្រាប់ពីអត្ថប្រយោជន៍របស់វាទៅថ្ងៃក្រោយ ជាពិសេសគឺនៅពេលពួកគេបន្តការសិក្សានៅមហាវិទ្យាល័យ។

### ៤.២.៥ ការរៀបចំមេរៀន

ទាក់ជាមួយការរៀបចំមេរៀន លោកគ្រូទាំងបីនាក់បានឱ្យដឹងថា ពួកគាត់តែងតែរៀបចំកិច្ចតែការបង្រៀនគ្រប់មេរៀនទាំងអស់មុនពេលបង្រៀន។ពួកគាត់និយាយថា ស៊ូរមិនបង្រៀនប្រសើរជាបង្រៀនខុស ដូចច្នេះពួកគាត់បានបន្ថែមទៀតថា ក្នុងករណីដែលគាត់រវល់មិនបានរៀបចំមេរៀន ពួកគាត់នឹងដាក់តេស្តឱ្យសិស្សជំនួសការបង្រៀនប្រចាំថ្ងៃ។

### ៤.២.៦ បរិមាណសិស្សក្នុងថ្នាក់

លោកគ្រូទាំងបីនាក់មានប្រសាសន៍ដូចៗគ្នាថា ថ្នាក់រៀនរបស់គាត់មានសិស្សរហូតដល់ចន្លោះពី ៤០ ទៅ ៤៥ ឬ លើស។ ការមានចំនួនសិស្សច្រើនក្នុងថ្នាក់បង្កឱ្យមានការលំបានខ្លាំងណាស់ដល់ការបង្រៀន។ ការលំបាកទាំងនោះមានដូចជា ពិបាកក្នុងការពន្យល់ ពិបាកក្នុងការបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល ពោលគឺ ពិបាកក្នុងការរៀនចំតុ ការពិភាក្សាជាដៃគូ និង ជាក្រុមជាដើម។

### ៤.២.៧ ស្ថានភាពសិស្សក្នុងថ្នាក់

លោកគ្រូទាំងបីសង្កេតឃើញថា ការមករៀនទៀងទាត់ និង ទាន់ពេលវេលា មានកម្រិតល្អច្រើន មានសិស្សតែ ១ ឬ ២ នាក់ប៉ុណ្ណោះក្នុងមួយថ្នាក់ដែលមានអវត្តមានច្រើន។ ចំណែកឯការយកចិត្តទុកដាក់ស្តាប់គ្រូក្នុងម៉ោងសិក្សាវិញក៏មានលក្ខណៈល្អគួរសមដែរ។ សិស្សមួយចំនួនធំបានចូលរួមធ្វើកិច្ចការដែគ្រូដាក់ឱ្យល្អ មានតែចំនួនសិស្សតិចតួចប៉ណ្ណោះដែលមិនសូវបានបញ្ចេញសកម្មភាព។ ចំណែកឯកិច្ចការផ្ទះដែលគ្រូដាក់វិញ សិស្សប្រហែលជា ៩៨ % បានធ្វើ ទោះបីជាខ្លះបានល្អ និងខ្លះមិនបានល្អក៏ដោយ។

### ៤.២.៨ បញ្ហាប្រឈមនានាចំពោះការបង្រៀនភាសាអង់គ្លេស

ជាចុងបញ្ចប់កិច្ចសម្ភាស លោកគ្រូទាំងបីនាក់បានសម្តែងអារម្មណ៍ទាក់ទងនឹងបញ្ហាប្រឈមនានាក្នុងការបង្រៀនភាសាអង់គ្លេសដូចជា សិស្សក្នុងថ្នាក់នីមួយៗច្រើនពេក ម៉ោងបង្រៀនតិចពេក សៀវភៅមានមេរៀនច្រើន និង ហួសពីសមត្ថភាពសិស្ស កង្វះឯកសារសម្រាប់ស្រាវជ្រាវបន្ថែម ខ្វះសម្ភារឧបទ្ទេស សៀវភៅសិក្សាគោលមានមិនគ្រប់ និង សៀវភៅចេញថ្មីមិនបានហៅគ្រូទៅបំប៉ន ជាហេតុនាំឱ្យមានមេរៀនមួយចំនួនត្រូវពួកគាត់រំលងចោល ព្រោះមិនយល់ពីសកម្មភាពមេរៀន មិនយល់ពីវត្ថុបំណងមេរៀន មិនដឹងថាត្រូវដើរតាមណាដើម្បីសម្រេចវត្ថុបំណងមេរៀន។

## ៤.៣ ការយល់ឃើញរបស់សិស្ស( សំណួរស្ទង់មតិ )

បន្ទាក់ពីការប្រមូលទិន្នន័យពីសិស្សថ្នាក់ទី៧ ដល់ ៩ ចំនួន ២៥០នាក់តាមរយៈការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវបានយកទិន្នន័យទាំងអស់មកបញ្ចូលក្នុងកម្មវិធី SPSS និងធ្វើការវិភាគកត្តាដែលជះឥទ្ធិពលដល់ការបង្រៀន និង រៀនភាសាអង់គ្លេស តាមចំណុចសំខាន់ៗទាក់ទងនឹងចំណុចសំខាន់ៗដូចជា គុណវុឌ្ឍិគ្រូបង្រៀន កម្មវិធីសិក្សា សម្ភារឧបទ្ទេស សកម្មភាពរៀនក្នុងថ្នាក់ ចំនួនសិស្សក្នុងថ្នាក់ ស្ថានភាពសិក្សារបស់សិស្ស។ ហើយលទ្ធផលក៏បានចេញដូចតារាងទី២ ខាងក្រោម៖

តារាងទី២៖ចម្លើយរបស់កម្រងសំណួរតាមក្រុម

| **កត្តាដែលជះឥទ្ធិពលលើការបង្រៀន និង រៀន** | **ចំនួនសិស្ស** | **អប្បបរមា** | **អតិបរមា** | **មធ្យម** | **គំលាតស្តង់ដា** |
|---|---|---|---|---|---|
| គុណវុឌ្ឍិគ្រូបង្រៀន | 250 | 1.00 | 3.67 | 1.90 | 0.46 |
| កម្មវិធីសិក្សា | 250 | 1.50 | 1.75 | 1.60 | 0.12 |
| សម្ភារឧបទ្ទេស | 250 | 1.90 | 3.60 | 2.68 | 0.35 |
| សកម្មភាពរៀនក្នុងថ្នាក់ | 250 | 1.50 | 3.67 | 2.34 | 0.46 |
| ចំនួនសិស្សក្នុងថ្នាក់ | 250 | 2.00 | 4.50 | 3.22 | 0.45 |
| ស្ថានភាពសិក្សារបស់សិស្ស | 250 | 1.00 | 3.75 | 2.62 | 0.56 |

កត្តាដែលប៉ះពាល់ដល់គុណភាពនៃការបង្រៀន និងរៀនភាសាអង់គ្លេសដែលសំខាន់ៗនៅកម្រិតមធ្យមសិក្សាមបមភូមិនៃវិទ្យាល័យ គិត ម៉េង ប្រាសាទមានដូចជា គុណវុឌ្ឍិគ្រូបង្រៀនភាសាអង់គ្លេស កម្មវិធីសិក្សាភាសាអង់គ្លេស ការប្រើប្រាស់សម្ភារឧបទ្ទេស សកម្មភាពរៀនក្នុងថ្នាក់ និង ស្ថានភាពសិក្សារបស់សិស្ស ។ កត្តាទាំងនេះត្រូវបានសិស្សានុសិស្សបំពេញតារាងសំណួរ ហើយអ្នកស្រាវជ្រាវបានយកមកវិភាគ និងមានលទ្ធផលដូចតទៅ៖

## ៤.៣.១ គុណវុឌ្ឍិគ្រូបង្រៀនភាសាអង់គ្លេស

ខាងក្រោមជា ក្រាបបង្ហាញពីគុណវុឌ្ឍិគ្រូបង្រៀនភាសាអង់គ្លេសដែលបានបំពេញកម្រងសំណួរដោយសិស្សថ្នាក់ទី ៧ ៨ និង ៩ នៅវិទ្យាល័យ គិត ម៉េង ប្រាសាទ ខេត្ត តាកែវ។ ហើយគុណវុឌ្ឍិគ្រូបង្រៀនភាសាអង់គ្លេសរួមមាន៖

១. តើគ្រូភាសាអង់គ្លេសរបស់ប្អូនមានចំណេះដឹងកម្រិតណា?

២. តើគ្រូដែលមានសមត្ថភាពខ្ពស់ ជួយឱ្យប្អូនឆាប់យល់មេរៀនបានដល់កម្រិតណា?
៣.តើប្អូនយល់ឃើញយ៉ាងណា ចំពោះការបង្រៀនភាសាអង់គ្លេសរបស់គ្រូប្អូន?

ក្រាបទី១៖គុណវុឌ្ឍគ្រូបង្រៀនភាសាអង់គ្លេស




ក្រាបខាងលើបង្ហាញថា កម្រិតនៃការយល់ឃើញរបស់សិស្សទាក់ទងនឹងគុណវុឌ្ឍិគ្រូបង្រៀនដែលអ្នកស្រាវជ្រាវឱ្យសិស្សានុសិស្សបំពេញកម្រងសំណួរ ហើយទទួលបានលទ្ធផលគឺ អប្បបរមា: ១.០០ អតិបរមា: ៣.៧៥ មធ្យម: ១.៩ និង គំលាតស្តង់ដា: ០.៤៦។ តាមរយៈការស្រាវជ្រាវនេះបង្ហាញថាលលទ្ធផលត្រឹមត្រូវ និងទទួលយកបានព្រោះគំលាតស្តង់ដាមានកម្រិតទាប (០.៤៦) ដែលបង្ហាញឱ្យឃើញថាការបំពេញកម្រងសំណួរដោយព្រាវៗមានតិចតួច ។

### ៤.៣.២ កម្មវិធីសិក្សា

ខាងក្រោមជាក្រាបដែលវិភាគចេញមកពីការបំពេញកម្រងសំណួររបស់សិស្សានុសិស្សវិទ្យាល័យ គិត ម៉េង ប្រាសាទ ពីថ្នាក់ទី ៧ ដល់ ថ្នាក់ទី ៩ ក្នុងកំឡុងឆមាសទី ១ ឆ្នាំសិក្សា ២០១៨-២០១៩។ កម្មវិធីសិក្សាជះឥទ្ធិពល ទាំងវិជ្ជមាន និង អវិជ្ជមានដល់លទ្ធផលនៃការបង្រៀន និង រៀនភាសាអង់គ្លេស។ កត្តាទាំងនោះមានដូចជា៖

១.តើខ្លឹមសារមេរៀនក្នុងសៀវភៅពុម្ពសមស្របទៅនឹងកម្រិតសមត្ថភាពភាសាអង់គ្លេសរបស់ប្អូនៗឬទេ?

២. តើប្អូនចាប់អារម្មណ៍ដូចម្តេចចំពោះសៀវភៅពុម្ពភាសាអង់គ្លេសដែលកំពុងរៀនសព្វថ្ងៃ?

៣.តើម៉ោងភាសាអង់គ្លេសនៅសាលារបស់ប្អូនគ្រប់គ្រាន់សម្រាប់ការរៀនរបស់ប្អូនឬទេ?

៤. បើមិនគ្រប់គ្រាន់ តើម៉ោងសិក្សាភាសាអង់គ្លេសនៅសាលារដ្ឋគួរតែមានប៉ុន្មានម៉ោងក្នុងមួយសប្តាហ៍ទើបគ្រប់គ្រាន់ក្នុងការសិក្សា?




ក្រោយការវិភាគក្រោយពេលដែលអ្នកស្រាវជ្រាវយកកម្រងសំណួរឱ្យសិស្សនុសិស្សថ្នាក់ទី ៧ ៨ និងទី ៩ បង្ហាញថា គំលាតស្តង់ដាគឺ ០.១២ មធ្យម: ១.៦ អតិបរមា: ១.៧៥ និង អប្បរមា: ១.៥។ Barនេះជាដែលអ្នកស្រាវជ្រាវអាចនិយាយបានថាជា Bar ដែលមានលក្ខណៈវិទ្យាសាស្ត្រព្រោះគំលាតស្តង់ដាទាប (០.១២) ដែលបង្ហាញថា ការបំពេញកម្រងសំណួររបស់សិស្សមានការយកចិត្តទុកដាក់ខ្ពស់ មិនមែនគ្រាន់តែជាការបំពេញកម្រងសំណួរលេងសើចឡើយ។

## ៤.៣.៣ សម្ភារឧបទ្ទេស

សម្ភារឧបទ្ទេសជាធាតុចូលមួយយ៉ាងសំខាន់ដែលជះឥទ្ធិពលដល់ការបង្រៀន និង រៀនភាសាអង់គ្លេស ។ ក្នុងឆមាសទី ១ ឆ្នាំសិក្សា ២០១៨-២០៩ អ្នកស្រាវជ្រាបានធ្វើការស្រាវជ្រាវមួយដែលមានចំណងជើងថា ការបង្រៀន និង រៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ ករណីសិក្សាវិទ្យាល័យ គិត ម៉េង ប្រាសាទ ខេត្ត តាកែវ។ សម្ភារឧបទ្ទេសសំខាន់ៗមានដូចជា៖ សៀវភៅពុម្ព ម៉ាញ៉េចាក់កាសែត ឬស៊ីឌី បណ្ណរូបភាព / បណ្ណពាក្យ បន្ទប់

អនុវត្ត (ការស្តាប់ និងមើលវីឌីអូ) បណ្ណាល័យដែលមានឯកសារជាភាសាអង់គ្លេស។ ហើយ ។ ក្នុងចំណុចនេះអ្នកស្រាវជ្រាវបានឱ្យសិស្សានុសិស្សជ្រើសរើសតាមជាក់ស្តែងពីការការប្រើប្រាស់សម្ភារៈទាំងនេះ។ ហើយក៏មានសំណួរមួយដែលសួរថា៖

១. ការប្រើសម្ភារឧបទេសគ្រប់គ្រាន់ តើមានប្រយោជន៍ដល់ការសិក្សាភាសាអង់គ្លេសរបស់ប្អូនដល់កម្រិតណា?

ក្រោយពេលប្រមូលទិន្នន័យពីសិស្សានុសិស្សអ្នកស្រាវជ្រាវទទួលបានលទ្ធផលដូចខាងក្រោម៖

ក្រាបទី៣៖សម្ភារឧបទេស




ក្រោយពេលបញ្ចូលទិន្នន័យក្នុងកម្មវិធី SPSS រួចវិភាគ អ្នកស្រាវជ្រាវទទួលបានលទ្ធផលដូច Area ខាងលើ។ Are បង្ហាញថា អតិបរមាគឺ ៣.៦ អប្បបរមា: ១.៩ មធ្យម ២.៦៨ និង គំលាតស្តង់ដា: ០.៣៥ ។ តាមរយៈគំលាតស្តង់ដា អ្នកស្រាវជ្រាវអាចនិយាយបានថា ការស្រាវជ្រាវនេះមានគុណភាព ព្រោះគំលាតស្តង់ដាទាប ពោលគឺត្រឹម ០.៣៥។

### ៤.៣.៤ សកម្មភាពរៀនក្នុងថ្នាក់

សកម្មភាពរៀនក្នុងថ្នាក់ជាកត្តាដែលជះឥទ្ធិពលខ្លាំងដល់ការបង្រៀន និងរៀនភាសាអង់គ្លេស។ សកម្មភាពទាំងនោះរួមមាន៖

១.តើលោកគ្រូអ្នកគ្រូប្រើប្រាស់សកម្មភាពទាំងនេះនៅក្នុងការបង្រៀនបានកម្រិតណា?

ក. សិស្សធ្វើការម្នាក់ឯង

ខ. សិស្សធ្វើការជាដៃគូ

គ. សិស្សធ្វើការជាក្រុម

ឃ. សិស្សទាំងអស់ធ្វើការរួមគ្នា

២.តើលោកគ្រូ អ្នកគ្រូបានលើកទឹកចិត្តឱ្យខំរៀនភាសាអង់គ្លេសដល់កម្រិតណានៅពេលបង្រៀន?

៣.តើគ្រូមុខវិជ្ជាភាសាអង់គ្លេសបានដាក់កិច្ចការផ្ទះឱ្យប្អូនធ្វើប៉ុន្មានដងក្នុងមួយសប្ដាហ៍?

Pie ខាងក្រោមបង្ហាញពីការយល់ដឹងរបស់សិស្សវិទ្យាល័យ គិត ម៉េង ប្រាសាទទាក់ទងនឹងសកម្មភាពនៃការបង្រៀន និងរៀនភាសអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ។

ក្រាបទី៩៖សកម្មភាពរៀន និងបង្រៀន




Pie ខាងលើជាលទ្ធផលក្រោយការប្រមូលទិន្ន័យ ហើយបញ្ចូលក្នុងកម្មវិធី SPSS របស់អ្នកស្រាវជ្រាវ ។ តាម Pie បង្ហាញថា អប្បបរមា: ១.៥ អតិបរមា: ៣.៦៧ មធ្យម: ២.៣៤ និងគំលាតស្តង់ដា: ០.៤៦។ តាមរយ:ការវិភាគរកទិន្ន័យ បង្ហាញថា វាជាការស្រាវជ្រាវដែលមានលក្ខណ:បែបវិទ្យាសាស្រ្ត ព្រោះគំលាតស្តង់ដាកដែលរកឃើញដោយអ្នកស្រាវជ្រាវមានកម្រិតទាប (០.៤៦) ប៉ុណ្ណោះ។

### ៤.៣.៥ ចំនួនសិស្សក្នុងថ្នាក់

ចំនួនសិស្សក្នុងថ្នាក់ជាកត្តាមួយក្នុងចំណោមកត្តាសំខាន់ៗដែលជះឥទ្ធិពលខ្លាំងដល់ការបង្រៀន និង រៀនភសាអង់គ្លេស ។ Blatchford (2003) បានពន្យល់ថាមានយុទ្ធសាស្រ្តជាច្រើនសម្រាប់លើកកម្ពស់ស្តង់ដា
អប់រំ។ អ្នកសិក្សារូបនេះក៏បានពន្យល់បន្ថែមទៀតថា ថ្នាក់តូចអាចនាំឱ្យគុណភាពការរៀននិងបង្រៀនប្រសើរឡើង។ នៅពេលដែលគាត់បានចុះទៅអង្កេតនៅថ្នាក់រៀនមួយដែលមាន

សិស្ស១៥នាក់ឃើញថា ស្ថានភាពទូទៅនៅក្នុងថ្នាក់រៀននោះគឺវិជ្ជមាន ដោយគ្រូតែងតែនិយាយលេងសើចជាមួយសិស្ស និងមានការទំនាក់ទំនងផ្ទាល់ខ្លួនជាច្រើន។ ក្រៅពីនេះ អ្នកស្រាវជ្រាវក៏ចុះទៅអង្កេតថ្នាក់រៀនធំផ្សេងទៀតដែលមានសិស្សចំនួន៣០នាក់ ហើយបានរកឃើញថារវាងថ្នាក់ទាំងពីរមានសភាពខុសគ្នាគួរឱ្យកត់សម្គាល់។ នៅក្នុងថ្នាក់តូចគ្រូបានចំណាយពេលតិចតួចនៅក្នុងការគ្រប់គ្រងថ្នាក់រៀន ប៉ុន្តែនៅក្នុងថ្នាក់ធំគ្រូព្យាយាមចំណាយពេលជាច្រើនដើម្បីទាញចំណាប់អារម្មណ៍សិស្សលើការងារដែលគ្រូដាក់។

ម៉្យាងទៀតនៅក្នុងថ្នាក់តូចគ្រូស្គាល់សិស្សម្នាក់ៗច្បាស់ ដែលអាចឱ្យគ្រូជួយសិស្សក្នុងការសិក្សាបានងាយស្រួល (Blatchford, 2003)។ Hong Thi Nguyen, Wendy Warren & Heather Fehring, (2014) បានធ្វើការសិក្សាមួយទៀតគឺ បានធ្វើការអង្កេតថ្នាក់មួយចំនួននៅក្នុងសាលា HUTECH ក្នុងប្រទេសវៀតណាម ដែលក្នុងនោះថ្នាក់រៀនភាគច្រើនមានសិស្សច្រើនចាប់ពី៤០ នាក់ ដល់ទៅ៥០ នាក់។ ជាលទ្ធផលរកឃើញថាក្នុងថ្នាក់រៀនដែលមានសិស្សតិចគឺ ការសិក្សារបស់សិស្សទទួលបានលទ្ធផលជាង ពីព្រោះនៅក្នុងថ្នាក់រៀនតូចគ្រូងាយស្រួលគ្រប់គ្រងរាល់សកម្មភាពទាំងឡាយដែលគ្រូដាក់ឱ្យសិស្សអនុវត្ត និងធ្វើ។ ចណុចសំខាន់ៗដែលទាក់ទងនឹងចំនួនសិស្សក្នុងថ្នាក់រួមានៈ

Pie ខាងក្រោមជាលទ្ធផលនៃការបំពេញកម្រងសំណួរដែលរៀបចំឡើងដោយអ្នកស្រាវជ្រាវ ហើយអ្នកស្រាវជ្រាវបានឱ្យសិស្សានុសិស្សថ្នាក់ទី ៧ ៨ និងទី ៩ នៃវិទ្យាល័យ គិត ម៉េង ប្រាសាទ បំពេញក្នុងឆមាសទី ១ ឆ្នាំសិក្សា ២០១៨-២០១៩។ ក្រោយពេលប្រមូលទិន្ន័យរួច អ្នកស្រាវជ្រាវបានយកទិន្ន័យដែលប្រមូលបានមកត្រួតពិនិត្យ រួចបញ្ចូលក្នុងកម្មវិធី SPSS រួចទទួលបានលទ្ធផលដូចក្នុង Pie ។ ចំណុចសំខាន់ៗដែលនាំឱ្យមានជាលទ្ធផលដល់ការបង្រៀន និង រៀនមានៈ

១. តើនៅក្នុងថ្នាក់រៀនប្អូន ជាមធ្យមមានសិស្សប៉ុន្មាននាក់?

២.តើចំនួនសិស្សច្រើននៅក្នុងថ្នាក់អាចធ្វើឱ្យជះឥទ្ធិពលអវិជ្ជមានដល់ការសិក្សាដល់កម្រិតណា?

តាមរយៈក្រាបបង្ហាញថា អប្បបរមាគឺ ២.០០ អតិបរមាៈ ៤.៥០ មធ្យម ៣.២២ និង

គំលាតស្តង់ដាៈ ០.៤៥ ។ តាមយៈលទ្ធផលនេះ បង្ហាញថាជាលទ្ធផលមួយបានការ និងមានលក្ខណៈវិទ្យាសាស្ត្រ ព្រោះគំលាតស្តង់ដាមានកម្រិតទាប (ត្រឹម ០.៤៥) ។ វាក៏ជាការ

បង្ហាញមួយថា សិស្សានុសិស្សដែលបានមបំពេញកម្រងសំណួរភាគច្រើនគឺបំពេញដោយយកចិត្តទុកដាក់។

ក្រាបទី៥៖ចំនួនសិស្សក្នុងថ្នាក់




### ៤.៣.៦ ស្ថានភាពសិក្សារបស់សិស្ស

ស្ថានភាពសិស្សក្នុងថ្នាក់ជាកត្តាមួយទៀតក្នុងចំណោមកត្តាដែលជះឥទ្ធិពលខ្លាំងដល់ដំណើរការបង្រៀន និង រៀនភាសាអង់គ្លេស។ ស្ថានភាពសិស្សក្នុងថ្នាក់មានដូចជា៖

១. មករៀនទៀងទាត់ និងទាន់ពេលវេលា
២. យកចិត្តទុកដាក់ស្តាប់គ្រូក្នុងម៉ោងសិក្សា
៣. ចូលរួមធ្វើសកម្មភាពផ្សេងៗដែលគ្រូដាក់ឱ្យក្នុងថ្នាក់
៤. ធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យទៀងទាត់

បន្ទាប់ពីការប្រមូលកម្រងសំណួរយកមកបញ្ចូលទិន្ន័យ រួចអ្នកស្រាវជ្រាវទទួលបានលទ្ធផលដូចក្នុង Line ខាងក្រោម។ អប្បបរមា: ១.០០ អតិបរមា: ៣.៧៥ មធ្យម: ២.៦២ និង គំលាតស្តង់ដា: ០.៥៨ ។ ដោយសារអ្នកស្រាវជ្រាវសង្កេតឃើញ គំលាតស្តង់ដា មានកម្រិតទាបទើបអ្នកស្រាវជ្រាវសន្និដ្ឋានថា លទ្ធផលនេះជាលទ្ធផលត្រឹមត្រូវ និង មានលក្ខណៈវិទ្យាសាស្ត្រ។

ក្រាបទី៦៖ស្ថានភាពសិក្សារបស់សិស្ស




## ៤.៤ ការពិភាក្សា

### ៤.៤.១ ការពិភាក្សានៅលើសំណួរសម្ភាស

តាមរយៈការសម្ភាសជាមួយនាយកសាលា នាយករង និង គ្រូបង្រៀនភាសាអង់គ្លេស បង្ហាញស្ថានភាពនៃការបង្រៀន និង រៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងវិទ្យាល័យ គិត ម៉េង ប្រាសាទ មានស្ថានភាពល្អបង្គួរ និង មានការខ្វះខាតសម្ភារៈមួយចំនួនដូចជាបន្ទប់សិក្សា (បន្ទប់សិក្សានីមួយៗមានសិស្សច្រើនចាប់ពី ៤២ ដល់ ៤៩) ប្រដាប់បំពងសសំឡេងសម្រាប់ចាក់ឱ្យសិស្សស្តាប់ (Speaker មានតែមួយ) បន្ទប់ហាត់ស្តាប់ភាសាអង់គ្លេស បន្ទប់មើលវីដេអូ និង បណ្ណាល័យខ្វះឯកសារជាភាសាអង់គ្លេសជាដើម ។ ទាំងនេះជាបញ្ហាប្រឈមដែលត្រូវតែដោះស្រាយដើម្បីឱ្យស្ថានភាពល្អប្រសើរ។

### ៤.៤.២ ការពិភាក្សានៅលើកម្រងសំណួរ

តាមរយៈកម្រងសំណួរទាំង ២៥០ ដែលបំពេញដោយសិស្សានុសិស្សវិទ្យាល័យ គិត ម៉េង ប្រាសាទ បង្ហាញថា កត្តាដែលជះឥទ្ធិពលខ្លាំងជាងគេដល់ សកម្មភាពនៃការបង្រៀន និង រៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងវិទ្យាល័យ គិត ម៉េង ប្រាសាទ

នោះ គឺ ចំនួនសិស្សក្នុងថ្នាក់ (តារាងទី ១ និង ក្រាបទី ៥) ដែលបង្ហាញថា អប្បបរមា គឺ ២.០០ អតិបរមា ៤.៥០ និង មធ្យម ៣.២២ ។ តាមរយៈ Figures នេះបង្ហាញថា ចំនួនសិស្សច្រើនក្នុងថ្នាក់វាពិតជាបង្កឱ្យមានផលអវិជ្ជមានដល់ដំណើរការនៃការបង្រៀន និង រៀនខ្លាំងដូចជា គ្រូមានការពិបាកក្នុងការពន្យល់ ពិបាកក្នុងការបែងចែកក្រុម ពិបាកក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ។

## ៤.៥. សំណូមពរទាក់ទងនឹងបញ្ហាប្រឈមនានាចំពោះការសិក្សាភាសាអង់គ្លេសរបស់សិស្ស

សិស្សានុសិស្សភាគច្រើនភាគច្រើនសំណូមពរឱ្យបន្ថែមម៉ោងសិសក្សាភាសាអង់គ្លស។ សូមបញ្ជាក់ថា ម៉ោងសិក្សាភាសាអង់គ្លេសបច្ចុប្បន្នមានចំនួន ៤ ម៉ោងក្នុងមួយសប្តាហ៍។ សិស្សនុសិស្សភាពច្រើនសំណូមពរឱ្យបង្កើនថែម ២ ម៉ោងទៀតដែលសរុបទៅស្មើនឹង ៦ ម៉ោងក្នុង ១ សប្តាហ៍។ ជាមួយគ្នានេះដែរ សិស្សនុសិស្សបានសំណូមពរឱ្យក្រសួងផ្តល់សៀវភៅសិក្សាគោលឱ្យបានគ្រប់គ្រាន់ព្រោះពួកគេភាគច្រើនទិញសៀវភៅដោយខ្លួនឯង ឬសៀវភៅមួយប្រើពីរនាក់ ។ សិស្សមួយចំនួនទៀត សំណូមពរកុំឱ្យគ្រូបង្រៀនមេរៀនលឿនពេកព្រោះពួកគេតាមមិនទាន់។ ចំណែកឯ សិស្សមួយចំនួនទៀតសូមឱ្យគ្រូដាក់ពិន័យសិស្សណាដែលមិនបានធ្វើកិច្ចការផ្ទះឱ្យបានធូន់ធូរ។

# ជំពូក ៥

# សេចក្តីសន្និដ្ឋាន និង សំណូមពរ

# ជំពូក ៥
# សេចក្តីសន្និដ្ឋាន និង សំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

ជាការសន្និដ្ឋាន ស្ថានភាពនៃការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិនៅក្នុងវិទ្យាល័យ គិត ម៉េង ប្រាសាទ មានកម្រិតវិជ្ជមានច្រើនគួរឱ្យកត់សម្គាល់ហើយមានការឆ្លើយតបបានល្អបង្គួរទៅនឹងអ្វីដែលអ្នកសិក្សាស្រាវជ្រាវកំពុងស្វែងរកដើម្បីបានចូលរួមជាចំណែកដ៏តូចមួយក្នុងការកែលម្អស្ថានភាពបង្រៀននិងរៀនភាសអង់គ្លេសនៅក្នុងវិទ្យាល័យនេះឱ្យមានការរីកចម្រើនឡើង។

ចំណុចល្អទាំងអស់នោះមានដូចជា គ្រូបង្រៀនភាសាអង់គ្លេសទាំងបីនាក់មានកិច្ចតែងការបង្រៀន (បានរៀបចំមុនពេលបង្រៀន) លោកគ្រូទាំងបីនាក់គោរពពេលវេលាបានល្អ លោកគ្រូទាំងបីបានចំណាយថវិកាផ្ទាល់ខ្លួនដើម្បីរៀនបន្តដែលជួយឱ្យពួកគាត់បង្កើនគុណវុឌ្ឍិ គ្រូបានដាក់កិច្ចការផ្ទះឱ្យសិស្សបានទៀងទាត់ លោកនាយក នាយករងបានតាមដានការបង្រៀនរបស់គ្រូបានជាប្រចាំជាដើម ។

ទន្ទឹមនឹងនេះចំណុចៗល្អទាំងនេះ អ្នកស្រាវជ្រាវបានរកឃើញនូវចំណុចមួយចំនួនដែលគួរតែធ្វើឱ្យមានភាពល្អប្រសើ។ ចំណុចទាំងនោះមានដូចជា គ្រូបង្រៀនទាំងបីនាក់ មានតែម្នាក់ទេ ដែលបានចូលរួមការបណ្តុះបណ្តាលស្តីអំពីវិធីសាស្រ្របង្រៀនក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ សិស្សខ្វះសៀវភៅសិក្សាគោល ថ្នាក់រៀនមានសិស្សច្រើនពេក (៥២ ទៅ ៥៩) ដោយសារខ្វះអគារសិក្សា ខ្វះសម្ភារឧបទ្ទេស មិនមានបន្ទប់សម្រាប់អនុវត្តស្តាប់ មិនបន្ទប់សម្រាប់មើលវីដេអូ បណ្ណាល័យខ្វះឯកសារភាសាអង់គ្លេស និង ម៉ោងសិក្សាមិនគ្រប់គ្រាន់។

## ៥.២. សំណូមពរ

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ និងជួយបង្កើនគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិនាពេលបច្ចុប្បន្ន អ្នកសិក្សាស្រាវជ្រាវបានលើកជាសំណូមពរមួយចំនួនដូចខាងក្រោមៈ

### ៥.២.១ ក្រសួងអប់រំ យុវជន និងកីឡា

- រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្រ្តបង្រៀនការផលិតសម្ភារឧបទេស និងចិត្ត-

គរុកោសល្យផ្សេងៗជាប្រចាំ ដើម្បីធ្វើបច្ចុប្បន្នភាពនៃការបង្រៀនដើរឱ្យទាន់សតវត្សទី២១ជាពិសេស វិធីសាស្ត្របង្រៀនបែបរិះរក គិតស៊ីជម្រៅ ការសហការ ការដោះស្រាយបញ្ហា និងពលរដ្ឋសកល ស្របទៅតាមក្របខណ្ឌកម្មវិធីសិក្សាថ្មី។

- គួរតែផ្តល់ឱ្យសាលារៀននូវ សម្ភារទ្រទ្រង់ការបង្រៀន និងរៀនភាសាអង់គ្លេសចាំបាច់មួយចំនួនដូចជា ឧបករណ៍សម្រាប់បម្រើឱ្យបំណិនស្តាប់ បណ្ណរូបភាពពណ៌ ។ ជាមួយគ្នានេះដែរត្រូវរៀបចំឱ្យសាលាទាំងអស់ មានបណ្ណាល័យដែលមានឯកសារភាសាអង់គ្លេស ឬឯកសារបម្រើឱ្យការបង្រៀន និងរៀនភាសាអង់គ្លេស ដើម្បីឱ្យសិស្សអាចមានលទ្ធភាពស្វ័យសិក្សាបង្កើនសមត្ថភាពភាសាអង់គ្លេសបន្ថែម ដែលនាំឱ្យមានគុណភាព និងប្រសិទ្ធភាពនៃការរៀន និងបង្រៀនភាសាអង់គ្លេសនៅតាមសាលារៀនរបស់រដ្ឋកាន់តែប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំសិក្សា។
- ពិនិត្យលទ្ធភាពផ្តល់ជូននូវសៀវភៅសិក្សាគោលទៅឱ្យសាលារៀន ឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ឆ្នាំសិក្សា។

### ៥.២.២ មន្ទីរអប់រំ យុវជន និងកីឡា

- គួរតែអន្តរាគមន៍ និងពិនិត្យតាមដានជាប្រចាំទៅលើការបង្រៀន និងរៀន ហើយមួយវិញទៀត រាយការណ៍ ដោះស្រាយឱ្យទាន់ពេលវេលា រាល់តម្រូវការចាំបាច់របស់សាលារៀនទៅថ្នាក់លើបន្ត ។
- គួរតែពង្រឹងរដ្ឋបាលគ្រូបន្ថែមទៅលើអ្វីដែលលោកគ្រូ អ្នកគ្រូមានស្រាប់ ។

### ៥.២.៣ គណៈគ្រប់គ្រងសាលារៀន

- គួរតែលើកទឹកចិត្តគ្រូបង្រៀន ឱ្យផលិតសម្ភារឧបទេសងាយៗ តាមរយៈការប្រជុំបច្ចេកទេសប្រចាំខែនីមួយៗ និងប្រើប្រាស់សម្ភារឧបទេសរាល់ការបង្រៀនឱ្យអស់លទ្ធភាព។ មួយទៀត គួរស្វែងរកដៃគូអភិវឌ្ឍដើម្បីឱ្យជួយឧបត្ថម្ភលើសម្ភារទ្រទ្រង់ការបង្រៀនណាដែលគ្រូមិនអាចផលិតបាន។
- ពង្រឹងបទបញ្ញត្តិរបស់សាលារៀន និង វិន័យសិស្សគ្រូឱ្យមានប្រសិទ្ធភាពខ្ពស់។

### ៥.២.៤ ចំពោះលោកគ្រូ អ្នកគ្រូ

- គួតែស្វ័យសិក្សាស្រាវជ្រាវពីវិធីសាស្ត្រណាដែលថ្មីៗជាប្រចាំពង្រឹងចំណេះដឹង ជំនាញ ទៅលើអ្វីដែលខ្លួនមានស្រាប់ ។
- គួរតែពង្រឹងរដ្ឋបាលរបស់គ្រូបន្ថែមពីលើកអ្វីដែលខ្លួនកំពុងធ្វើស្រាប់។
- ជំរុញ លើកទឹកចិត្តសិស្ស និង ពន្យល់ឱ្យពួកគេទទួលស្គាល់ពីគុណតម្លៃ និងអត្ថប្រយោជន៍នៃការសិក្សាភាសាអង់គ្លេស។

**៥.២.៥ ចំពោះសិស្សានុសិស្ស**

- គួរពង្រឹងសមត្ថភាពខ្លួនឱ្យស្ទាត់ជំនាញ ទៅលើភាសាអង់គ្លេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងទៅអនាគត។

## ៥.៣. ការស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវមួយនេះបានធ្វើឡើងតែក្នុងវិទ្យាល័យគិត ម៉េង ប្រាសាទប៉ុណ្ណោះ ដូច្នេះ លទ្ធផលដែលរកឃើញមិនអាចឆ្លើយតបទៅគ្រប់សាលា ឬ ក្នុងស្រុកឡើយ។ ហេតុនេះ អ្នកសិក្សាស្រាវជ្រាវក្រោយៗ ដែលមានបំណងចង់សិក្សាស្រាវជ្រាវបន្តលើប្រធានបទនេះគួរតែពង្រីកដែនកំណត់ និងវិសាលភាពរបស់ខ្លួនឱ្យបានធំជាងនេះ ប្រសិនបើនៅតែមានបំណងចង់សិក្សានៅក្នុងតាកែវដដែល។ ក្រៅពីនេះ អ្នកសិក្សាស្រាវជ្រាវក្រោយៗក៏អាចយកប្រធានបទនេះទៅសិក្សានៅតំបន់ទីប្រជុំជន ឬតំបន់ដាច់ស្រយាលនៅតាមបណ្តាខេត្តនានាផងដែរ ដោយសារតែគុណភាពសាលារៀន គុណភាពគ្រូបង្រៀន និងចំណេះដឹងភាសាអង់គ្លេសរបស់សិស្សនៅទីនោះអាចមានភាពខុសគ្នាឆ្ងាយពីស្ថានភាពនៅក្នុងវិទ្យាល័យ គិត ម៉េង ប្រាសាទ ខេត្ត តាកែវ ។

# ឯកសារយោង

*រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។*

ក្រសួងអប់រំ យុវជន និងកីឡា២០១៤, *ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀនៈ* នាយកដ្ឋានបណ្តុះបណ្តាលគ្រូ, ខែមករា ឆ្នាំ២០១៥។

ក្រសួងអប់រំ យុវជន និងកីឡា, *ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងបច្ចេកទេស ២០១៦, នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា*, ប្រទេសកម្ពុជា ទំ.២ & ៧។

ក្រសួងអប់រំ យុវជន និងកីឡា, *ផែនការយុទ្ធសាស្ត្រស្តីពីការអប់រំ២០១៤-២០១៨*, ប្រទេសកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា ២០១៦, *របាយការណ៍ពាក់កណ្តាលអាណត្តៈ* ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ និងការធ្វើចំណោលដល់ឆ្នាំ២០២០, ប្រទេសកម្ពុជា ទំ. ១២៨ - ១៣៥។

ក្រសួងអប់រំ យុវជន និងកីឡា ២០០៧, *ច្បាប់ស្តីពីការអប់រំ*, ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា ២០១៦, *សេចក្តីណែនាំស្តីពីការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេស English Grade 7-9*, ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា ២០១៧, *ការអប់រំភាសាបរទេសនៅកម្ពុជាៈ* លទ្ធភាពក្នុងការដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាកាតព្វកិច្ច, នាយកដ្ឋានគោលនយោបាយ។

ក្រសួងអប់រំ យុវជន និងកីឡា ២០១៥, *ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស*, នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។

រាជរដ្ឋាភិបាលកម្ពុជា ២០១៣, *យុទ្ធសាស្ត្រចតុកោណៈ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៣*, ភ្នំពេញ។

ហង់ជួន ណារ៉ុន, ២០១៦, *កំណែទម្រង់វិស័យអប់រំនៅកម្ពុជាៈ មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព*, ADB, ភ្នំពេញៈ។

Beishuizen, J. (2001). Students´ and Teachers´ recognition about good teacher. *British Journal of Educational Psychology,* 185-201.

Blatchford, P. (2003). The class size debate. Is smaller better? Philadelphia: McGraw Hills Education.

Brown, H. D. (2001). *Teaching by principles: an interactive approach to laguage pedagogy.* New York: Addison Wesley.

Burton, J. (2000). Learning from teaching practice: a case study appoach. *Prospect, 5-22.*

Celce-Murcia, M. (2001). *Teaching English as a second laguage.* Boston: Heinle &Heinle.

Cheng Liying & Andy Curtis. (2010). eachers′ self-evaluation of knowledge, skills and personality characteristics. *Asia-Pacific Journal of Teacher Education, 139-152.*

Clayton,T. (2007). TRANSITION, Cultue, language in Cambodia. IN A. B. Tollefson, *Language Policy, Culture, and Identitynin Asian Contexts (pp. 95-120).* New Jersy: Lawrence Erlbaum Associates.

Elliot, S., Kratochil, T., & Cook, J. (2000). Eduacational psychology. New York: McGraw-Hill.

Ethell, R. G. & McMeniman, M. M. (2000). Unlocking the knowledge in action of an expert practitioner. *Journal of Teacher Education,* 87-101.

Gardner, R. C. (2000). The social-educational model of second language acquisition. *A research paradigm, 237-260.*

Glatthor, A. & Jailall, J. (2000). Curriculum for the new millennium. Review of Educational Research, 99-119.

Grower, R, Phillips, D., & Walters, S. (2005). *Teaching practice: A handbook for teachers in training.* Thailand: Macmillan Education.

Hayes, D. (2014) *Factor influencing success in teaching English in state primary school.* London: British Council.

Hong Thi Nguyen, Wendy Warren & Heather Fehring. (2014). Factors Affecting English Language Teaching and Learning in Higher education. *English language teaching, 94-105.*

Huang, Z. (2010). What makes a successful EFL Teacher in China? A Case Study of an English Language Teacher at Nanjing University of Chinese Medicine. *English Language Teaching, 20-28.*

Igawa, K. (2008). English and Education in Cambodia, a Country in Transition.

*Shitennoji University Bulletin, 343-369.*

Lee, Gi-Pyo Prak 7 Hyo-Woong. (2006). The characteristics of Effective English Teachers As Perceived by High School Teacher and Students in Korea. *Asia Pacific Education Review, 236-248.*

Mao, S. (2013). Education and Policy on English Language In Cambodia. Forum publication Complete, 23-32.

Mao, S. (2013). Education and Policy on English Language In Cambodia in T, W Bigalke & S, Sabarwi(eds), ʽEnglish For ASEAN integration: Policy and Practices in region, Universiti Brunei Darrussalum.

Minh, L. L. (2013). *ASEAN STATE OF EDUCATION REPORT 2013.* Jakarta: ASEAN Secretariat.

Mosha, M. A. (2014). Factors Affecting Students′ performance in English Language in Zanzibar Rural and Urban Seccondary Schools. Jaurnal of Education and Practice, 64-77.

Naron, H. C. (2014, February 22). Education Reform, English language learning and the ASEAN Community. (A. Magazine, Interviewer)

Nuangpolmak, A. (2017). Improving Professional English proficiency in the Lower Mekong. In D. F. Drean, *Developing Classroom English Competence Learning from Vietnam Experience.* (pp. 7-18). Phnom Penh: IDP Education.

Petty, G. (1998). *Teaching today.* English: Stanley Thornes.

Richards, J., & Rodgers, T. (2001). Approaches and methods in language teaching. New Kork: Cambridge University Press.

Ryan, M, R. & Deci, E, L. (2000). Intrinsic and Exrinsic motivations: classic definitions and new directions. *Contemporary Educational Psychology, 54-67.*

Shalaway, L. (2005). Learning to teach not just beginners. New York: Scholastic.

Skaggs, A.M.N. (2007). Homework: A Nightly Ritual Beginning in the Elementary Grades. Paper Submitted for the degree of Master of Science in Education,

Dominican University of California, San Rafael, CA.

Spatt, M, Pulvemess, A., & Williams, M. (2005). *The KTK teaching knowledge test course.* Cambridge: Cambridge.

Stabback, P. (2016). What makes a quality curriculum. UNESCO.

Stern, H. (2001). *Fumdamental concepts of language teaching.* Oxford: Oxford University Press.

Tweed, A. D., & Som, M. (2015). English Language Education in Cambodia and international support ahead of ASEAN integration. *IDP Education, 13-40.*

*Vira, N. (2002). Teaching English in Cambodia secondary schools:* With a special focus on teachers′ Preferences towards the improvement of their professional career in language teaching. Hiroshima University, 197-206

Woodward, T. (2001). Planning lessons and courses: Designing sequences of work for the language classroom. Cambridge: Cambridge University Press.

Yoon, K. S., Duncan, T., Lee, S. W.-Y., Scarloss, B., & Shaply, K. (2007). Reviewing the evidence on how teacher professional development affects student achievement.Washington DC: U.S.

Elena T. T. (2006). *Concepts on The Methodology of Teaching English.* The Economic Journal of Takasaki City University of Economics vol.48 No.3 2006 pp.169-188.

# ឧបសម្ព័ន្ធ

## កម្រងសំណួរសម្រាប់នាយក

ខ្ញុំបាទឈ្មោះ អ៊ឹម សិរីរដ្ឋ ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ បានរៀបចំការសិក្សាស្រាវជ្រាវមួយទាក់ទងទៅនឹងប្រធានបទ **«ការរៀន និងបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ ករណីសិក្សាៈ វិទ្យាល័យ គិត ម៉េង ប្រាសាទ ខេត្ត តាកែវ»**។ អាស្រ័យហេតុនេះសូមលោកនាយក/នាយិកា មេត្តាជួយឆ្លើយនូវកម្រងសំណួរនេះតាមភាពជាក់ស្តែងរបស់ខ្លួន។ **រាល់ចម្លើយរបស់លោកនាយក/នាយិកាទាំងអស់ នឹងត្រូវបានរក្សាជាការសម្ងាត់** និង ត្រូវប្រើសម្រាប់តែសរសេរនិក្ខេបបទនេះប៉ុណ្ណោះ។ សូមថ្លែងអំណរគុណដល់លោកនាយក-នាយិកាទាំងអស់ដែលបានចំណាយពេលវេលាក្នុងការចូលរួមជាមួយខ្ញុំបាទ ក្នុងការសិក្សាស្រាវជ្រាវដ៏មានសារៈសំខាន់មួយនេះ។

**សូមបំពេញ ដោយគូសសញ្ញា ✓ ក្នុងប្រអប់ ☐ និងបំពេញចន្លោះតាមភាពជាក់ស្តែងរបស់លោកនាយក/នាយិកាដែលជ្រើសរើស ។**

### ផ្នែកទី១៖ ព័ត៌មានទូទៅ

ខេត្ត៖ តាកែវ

១. ស្រុក/ក្រុង៖ …………………………………… ២. សាលា៖ …………………………………

៣. ឋានៈ តួនាទី៖ ☐ ១. នាយក/នាយយិកា ☐ ២. នាយក/នាយិការង

៤. ភេទ៖ ☐ ១. ប្រុស ☐ ២. ស្រី

### ផ្នែកទី២៖ គុណវុឌ្ឍិនាយកសាលា

៥. តើលោកនាយក/នាយិកាមានតួនាទីជានាយកនៅសាលានេះប៉ុន្មានឆ្នាំមកហើយ?

☐ ១. ១ឆ្នាំដល់ ៥ឆ្នាំ ☐ ២. ៥ឆ្នាំ ដល់ ១០ឆ្នាំ

☐ ៣. ១០ឆ្នាំ ដល់ ២០ឆ្នាំ ☐ ៤. ច្រើនជាង ២០ឆ្នាំ

៦. តើលោកនាយក/នាយិកមានក្របខណ្ឌប្រភេទអ្វី?

☐ ១. គ្រូបង្រៀនកម្រិតមូលដ្ឋាន ☐ ២. គ្រូបង្រៀនកម្រិតឧត្តម

៧. សូមបញ្ជាក់ពីកម្រិតសញ្ញាបត្រចុងក្រោយរបស់លោកនាយក/នាយិកា៖

☐ ១. សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

☐ ២. សញ្ញាបត្របរិញ្ញាបត្រ (ឯកទេស៖……………………………………………………)

☐ ៣. សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ (ឯកទេស៖…………………………………………)

☐ ៤. សញ្ញាបត្របណ្ឌិត (ឯកទេស៖………………………………………………………….)

៨. លោកនាយក/លោកស្រីនាយិកា ធ្លាប់បានចូលរួមវគ្គបំប៉នខ្លីៗទាក់ទងនឹងការគ្រប់គ្រងដែរឬទេ? បើបាន វគ្គនោះមានរយៈពេលប៉ុន្មាន?

☐ ១. មាន (រយៈពេល)................................ ☐ ២. គ្មាន

## ផ្នែកទី៣៖ ការគ្រប់គ្រងសាលារៀន

៩. តើសាលារៀនមានគ្រូភាសាអង់គ្លេសប៉ុន្មាននាក់?

..........................................................................................................................

..........................................................................................................................

១០. តើពួកគាត់សុទ្ធតែមានជំនាញឯកទេសភាសាអង់គ្លេសទាំងអស់ឬយ៉ាងណា?

..........................................................................................................................

..........................................................................................................................

១១. តើពួកគាត់សុទ្ធតែមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្រៀន ឬយ៉ាងណា?

..........................................................................................................................

..........................................................................................................................

១២. តើលោកគ្រូ អ្នកគ្រូមុខវិជ្ជាភាសាអង់គ្លេស បានទទួលការបណ្តុះបណ្តាលរយៈពេលខ្លី ឬចូលរួមសិក្ខាសាលាទាក់ទងទៅនឹងវិធីសាស្រ្តបង្រៀនភាសាអង់គ្លេស រយៈពេល ៥ឆ្នាំចុងក្រោយដែរឬទេ?

☐ ១. មាន ☐ ២. គ្មាន

១៣. តើលោកនាយក/នាយិកាគិតថាគ្រូភាសាអង់គ្លេសបានអនុវត្តការងាររបស់ខ្លួនដល់កម្រិតណាពាក់ព័ន្ធទៅនឹង៖

☐ ១. ការមកបង្រៀនទៀងទាត់

..........................................................................................................................

..........................................................................................................................

☐ ២. ការរៀបចំកិច្ចតែងការបង្រៀន

..........................................................................................................................

..........................................................................................................................

☐ ៣. ការពង្រឹងចំណេះដឹង និងជំនាញទាក់ទងនឹងមុខវិជ្ជាកំពុងបង្រៀន

..........................................................................................................................

..........................................................................................................................

☐ ៤. ការយកចិត្តទុកដាក់លើការសិក្សារបស់សិស្ស

..........................................................................................................................

.........................................................................................................................

## ផ្នែកទី៣៖ សម្ភារសិក្សា

១៤. តើសិស្ស មានសៀវភៅពុម្ពភាសាអង់គ្លេសគ្រប់គ្នាដែរឬទេ?

.........................................................................................................................

.........................................................................................................................

១៥. តើសាលា មានសម្ភារឧបទេសអ្វីខ្លះ សម្រាប់ជួយដល់ការគាំទ្រការបង្រៀនភាសាអង់គ្លេសរបស់លោកគ្រូ អ្នកគ្រូ?

.........................................................................................................................

.........................................................................................................................

១៦. តើលោកគ្រូ អ្នកគ្រូបានប្រើប្រាស់សម្ភារទាំងនេះដល់កម្រិតណា?

.........................................................................................................................

.........................................................................................................................

១៧. តើលោកនាយក/នាយិកា មានសំណូមពរអ្វីខ្លះដើម្បីឱ្យស្ថានភាពនៃការបង្រៀន និងរៀនភាសាអង់គ្លេសនៅក្នុងសាលារបស់លោកនាយក/នាយិកាកាន់តែប្រសើរជាងនេះទៀត?

.........................................................................................................................

.........................................................................................................................

.........................................................................................................................

.........................................................................................................................

# កម្រងសំណួរសម្រាប់គ្រូ

ខ្ញុំបាទឈ្មោះ អ៊ឹម សិរីរដ្ឋ ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ បានរៀបចំការសិក្សាស្រាវជ្រាវមួយទាក់ទងទៅនឹងប្រធានបទ «ការរៀន និងបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ ករណីសិក្សាៈ វិទ្យាល័យ គិត ម៉េង ប្រាសាទ ខេត្ត តាកែវ»។ អាស្រ័យហេតុនេះសូមលោកគ្រូ អ្នកគ្រូមេត្តាជួយឆ្លើយនូវកម្រងសំណួរនេះតាមភាពជាក់ស្តែងរបស់ខ្លួន។ **រាល់ចម្លើយរបស់លោកគ្រូ/អ្នកគ្រូទាំងអស់ នឹងត្រូវបានរក្សាជាការសម្ងាត់ និងត្រូវ**ប្រើសម្រាប់តែសរសេរនិក្ខេបបទនេះប៉ុណ្ណោះ។ សូមថ្លែងអំណរគុណដល់លោកគ្រូ អ្នកគ្រូទាំងអស់ដែលបានចំណាយពេលវេលាក្នុងការចូលរួមជាមួយខ្ញុំបាទ ក្នុងការសិក្សាស្រាវជ្រាវដ៏មានសារៈសំខាន់មួយនេះ។

**សូមបំពេញ ដោយគូសសញ្ញា ✓ ក្នុងប្រអប់ ☐ និង បំពេញចន្លោះតាមភាពជាក់ស្តែងរបស់លោកគ្រូ អ្នកគ្រូដែលជ្រើសរើស ។**

## ផ្នែកទី១៖ ព័ត៌មានទូទៅ

ខេត្ត៖ តាកែវ

១. ស្រុក/ក្រុង៖ …………………………………… ២. សាលា៖ ……………………………………

៣. ភេទ៖ ☐ ១. ប្រុស ☐ ២. ស្រី

## ផ្នែកទី២៖ គុណវុឌ្ឍិគ្រូបង្រៀនភាសាអង់គ្លេស

៤. តើលោកគ្រូ អ្នកគ្រូមានក្របខណ្ឌប្រភេទអ្វី?

☐ ១. គ្រូបង្រៀនកម្រិតបឋម ☐ ២. គ្រូបង្រៀនកម្រិតមូលដ្ឋាន

☐ ៣. គ្រូបង្រៀនកម្រិតឧត្តម

៥. សូមបញ្ជាក់ពីកម្រិតសញ្ញាបត្រចុងក្រោយរបស់លោកគ្រូអ្នកគ្រូ៖

☐ ១. សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ☐ ២. សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

☐ ៣. សញ្ញាបត្របរិញ្ញាបត្រ (ឯកទេស៖.....................................................)

☐ ៤. សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ (ឯកទេស៖.....................................................)

☐ ៥. សញ្ញាបត្របណ្ឌិត (ឯកទេស៖.....................................................)

៦. តើលោកគ្រូ អ្នកគ្រូយល់ថា នៅពេលដែលគ្រូមានសមត្ថភាពខ្ពស់ អាចជួយសិស្សឱ្យឆាប់យល់មេរៀនដល់កម្រិតណា?

☐ ១. ខ្លាំងណាស់ ☐ ២. ខ្លាំង ☐ ៣. មធ្យម ☐ ៤. តិចតួច ☐ ៥. អត់សោះ

៧. តើលោកគ្រូ អ្នកគ្រូមានបទពិសោធន៍បង្រៀនភាសាអង់គ្លេសប៉ុន្មានឆ្នាំ?

☐ ១. តិចជាង ៥ឆ្នាំ ☐ ២. ៦-១០ឆ្នាំ ☐ ៣. ១១-១៥ឆ្នាំ ☐ ៤. ច្រើនជាង ១៥ឆ្នាំ

៨. តើលោកគ្រូ អ្នកគ្រូឆ្លងកាត់វគ្គបណ្ដុះបណ្ដាលខ្លី ឬសិក្ខាសាលាទាក់ទងនឹងគរុកោសល្យ ឬវិធីសាស្ត្របង្រៀនភាសាអង់គ្លេសក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយឬទេ?

☐ ១. មាន ☐ ២. គ្មាន

៩. តើលោកគ្រូ អ្នកគ្រូគិតថា ការចូលរួមវគ្គបណ្ដុះបណ្ដាលខ្លី ឬសិក្ខាសាលាមានប្រយោជន៍ដល់ការបង្រៀនភាសាអង់គ្លេសរបស់លោកគ្រូ អ្នកគ្រូបានកម្រិតណា?

☐ ១. ខ្លាំងណាស់ ☐ ២. ខ្លាំង ☐ ៣. មធ្យម ☐ ៤. តិចតួច ☐ ៥. អត់សោះ

១០. សូមជ្រើសរើសវគ្គបំប៉នខាងក្រោមចំនួន ៣ ដែលលោកគ្រូ អ្នកគ្រូត្រូវការចាំបាច់ដើម្បីបង្រៀនភាសាអង់គ្លេសនៅកម្រិតបឋមភូមិ៖

☐ ១. ចិត្ត-គរុកោសល្យ ☐ ២. វិធីសាស្ត្របង្រៀន

☐ ៣. ពង្រឹងចំណេះដឹងភាសាអង់គ្លេស ☐ ៤. បច្ចេកវិទ្យាព័ត៌មាន (ICT)

☐ ៥. ការផលិត និងប្រើប្រាស់សម្ភារឧបទេស

**ផ្នែកទី៣៖ កម្មវិធីសិក្សា**

១១. តើលោកគ្រូអ្នកគ្រូ មានបំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេសប្រចាំឆ្នាំ សម្រាប់ប្រើប្រាស់ក្នុងការបង្រៀនដែរ ឬទេ?

☐ ១. មាន ☐ ២. គ្មាន

១២. តើបំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេស មានសារៈសំខាន់កម្រិតណាដល់ការបង្រៀនមុខវិជ្ជាភាសាអង់គ្លេសរបស់លោកគ្រូ អ្នកគ្រូ?

☐ ១. ខ្លាំងណាស់ ☐ ២. ខ្លាំង ☐ ៣. មធ្យម ☐៤. តិចតួច ☐ ៥. អត់សោះ

១៣.តើខ្លឹមសារក្នុងសៀវភៅសិក្សាគោល សមស្របទៅនឹងកម្រិតសមត្ថភាពភាសាអង់គ្លេសរបស់សិស្សដែរឬទេ?

☐ ១. មានកម្រិតខ្ពស់ជាងសមត្ថភាពសិស្ស ☐ ២. សមស្របនឹងសមត្ថភាពសិស្ស

☐ ៣. ទាបជាងសមត្ថភាពសិស្ស

១៤. តើចំនួនមេរៀនក្នុងសៀវភៅសិក្សាគោលសមស្របទៅនឹងពេលវេលាដែលត្រូវដាក់ឱ្យបង្រៀនក្នុងមួយឆ្នាំៗ ដែរឬទេ?

☐ ១. សមស្រប ☐ ២. មិនសមស្រប

១៥. តើម៉ោងបង្រៀនភាសាអង់គ្លេសនៅសាលារបស់លោកគ្រូ អ្នកគ្រូ គ្រប់គ្រាន់សម្រាប់ឱ្យសិស្សចេះដែរឬទេ?

☐ ១. គ្រប់គ្រាន់ (បើ ✓ក្នុងប្រអប់លេខ១ សូមបន្តទៅសំណួរទី១៧)

☐ ២. មិនគ្រប់គ្រាន់

១៦. បើមិនគ្រប់គ្រាន់ តើម៉ោងសិក្សាភាសាអង់គ្លេសនៅសាលារដ្ឋ គួរតែមានប៉ុន្មានម៉ោងក្នុងមួយថ្នាក់ មួយសប្ដាហ៍សម្រាប់ការសិក្សារបស់សិស្ស?

☐ ១. ៤ ម៉ោង ☐ ២. ៥ ម៉ោង ☐៣. ៦ ម៉ោង

## ផ្នែកទី៤៖ សម្ភារទ្រទ្រង់ការបង្រៀន

១៧. ស្ថានភាពសម្ភារ និងកម្រិតនៃការប្រើប្រាស់សម្ភាររបស់គ្រូ៖

| ប្រភេទសម្ភារ | ស្ថានភាពសម្ភារជាក់ស្ដែង | | កម្រិតនៃការប្រើប្រាស់សម្ភារបង្រៀនរបស់គ្រូ | | | |
|---|---|---|---|---|---|---|
| | គ្មាន (បើគ្មាន សូមមេត្តាកុំគូសបន្ត) | មាន (បើមាន សូមគូសបន្ត) | ប្រើគ្រប់ពេល (១) | ប្រើញឹកញាប់ (២) | ប្រើម្ដងកាល (៣) | អត់ប្រើសោះ (៤) |
| ១. សៀវភៅសិក្សាគោល | | | | | | |
| ២. សៀវភៅគ្រូ | | | | | | |
| ៣. ម៉ាញ៉េចាក់កាសែត ឬស៊ីឌី | | | | | | |
| ៤. បណ្ណរូបភាព/បណ្ណពាក្យ | | | | | | |
| ៥. បន្ទប់អនុវត្តការស្ដាប់ | | | | | | |
| ៦. បណ្ណាល័យដែលមានឯកសារជាភាសាអង់គ្លេស | | | | | | |

១៨. តើការប្រើសម្ភារឧបទេសគ្រប់ម៉ោងបង្រៀន មានប្រយោជន៍ដល់ការសិក្សាភាសាអង់គ្លេសរបស់សិស្សដល់កម្រិតណា?

☐ ១. ខ្លាំងណាស់ ☐ ២. ខ្លាំង ☐ ៣. មធ្យម ☐ ៤. តិចតួច ☐ ៥. អត់សោះ

## ផ្នែកទី៥៖ សកម្មភាពរៀនរបស់សិស្សក្នុងថ្នាក់

១៩. តើលោកគ្រូ អ្នកគ្រូប្រើប្រាស់សកម្មភាពទាំងនេះនៅក្នុងការបង្រៀនបានកម្រិតណា?

| សកម្មភាព | គ្រប់ពេល | ញឹកញាប់ | ពេលខ្លះ | កម្រណាស់ | អត់សោះ |
|---|---|---|---|---|---|
| ១. សិស្សធ្វើការម្នាក់ឯង | | | | | |
| ២. សិស្សធ្វើការជាដៃគូរ | | | | | |
| ៣. សិស្សធ្វើការជាក្រុម | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៤. សិស្សទាំងអស់ធ្វើការរួមគ្នា | | | | | |

២០. តើក្នុងមួយសប្តាហ៍លោកគ្រូ អ្នកគ្រូបានផ្តល់កិច្ចការផ្ទះឱ្យសិស្សធ្វើ បានប៉ុន្មានដង?

☐ ៤ ដង ☐ ៣ ដង ☐ ២ ដង ☐ ១ ដង ☐ អត់សោះ

២១. តើលោកគ្រូ អ្នកគ្រូបានព្យាយាមលើកទឹកចិត្តសិស្សដល់កម្រិតណានៅពេលបង្រៀន?

☐ ១. គ្រប់ពេល ☐ ២. ញឹកញាប់ ☐ ៣.ម្តងម្កាល ☐ ៤. អត់សោះ

## ផ្នែកទី៦៖ ការរៀបចំមេរៀនបង្រៀន

២២. តើលោកគ្រូ អ្នកគ្រូធ្វើកិច្ចតែងការបង្រៀនបានគ្រប់មេរៀនដែរឬទេ?

☐ ១. គ្រប់មេរៀន ☐ ២. ពេលខ្លះ ☐ ៣. កម្រណាស់ ☐ ៤. អត់សោះ

## ផ្នែកទី៧៖ បរិមាណសិស្សក្នុងថ្នាក់

២៣. តើជាមធ្យម ថ្នាក់រៀនដែលលោកគ្រូ អ្នកគ្រូបង្រៀន មានសិស្សចំនួនប៉ុន្មាននាក់?

☐ ១. តិចជាង៣០ ☐ ២. ៣០-៣៥ ☐ ៣. ៣៦-៤០

☐ ៤. ៤១-៤៥ ☐ ៥. ៤៦-៥០ ☐ ៦. ច្រើនជាង ៥០

២៤. តើលោកគ្រូ អ្នកគ្រូយល់ថាចំនួនសិស្សច្រើននៅក្នុងថ្នាក់ធ្វើឱ្យជះឥទ្ធិពលអវិជ្ជមានដល់ការបង្រៀនរបស់លោកគ្រូអ្នកគ្រូដល់កម្រិតណា?

☐ ១. ខ្លាំងណាស់ ☐ ២. ខ្លាំង ☐ ៣. មធ្យម

☐ ៤. តិចតួច ☐ ៥. អត់សោះ

## ផ្នែកទី៨៖ ស្ថានភាពសិក្សារបស់សិស្ស

២៥. តើលោកគ្រូ អ្នកគ្រូសង្កេតឃើញថាសិស្សបានប្រឹងប្រែងក្នុងការរៀនភាសាអង់គ្លេសកម្រិតណា?

| សកម្មភាព | កម្រិតនៃការប្រឹងប្រែង | | | | |
|---|---|---|---|---|---|
| | ខ្លាំងណាស់ | ខ្លាំង | បន្តិច | មធ្យម | ខ្សោយ |
| ១. មករៀនទៀងទាត់ និងទាន់ពេលវេលា | | | | | |
| ២. យកចិត្តទុកដាក់ស្តាប់គ្រូក្នុងម៉ោងសិក្សា | | | | | |
| ៣. ចូលរួមធ្វើសកម្មភាពផ្សេងៗដែលគ្រូដាក់ឱ្យក្នុងថ្នាក់ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៤. ធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យទៀងទាត់ | | | | | |

២៦. បញ្ហាប្រឈមនានាចំពោះការបង្រៀនភាសាអង់គ្លេស ។

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

# **កម្រងសំណួរសម្រាប់សិស្ស**

ខ្ញុំបាទឈ្មោះ អ៊ឹម សិរីរដ្ឋ ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ បានរៀបចំការសិក្សាស្រាវជ្រាវមួយទាក់ទងទៅនឹងប្រធានបទ «ការរៀន និង បង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ ករណីសិក្សាៈ វិទ្យាល័យ គិត ម៉េង ប្រាសាទ ខេត្ត តាកែវ» ។ អាស្រ័យហេតុនេះសូមប្អូនៗ មេត្តាជួយឆ្លើយនូវកម្រងសំណួរនេះតាមភាពជាក់ស្តែងរបស់ខ្លួន។ រាល់ចម្លើយរបស់ប្អូនៗ ទាំងអស់ នឹង ត្រូវបានរក្សាជាការសម្ងាត់ និង ត្រូវប្រើសម្រាប់តែសរសេរនិក្ខេបបទនេះប៉ុណ្ណោះ។ សូមថ្លែងអំណរគុណដល់ប្អូនៗទាំងអស់ដែលបានចំណាយពេលវេលាក្នុងការចូលរួមជាមួយខ្ញុំបាទក្នុងការសិក្សាស្រាវជ្រាវដ៏មានសារៈសំខាន់មួយនេះ។

<u>សូមបំពេញ ដោយគូសសញ្ញា ✓ ក្នុងប្រអប់ ☐ និង បំពេញចន្លោះតាមភាពជាក់ស្តែងរបស់ប្អូនៗដែលបានជ្រើសរើស ។</u>

## **ផ្នែកទី១៖ ព័ត៌មានទូទៅ**

ខេត្ត៖ តាកែវ

១. ស្រុក/ក្រុង៖ …………………………………… ២. សាលា៖ ………………………………

៣. ភេទ៖ ☐ ១. ប្រុស ☐ ២. ស្រី

## **ផ្នែកទី២៖ គុណវុឌ្ឍិគ្រូបង្រៀនភាសាអង់គ្លេស**

៤. តើគ្រូភាសាអង់គ្លេសរបស់ប្អូនមានចំណេះដឹងកម្រិតណា?

☐ ១. ខ្លាំងណាស់ ☐ ២. ខ្លាំង ☐ ៣. មធ្យម ☐ ៤. ខ្សោយ

៥. តើគ្រូដែលមានសមត្ថភាពខ្ពស់ ជួយឱ្យប្អូនឆាប់យល់មេរៀនបានដល់កម្រិតណា?

☐ ១. ខ្លាំងណាស់ ☐ ២. ខ្លាំង ☐ ៣. មធ្យម ☐ ៤. ខ្សោយ

៦. តើប្អូនយល់ឃើញយ៉ាងណា ចំពោះការបង្រៀនភាសាអង់គ្លេសរបស់គ្រូប្អូន?

☐ ១. ល្អណាស់ ☐ ២. ល្អ ☐ ៣. មធ្យម ☐ ៤. ខ្សោយ

## **ផ្នែកទី៣៖ កម្មវិធីសិក្សា**

៧. តើខ្លឹមសារមេរៀនក្នុងសៀវភៅពុម្ព សមស្របទៅនឹងកម្រិតសមត្ថភាពភាសាអង់គ្លេសរបស់ប្អូនៗឬទេ?

☐ ១. មានកម្រិតខ្ពស់ជាងសមត្ថភាពរបស់ខ្ញុំ ☐ ២. សមស្របនឹងសមត្ថភាពរបស់ខ្ញុំ

☐ ៣. ទាបជាងសមត្ថភាពរបស់ខ្ញុំ

៨. តើ ប្អូនចាប់អារម្មណ៍ដូចម្ដេចចំពោះសៀវភៅពុម្ពភាសាអង់គ្លេសដែលកំពុងរៀនសព្វថ្ងៃ?

☐ ១. គួរឱ្យចាប់អារម្មណ៍ខ្លាំង ☐ ២. មិនសូវគួរឱ្យចាប់អារម្មណ៍ ☐ ៣. គួរឱ្យធុញទ្រាន់

៩. តើម៉ោងភាសាអង់គ្លេសនៅសាលារបស់ប្អូន គ្រប់គ្រាន់សម្រាប់ការរៀនរបស់ប្អូនឬទេ?

☐ ១. គ្រប់គ្រាន់ (បន្តទៅសំណួរទី១១) ☐ ២. មិនគ្រប់គ្រាន់

១០. បើមិនគ្រប់គ្រាន់ តើម៉ោងសិក្សាភាសាអង់គ្លេសនៅសាលារដ្ឋគួរតែមានប៉ុន្មានម៉ោងក្នុងមួយសប្ដាហ៍ទើបគ្រប់គ្រាន់ក្នុងការសិក្សា?

☐ ១. ៥ ម៉ោង ☐ ២. ៦ ម៉ោង ☐ ៣. ៤ ម៉ោង

## ផ្នែកទី៤៖ សម្ភារទ្រទ្រង់ការបង្រៀន និងរៀន

១១. ស្ថានភាពសម្ភារ និងកម្រិតនៃការប្រើប្រាស់សម្ភាររបស់គ្រូ៖

| ប្រភេទសម្ភារ | កម្រិតនៃការប្រើប្រាស់សម្ភារបង្រៀនរបស់គ្រូ | | | |
|---|---|---|---|---|
| | ប្រើគ្រប់ពេល (១) | ប្រើញឹកញាប់ (២) | ប្រើម្ដងកាល (៣) | អត់ប្រើសោះ (៤) |
| ១. សៀវភៅពុម្ព | | | | |
| ២. ម៉ាញ៉េចាក់កាសែត ឬស៊ីឌី | | | | |
| ៣. បណ្ណរូបភាព / បណ្ណពាក្យ | | | | |
| ៤. បន្ទប់អនុវត្ត (ការស្ដាប់ និងមើលវីឌីអូ) | | | | |
| ៥. បណ្ណាល័យដែលមានឯកសារជាភាសាអង់គ្លេស | | | | |

១២. ការប្រើសម្ភារឧបទេសគ្រប់គ្រាន់ តើមានប្រយោជន៍ដល់ការសិក្សាភាសាអង់គ្លេសរបស់ប្អូនដល់កម្រិតណា?

☐ ១. ខ្លាំងណាស់ ☐ ២. ខ្លាំង ☐ ៣. មធ្យម ☐ ៤. តិចតួច ☐ ៥. អត់សោះ

## ផ្នែកទី៥៖ សកម្មភាពរៀនក្នុងថ្នាក់

១៣. តើលោកគ្រូ អ្នកគ្រូប្រើប្រាស់សកម្មភាពទាំងនេះនៅក្នុងការបង្រៀនបានកម្រិតណា?

| សកម្មភាព | គ្រប់ពេល | ញឹកញាប់ | ពេលខ្លះ | កម្រណាស់ | អត់សោះ |
|---|---|---|---|---|---|
| ១. សិស្សធ្វើការម្នាក់ឯង | | | | | |
| ២. សិស្សធ្វើការជាដៃគូ | | | | | |
| ៣. សិស្សធ្វើការជាក្រុម | | | | | |
| ៤. សិស្សទាំងអស់ធ្វើការរួមគ្នា | | | | | |

១៤. តើលោកគ្រូ អ្នកគ្រូបានលើកទឹកចិត្តឱ្យខំរៀនភាសាអង់គ្លេសដល់កម្រិតណានៅពេលបង្រៀន?

☐ ១. គ្រប់ពេល ☐ ២. ញឹកញាប់ ☐ ៣.ម្តងម្កាល ☐ ៤. អត់សោះ

១៥. តើគ្រូមុខវិជ្ជាភាសាអង់គ្លេសបានដាក់កិច្ចការផ្ទះឱ្យប្អូនធ្វើ ប៉ុន្មានដងក្នុងមួយសប្តាហ៍?

១.☐ ៤ ដង ២.☐ ៣ ដង ៣.☐ ២ ដង ៤.☐ ១ ដង ៥.☐ អត់សោះ

## ផ្នែកទី៦៖ បរិមាណសិស្សក្នុងថ្នាក់

១៦. តើនៅក្នុងថ្នាក់រៀនប្អូន ជាមធ្យមមានសិស្សប៉ុន្មាននាក់?

☐ ១. តិចជាង៣០ ☐ ២. ៣០-៣៤ ☐ ៣. ៣៥-៣៩

☐ ៤. ៤០-៤៤ ☐ ៥. ៤៥-៤៩ ☐ ៦. ចាប់ពី ៥០

១៧. តើចំនួនសិស្សច្រើននៅក្នុងថ្នាក់អាចធ្វើឱ្យជះឥទ្ធិពលអវិជ្ជមានដល់ការសិក្សាដល់កម្រិតណា?

☐ ១. ខ្លាំងណាស់ ☐ ២. ខ្លាំង ☐ ៣. មធ្យម ☐ ៤. តិចតួច ☐ ៥. អត់សោះ

## ផ្នែកទី៧៖ ស្ថានភាពសិក្សារបស់សិស្ស

១៨. តើប្អូនបានប្រឹងប្រែងក្នុងការសិក្សាភាសាអង់គ្លេសនៅក្នុងថ្នាក់ដល់កម្រិតណា?

| សកម្មភាព | កម្រិតនៃការប្រឹងប្រែង | | | | |
|---|---|---|---|---|---|
| | ល្អណាស់ | ល្អ | បង្គួរ | មធ្យម | ខ្សោយ |
| ១. មករៀនទៀងទាត់ និងទាន់ពេលវេលា | | | | | |
| ២. យកចិត្តទុកដាក់ស្ដាប់គ្រូក្នុងម៉ោងសិក្សា | | | | | |
| ៣. ចូលរួមធ្វើសកម្មភាពផ្សេងៗដែលគ្រូដាក់ឱ្យក្នុងថ្នាក់ | | | | | |
| ៤. ធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យទៀងទាត់ | | | | | |

១៩. សំណូមពរទាក់ទងទៅនឹងបញ្ហាប្រឈមនានាចំពោះការសិក្សាភាសាអង់គ្លេសរបស់ប្អូន។

..............................................................................................................................

..............................................................................................................................

..............................................................................................................................

## តារាងទី៣ (ចម្លើយកម្រងសំណួរ)

| សំនួរ | ចំនួន(នាក់) | អប្បបរមា | អតិបរមា | មធ្យម | គំលាតស្តង់ដា |
|---|---|---|---|---|---|
| ចំណេះដឹងគ្រូ | 250 | 1 | 3 | 1.58 | 0.61 |
| គ្រូដែលមានសម្ថភាពខ្ពស់ | 250 | 1 | 4 | 2.33 | 0.63 |
| ការបង្រៀនរបស់គ្រូ | 250 | 1 | 4 | 1.79 | 0.64 |
| សៀវភៅពុម្ភ និង សម្ថភាព | 250 | 1 | 2 | 1.30 | 0.45 |
| ចំណាប់អារម្មណ៍លើសៀវភៅពុម្ភ | 250 | 1 | 2 | 1.13 | 0.33 |
| ចំនួនម៉ោង (គ្រប់?) | 250 | 1 | 2 | 1.97 | 0.17 |
| គួរមានប៉ុន្មានម៉ោង? | 250 | 2 | 3 | 2.03 | 0.17 |
| ស្ថានភាពសម្ភារៈបង្រៀន | 250 | 2 | 3 | 2.78 | 0.17 |
| ការប្រើប្រាស់សម្ភារៈបង្រៀន | 250 | 1 | 4 | 2.59 | 0.64 |
| សកម្មភាពសិស្សនិងគ្រូ | 250 | 2 | 4 | 2.92 | 0.49 |
| ការលើកទឹកចិត្តរបស់គ្រូ | 250 | 1 | 3 | 1.53 | 0.66 |
| កិច្ចការផ្ទះ | 250 | 1 | 4 | 2.56 | 0.74 |
| ចំនួនសិស្សក្នុងថ្នាក់ | 250 | 2 | 5 | 3.93 | 0.47 |
| ឥទ្ធិពលនៃសិស្សច្រើន | 250 | 1 | 4 | 2.52 | 0.73 |
| ការប្រប្រែងរៀនសូត្រក្នុងថ្នាក់ | 250 | 1 | 3 | 2.62 | 0.56 |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ ០៧៥៥ អយក.វិ.ល

*ថ្ងៃ [illegible] ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៩*

**ជម្រាបមក**
**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**
**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ ៖** ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង ៖** កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយក និងលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ចំនួន៨១នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្ត ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូមលោកនាយក និងលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយក និងលោកប្រធានទទួលនូវការគោរពរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
លេខ : ១១៩ ថជអ.ភក

## លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖

| ល.រ | គោត្តនាម និងនាម | ភេទ | សាលាគរុកោសល្យ និង រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កុយ វ៉ាឡង់ទីណា | ប | ខេត្តកំពង់ធំ |
| ២ | គុជ សំអ៊ែល | ប | ខេត្តស្វាយរៀង |
| ៣ |ឃិន សម្បត្តិ | ប | ខេត្តតាកែវ |
| ៤ | ងន ណារី | ប | រាជធានីភ្នំពេញ |
| ៥ | ង៉ែត វ៉ារុធ | ប | ខេត្តតាកែវ |
| ៦ | ងួន ផល្លី | ស | ខេត្តបាត់ដំបង |
| ៧ | ឆន ឈាង | ប | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| ៨ | ឆាយ បូនី | ស | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង |
| ៩ | ជា តត | ប | ខេត្តតាកែវ |
| ១០ | ជា វណ្ណារ៉ា | ប | ខេត្តកំពង់ឆ្នាំង |
| ១១ | ញ៉ែត សំអុល | ប | ខេត្តតាកែវ |
| ១២ | ទឹម ពិន្ទុ | ប | រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី |
| ១៣ | ទុយ សុវណ្ណារិទ្ធ | ប | រាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង និងខេត្តសៀមរាប |
| ១៤ | ធាម ហេង | ប | ខេត្តក្រចេះ |
| ១៥ | ប៉ុម សូគ៉ា | ប | ខេត្តកណ្ដាល |
| ១៦ | ផុន វណ្ណៈ | ប | ខេត្តកណ្ដាល |
| ១៧ | ផូ សុវណ្ណ | ប | រាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| ១៨ | ពុត ពិសី | ប | ខេត្តកំពត |
| ១៩ | ពេជ្រ វៀរ៉ា | ស | ខេត្តត្បូងឃ្មុំ |
| ២០ | ភោគ តុលា | ប | ខេត្តស្វាយរៀង |
| ២១ | លី កុសល | ប | ខេត្តកំពង់ចាម |
| ២២ | លីម សេងហួត | ប | ខេត្តបាត់ដំបង |
| ២៣ | លុន ហ៊ាប | ប | ខេត្តកំពង់ចាម |
| ២៤ | លុយ គីមសាន | ប | ខេត្តកណ្ដាល |
| ២៥ | វ៉ា សុភក្តិ | ប | ខេត្តព្រៃវែង |
| ២៦ | សន តារាស្មី | ប | ខេត្តកណ្ដាល |
| ២៧ | ស៊ើយ វង្សស៊ុ | ប | ខេត្តស្ទឹងត្រែង |
| ២៨ | សាម សុនិត | ប | ខេត្តកំពង់ចាម |
| ២៩ | សុទ្ធ ស្រីនាង | ស | ខេត្តកំពង់ស្ពឺ |
| ៣០ | សៀង គីមឈៀន | ប | ខេត្តកណ្ដាល |
| ៣១ | ស្រី មៅ | ប | រាជធានីភ្នំពេញ |
| ៣២ | ហៃល ម៉ូណា | ប | រាជធានីភ្នំពេញ |
| ៣៣ | ហៃយ ចម្លង | ស | រាជធានីភ្នំពេញ |
| ៣៤ | ឡាយ វីរៈ | ប | ខេត្តឧត្តរមានជ័យ |
| ៣៥ | ឡុង ចំណាន | ប | ខេត្តកំពង់ចាម |
| ៣៦ | អ៊ុន ចាន់ថា | ប | ខេត្តស្វាយរៀង |
| ៣៧ | អ៊ីវ សុធិ | ប | រាជធានីភ្នំពេញ |
| ៣៨ | អ៊ឹម សិរីវដ្ឍ | ប | ខេត្តតាកែវ |
| ៣៩ | អ៊ុក រិទ្ធិ | ប | ខេត្តសៀមរាប |
| ៤០ | អុន សេងទ្រី | ប | ខេត្តកំពង់ធំ |
| ៤១ | អៀង គីមឈាន | ប | ខេត្តកំពង់ចាម |

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័កព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

**កន្លែងទទួល៖**

- សាលារាជធានី-ខេត្តពាក់ព័ន្ធ
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
- មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារៈវិទ្យាស្ថានជាតិអប់រំ

**បណ្ឌិត.សៀង សុវណ្ណារ៉ា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៧២៤ **អយក.** ១ស
(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម **យក់ ឌីយ** | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម **លាង សេងហាក់** | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម **ម៉ក់ ខយ** | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកដឹកនាំវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៧២៥ **អយក.** ខ្ម
(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ រីក | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម ឡៅ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យួន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក នី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត នី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈុក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។ ៗ

ថ្ងៃ សុក្រ ១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ